ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើស
# រើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ
# នៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ

SCHOOL PRINCIPALS' PERSPECTIVE ON TEACHER OF HIGHER EDUCATION RECRUITMENT AND TRAINING REFORM IN CAMBODIA, CASE STUDY: TAKEO PROVINCE

**ដោយ**/ by

**សែម ជ្រាន**/ SEM CHREAN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

**ក្រសួងអប់រំ យុវជន និងកីឡា**
Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**
National Institute of Education

# និក្ខេបបទ

# ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ នៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ

## SCHOOL PRINCIPALS' PERSPECTIVE ON TEACHER OF HIGHER EDUCATION RECRUITMENT AND TRAINING REFORM IN CAMBODIA, CASE STUDY: TAKEO PROVINCE

**ដោយ**/ by

**សែម ជ្រាន**/ SEM CHREAN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**
**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

**គ្រូណែនាំគោល៖ ឯកឧត្តមបណ្ឌិត សិត សេង**
**គ្រូណែនាំរង ៖ បណ្ឌិត នួង វីរ៉ា**

# សេចក្តីអះអាងរបស់បេក្ខនារី

នាងខ្ញុំឈ្មោះ សែម ជ្រាន ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ឥទ្ធិពលរបស់នាយកសាលាលើគំរោងគ្រប់គ្រងការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ** » សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំ ពិតប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

**ហត្ថលេខា**

**សែម ជ្រាន**

# លិខិតបញ្ជាក់

**ឯកឧត្តមបណ្ឌិត សិត សេង** ជាគ្រូណែនាំគោល

**បណ្ឌិត នួន វីរ៉ា** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **សែម ជ្រាន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី **«ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សាខេត្តតាកែវ»** ពិតប្រាកដមែន។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣

**ឯកឧត្តមបណ្ឌិត សិត សេង**

នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

**បណ្ឌិត នួន វីរ៉ា**

នាយករងវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៨/៤៧៣ អយក.ខុទន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ឹង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ រ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី ផ្សោ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋាន វ.ហ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ ៤៥០១ អយក.ខ៦ក

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សៀង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោកទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# មូលន័យសង្ខេប


ការសិក្សាស្រាវជ្រាវនេះ សិក្សាលើប្រធានបទ "**ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ**" គោលបំណងដើម្បីសិក្សាឈ្វេងយល់ពីការយល់ឃើញរបស់នាយកសាលាទៅលើកំណែទម្រង់ការជ្រើសរើស និងបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា និងសិក្សាពីផលជះនៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិដល់សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ (Quantitative Research) ដោយប្រើវិធីបែបពិពណ៌នា (Descriptive Research Design)។ ការប្រមូលទិន្នន័យតាមរយៈការប្រើប្រាស់ឧបករណ៍សម្ភាសន៍ (កម្រងសំណួរ) និងការសម្ភាសន៍ដោយផ្ទាល់ Face to Face (Structured Interview) ដោយប្រើវិធី Purposive Sampling ក្នុងការជ្រើសរើសសំណាក។ អ្នកចូលរួមទាំងអស់មានចំនួន ៤៣នាក់ មានតួនាទីជានាយក នាយិកា នាយករង នាយិការង មកពីវិទ្យាល័យចំនួន២១ ស្ថិតក្នុងស្រុកបាទី ស្រុកព្រៃកប្បាស ស្រុកសំរោង ស្រុកត្រាំកក់ និងស្រុកទ្រាំង នៃខេត្តតាកែវ។ ការវិភាគទិន្នន័យដោយប្រើវិធីបែបពណ៌នាស្ថិតិ (Descriptive Statistics) ក្នុងការរកតម្លៃមធ្យម (M) និងតម្លៃគម្លាតស្តង់ដា (SD) ដោយប្រើកម្មវិធី SPSS។

លទ្ធផលស្រាវជ្រាវ បានបង្ហាញពីឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ក្នុងការចូលរួមចំណែកធ្វើឱ្យមានភាពប្រសើរឡើង ផ្តល់នូវប្រសិទ្ធភាព និងផលជះវិជ្ជមានក្នុងការអនុវត្តការងារនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ ដោយ M របស់សូចនាករទី១ ដល់ ទី៩ និងសូចនាករទី១៧ ដល់ ទី២៩ មានតម្លៃលើសពី ៣.៥០។ មិនតែប៉ុណ្ណោះក៏បានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមដែលធ្លាប់កើតមាន ដោយ M របស់សូចនាករទី១០ ទី១២ ដល់ ទី១៦ និងទី៣០ ដល់ ទី៣២ មានតម្លៃលើសពី ៣.៥០។ M នៃសូចនាករទី១១ មានតម្លៃទាបជាង ៣.៥០ បង្ហាញថាការចូលរួមចំណែកដោះស្រាយបញ្ហាខ្វះខាតគ្រូបង្រៀនពុំរ៉ែនៅតំបន់ជនបទ តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល ពុំទាន់ទទួលបានលទ្ធផលជាវិជ្ជមាននៅឡើយ ដោយសារអត្រានៃការទទួលបានបេក្ខជនក្នុងមូលដ្ឋានឱ្យចូលបម្រើការងារក្នុងអាជីពជាគ្រូបង្រៀននៅមានកម្រិត។

# Abstract

This research study studies on the topic "SCHOOL PRINCIPALS' PERSPECTIVE ON TEACHER OF HIGHER EDUCATION RECRUITMENT AND TRAINING REFORM IN CAMBODIA, CASE STUDY: TAKEO PROVINCE" is to understand about perspective of school principals on reforming teacher of higher education recruitment and training in Cambodia and to study about the impact of implementing teacher of higher education recruitment and training reform to upper secondary school.

Researcher used Quantitative Research Method by using Descriptive Research Design. The data were collected by Interview Tools (Questionnaires) and face-to-face interviews (Structured Interview) use Purposive Sampling to select samples. There were 43 participants, the principals and deputy from 21 upper secondary schools of Bati, Prey Kabas, Samrong, Tram Kak, and Traing District in Takeo Province. The Data were analyzed by using Descriptive Statistics in SPSS to define Mean (M) and Standard Deviation (SD) values.

The research results show about best practices of implementing teacher of higher education recruitment and training reform in Cambodia has contributed to the improvement, effectiveness, and positive impact on work performance at upper secondary school as M value of the 1st to 9th and 17th to 29th indicators are higher than 3.50. Moreover, this reform also contributed to solve the challenges that have been caused as M value of the 10th, 12th to 16th and 30th to 32nd indicators are higher than 3.50. M value of the 11th indicator is less than 3.50, indicating about the contribution to addressing the shortage of chronic teachers in Rural area, Difficulty area, and Remotes area has not yet yielded positive results due to the limitation rate of admission the local candidates to the teaching profession.

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ" បានបញ្ចប់ប្រកបដោយជោគជ័យអាស្រ័យដោយមានការផ្តល់ឱកាស ការចង្អុលបង្ហាញ ការលើកទឹកចិត្ត ការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ នាងខ្ញុំឈ្មោះ **សែម ប្រាន** ជាអ្នកសិក្សាស្រាវជ្រាវ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ជាអ្នកគ្រប់គ្រងដ៏ឆ្នើម។

ឯកឧត្តមបណ្ឌិត **សិត សេង** នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ជាគ្រូណែនាំគោល និងលោកបណ្ឌិត **នួន វីរ៉ា** នាយករងវិទ្យាស្ថានជាតិអប់រំ ជាគ្រូណែនាំរង ក្នុងការសរសេរនិក្ខេបបទ ផ្តល់ឱកាស ជំរុញទឹកចិត្ត ចង្អុលបង្ហាញ តម្រង់ទិស និងចំណេះដឹងបន្ថែមជាច្រើនសម្រាប់ការសរសេរនិក្ខេបបទស្រាវជ្រាវហូតទទួលបានជោគជ័យ។

លោកឪពុក **ម៉ិល សឿន** និងអ្នកម្តាយ **កែវ នី** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ការទូន្មាន ការអប់រំ ការឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី និងថវិកា ព្រមទាំងបានផ្តល់នូវឱកាសឱ្យកូនបានសិក្សារៀនសូត្រ និងស្វែងយល់ពីសង្គមបានយ៉ាងទូលំទូលាយ។

ឧត្តមស្វាមី **ឈន ឧត្តម** ដែលតែងតែលើកទឹកចិត្ត និងគាំទ្រគ្រប់កាលៈទេសៈទាំងអស់។ កូនស្រីជាទីស្រលាញ់ **សំបូរ ពេជ្រម៉ូលិកា** ដែលជាកម្លាំងចិត្ត និងកម្លាំងជំរុញដ៏សំខាន់សម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងដៃគូសហការ ដែលបានរៀបចំកម្មវិធីបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា និងផ្តល់អាហារូបករណ៍សម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។

ថ្នាក់ដឹកនាំគ្រប់គ្រង គ្រូឧទ្ទេស និងមន្ត្រីពាក់ព័ន្ធ នៃវិទ្យាស្ថានជាតិអប់រំ សម្រាប់ការបណ្តុះបណ្តាលដ៏មានអត្ថប្រយោជន៍ និងការសម្របសម្រួល។

លោកគ្រូអ្នកគ្រូដែលបានបង្រៀន និងអប់រំតាំងពីបឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។

ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ថ្នាក់ដឹកនាំ និងក្រុមការងារក្នុងការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល ដែលតែងតែផ្តល់ឱកាស លើកទឹកចិត្ត និងសម្របសម្រួលភារកិច្ចដើម្បីដំណើរការសិក្សា និងការស្រាវជ្រាវទទួលបានលទ្ធផលផ្លែផ្កា។

ថ្នាក់ដឹកនាំ និងក្រុមការងារគម្រោង The Cambodia Charitable Trust សម្រាប់ការសម្របសម្រួលពេលវេលា ការផ្តល់ឱកាស ការជំរុញទឹកចិត្ត និងសាទរចំពោះការខិតខំប្រឹងប្រែងរបស់បុគ្គលិកក្រោមឱវាទ។

លោកនាយក លោកស្រីនាយិកា លោកនាយករង លោកស្រីនាយិការង គ្រឹះស្ថានមធ្យមសិក្សាទាំង២១ ក្នុងខេត្តតាកែវ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់កិច្ចសម្ភាសន៍ ផ្តល់ជាតុចូលសំខាន់ៗ និងសហការលើដំណើរការប្រមូលទិន្នន័យ។

ក្រុមនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ និងនិស្សិតរៀមច្បងដែលតែងតែលើកទឹកចិត្ត ចែករំលែកចំណេះដឹង ជាអ្នកផ្តល់ការពិភាក្សា ប្រឹក្សា ផ្តល់បទពិសោធ និងសហការក្នុងការសិក្សា ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ចំណេះដឹង។

សូមលោកឪពុក អ្នកម្តាយ ឧត្តមស្វាមី កូនស្រីជាទីស្រលាញ់ លោកគ្រូណែនាំគោល លោកគ្រូណែនាំរង ថ្នាក់ដឹកនាំ លោកគ្រូ អ្នកគ្រូ និងភាគីពាក់ព័ន្ធដូចមានរាយនាមខាងលើ មេត្តាទទួលនូវការគោរព និងសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអំពីនាងខ្ញុំ។ នាងខ្ញុំសូមគោរពជូនពរ សូមមានសុខភាពល្អ កម្លាំងមាំមួន សុខសុវត្ថិភាព និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

សូមអរគុណ!

# មាតិកា


សេចក្ដីអះអាងរបស់បេក្ខនារី ........ i

លិខិតបញ្ជាក់ ........ ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iii

មូលន័យសង្ខេប ........ vii

Abstract ........ viii

លិខិតថ្លែងអំណរគុណ ........ ix

បញ្ជីរូបភាព និងក្រាហ្វ ........ xv

បញ្ជីតារាង ........ xvi

អក្សរកាត់ ........ xviii


## ជំពូក ១

## សេចក្ដីផ្ដើម


១.១ ផ្ទៃខាងក្រោយនៃការស្រាវជ្រាវ ........ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 2

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 8

១.៤ សំណួរស្រាវជ្រាវ ........ 8

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ 8

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ 9

១.៧ ក្របខ័ណ្ឌគោលគំនិតនៃការស្រាវជ្រាវ ........ 9

១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 10

## ជំពូក ២

## រំលឹកទ្រឹស្តី

**២.១ សេចក្តីផ្តើម** ..... 11

**២.២ ពាក្យគន្លឹះ** ..... 12

**២.៣ ទ្រឹស្តីពាក់ព័ន្ធ** ..... 13

**២.៤ ស្ថានភាពខេត្តតាកែវ** ..... 16

២.៤.១ ភូមិសាស្ត្រទូទៅ ..... 16

២.៤.២ ស្ថានភាពអប់រំ ..... 17

**២.៥ ស្ថានភាពនៃការជ្រើសរើសគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ** ..... 20

**២.៦ ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ** ..... 25

**២.៧ និន្នាការនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន** ..... 36

២.៧.១ មូលហេតុនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន ..... 36

២.៧.២ អត្ថប្រយោជន៍នៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន ..... 37

២.៧.៣ បញ្ហាប្រឈមនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន ..... 37

## ជំពូក ៣

## វិធីសាស្ត្រស្រាវជ្រាវ

**៣.១ សេចក្តីផ្តើម** ..... 38

**៣.២ វិធីសាស្ត្រនៃការស្រាវជ្រាវ** ..... 38

**៣.៣ ការប្រមូលទិន្នន័យ** ..... 39

**៣.៤ ឧបករណ៍ស្រាវជ្រាវ** ..... 40

**៣.៥ ទំហំសំណាក និងការធ្វើសំណាក** ..... 42

**៣.៦ ការវិភាគទិន្នន័យ** ..... 44

**៣.៧ ក្រមសីលធម៌នៃការស្រាវជ្រាវ** ........ 45

**ជំពូក ៤**

**លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា**

**៤.១ ព័ត៌មានប្រជាសាស្ត្រ** ........ 46

**៤.២ ឧត្តមានុវត្តន៍នៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូ** ........ 48

៤.២.១ ឧត្តមានុវត្តន៍នៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ ........ 48

៤.២.២ ឧត្តមានុវត្តន៍នៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ........ 53

**៤.៣ ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់** ........ 61

៤.៣.១ ការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ ........ 61

៤.៣.២ ការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ........ 66

**៤.៤ ការពិភាក្សាពីការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូ** ........ 69

៤.៤.១ កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ ........ 69

៤.៤.២ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ........ 69

**ជំពូក ៥**

**សេចក្តីសន្និដ្ឋាន និងសំណូមពរ**

**៥.១ សេចក្តីសន្និដ្ឋាន** ........ 71

**៥.២ សំណូមពរ** ........ 73

**ឯកសារយោង** ........ 76

**ឧបសម្ព័ន្ធ ១៖ ឧបករណ៍ប្រមូលទិន្នន័យ** ........ 84

**ឧបសម្ព័ន្ធ ២៖ លិខិតបញ្ជាក់ការគណៈកម្មការការពារនិក្ខេបបទ** ........ 90

**ឧបសម្ព័ន្ធ ៣៖ ប្រធានបទនិក្ខេបបទស្រាវជ្រាវ**.....93

**ឧបសម្ព័ន្ធ ៤៖ លិខិតឧទ្ទេសនាមគ្រូណែនាំគោល និងគ្រូណែនាំរង**.....98

**ឧបសម្ព័ន្ធ ៥៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ**.....100

**ឧបសម្ព័ន្ធ ៦៖ សំណើចុះប្រមូលទិន្នន័យ**.....101

# បញ្ជីរូបភាព និងក្រាហ្វ


រូបភាព 1 ក្របខ័ណ្ឌគោលគំនិតនៃការសិក្សាស្រាវជ្រាវ ....................9

ក្រាហ្វ 1 ភេទ និងអាយុអ្នកចូលរួមសម្ភាសន៍ ....................46

ក្រាហ្វ 2 កម្រិតវប្បធម៌ ....................47

ក្រាហ្វ 3 កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ ....................47

ក្រាហ្វ 4 បទពិសោធដឹកនាំគ្រប់គ្រង ....................48

ក្រាហ្វ 5 ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ....................52

ក្រាហ្វ 6 ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ....................58

ក្រាហ្វ 7 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូ ....................64

ក្រាហ្វ 8 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ....................68

# បញ្ជីតារាង


តារាង 1 តារាងបែងចែកក្របខ័ណ្ឌប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម "បរិញ្ញា+1" ជំនាន់ទី២៥ .....4

តារាង 2 តារាងបែងចែកក្របខ័ណ្ឌ៣៦០០ កន្លែងសម្រាប់ប្រឡងជ្រើសរើសគរុសិស្ស និស្សិតឆ្នាំ២០២១ ......5

តារាង 3 ស្ថិតិក្របខ័ណ្ឌបុគ្គលិកអប់រំខេត្តតាកែវ ឆ្នាំសិក្សា ២០២២-២០២៣ ......17

តារាង 4 តារាងបែងចែកក្របខ័ណ្ឌ ៣០០០កន្លែង សម្រាប់ការប្រឡងជ្រើសរើសក្នុងឆ្នាំ២០២៣......18

តារាង 5 ស្ថានភាពគ្រូបង្រៀនកម្រិតឧត្តមក្នុងខេត្តតាកែវឆ្នាំ២០២៣ ......19

តារាង 6 រចនាសម្ព័ន្ធនៃកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+១)......28

តារាង 7 តារាងពិន្ទុនិទ្ទេសសរុប និងមូលវិចារ (បរិញ្ញាបត្រ+១)......30

តារាង 8 បណ្ដុំមុខវិជ្ជា និងចំនួនក្រេឌីតតាមប្រភេទនៃការបណ្ដុះបណ្ដាល......33

តារាង 9 រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+២) ឆ្នាំទី១ ឆមាសទី១ ......33

តារាង 10 រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+២) ឆ្នាំទី១ ឆមាសទី២ ......34

តារាង 11 រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+២) ឆ្នាំទី២ ឆមាសទី១......34

តារាង 12 រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+២) ឆ្នាំទី២ ឆមាសទី២ ......35

តារាង 13 តារាងពិន្ទុនិទ្ទេសសរុប និងមូលវិចារ (បរិញ្ញាបត្រ+២)......35

តារាង 14 តារាងវាយតម្លៃការបណ្ដុះបណ្ដាល......36

តារាង 15 វិទ្យាល័យគោលដៅ និងចំនួនសំណាក ......43

តារាង 16 ឧត្តមមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ......49

តារាង 17 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៥ ......52

តារាង 18 ឧត្តមមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិ......54

តារាង 19 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៦ ......59

តារាង 20 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូ ......61

តារាង 21 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៧ ....................................................................65

តារាង 22 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ...........66

តារាង 23 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៨ ....................................................................68

# អក្សរកាត់

| | |
|---|---|
| អយក | ក្រសួងអប់រំ យុវជន និងកីឡា |
| វជអ | វិទ្យាស្ថានជាតិអប់រំ |
| HRMIS | Human Resource Management Information System |
| M | Mean |
| SD | Standard Deviation |
| SPSS | Statistical Package for the Social Sciences |

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូក ១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការអប់រំមានសារៈសំខាន់សម្រាប់សង្គមជាតិ និងសកលលោកទាំងមូល ដោយវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមានសន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមជាតិរីកចម្រើន ភាពរីកចម្រើននៃបច្ចេកវិទ្យា ជាពិសេសគឺបង្កើតមូលធនមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលមុំទី១ ផ្តោតទៅលើការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សពិសេសអភិវឌ្ឍយុវជន ឱ្យក្លាយទៅជាពលរដ្ឋពេញលេញ មានចំណេះដឹង និងជំនាញវិជ្ជាជីវៈច្បាស់លាស់សម្រាប់កសាងសង្គមពុទ្ធិ និងវិបុលភាព ដើម្បីចូលរួមលើកកម្ពស់សេដ្ឋកិច្ចជាតិប្រែក្លាយពីប្រទេសកសិកម្ម ទៅជាប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសអភិវឌ្ឍន៍ឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, 2018) ។ គោលដៅចម្បងនៃផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច គឺការរៀបចំមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ។ ការអប់រំ ដើរតួនាទីយ៉ាងសំខាន់ដើម្បីឈានទៅសម្រេចបានគោលដៅនេះ។ ហេតុនេះ ដើម្បីសម្រេចបាននូវគោលដៅខាងលើ ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើការអនុវត្តគោលនយោបាយធំៗចំនួនពីរ ក្នុងនោះ គោលនយោបាយទី១ គឺធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងគោលនយោបាយទី២ គឺធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការដាក់ចេញនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅចំនួន១៥ចំណុចឈរលើសសរស្តម្ភចំនួនប្រាំ រួមមានការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ការកែលម្អកម្មវិធីបណ្តុះបណ្តាល និងសៀវភៅសិក្សាគោល ការធ្វើអធិការកិច្ចគ្រប់ជ្រុងជ្រោយ ការពង្រឹងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការធ្វើកំណែទម្រង់ឧត្តមសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា, 2019a)។

ម្យ៉ាងវិញទៀត ការផ្តល់អាទិភាពបង្កើតមូលធនមនុស្សដោយផ្តោតលើការកែលម្អការបង្រៀន និងរៀននៅក្នុងថ្នាក់រៀន បានជួយឱ្យមនុស្សមានការអប់រំល្អ មានក្រមសីលធម៌ មានសមត្ថភាពពេញលេញ ដែលនាំឱ្យមនុស្សមានស្មារតីសុទិដ្ឋិនិយម មានទំនោររកប្រាក់ចំណូលបានខ្ពស់ដោយវិជ្ជាជីវៈ ហើយអត្ថប្រយោជន៍នេះ បានជះឥទ្ធិពលដល់ការរីកចម្រើនលើកំណើនសេដ្ឋកិច្ច និងសង្គមជាតិ (Vaccari,V., & Gardinier, M. P., 2019)។

ដើម្បីចូលរួមចំណែកឱ្យការអប់រំទទួលបានប្រសិទ្ធភាព ការបង្កើតយន្តការនៃការជ្រើសរើសគ្រូបង្រៀន និងពង្រឹងគុណភាពបណ្តុះបណ្តាលគ្រូបង្រៀន ជាកត្តាចម្បងដ៏សំខាន់មួយក្នុងការជ្រើសរើស និងអភិវឌ្ឍគ្រូបង្រៀនគ្រប់កម្រិតដើម្បីធានាបានការបង្រៀន និងរៀនមានគុណភាពក្នុងក្របខ័ណ្ឌទូទាំងប្រទេស។ ក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាល និងនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀន ជាពិសេសគ្រូមធ្យមសិក្សាទុតិយភូមិ ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ឱ្យឆ្លើយតបទៅនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (វិទ្យាស្ថានជាតិអប់រំ, 2021a)។ តាមរយៈការពិនិត្យឡើងវិញលើកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំ ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់ សមត្ថភាព ស្មារតីទទួលខុសត្រូវ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈបានផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ (អយក, 2019b)។ ផ្អែកទៅតាមលក្ខណៈទាំងនេះ ជាកត្តាដែលបណ្តាលឱ្យមានការសិក្សាស្រាវជ្រាវលើប្រធានបទ **"ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ"** ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមរបាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៩-២០២០ និងលើកទិសដៅ ឆ្នាំសិក្សា២០២០-២០២១ និងរបាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២០-២០២១ និងលើកទិសដៅ ឆ្នាំសិក្សា២០២១-២០២២ បានបង្ហាញឱ្យឃើញថាស្ថានភាពលើសខ្វះគ្រូបង្រៀនមិនទាន់ដោះស្រាយបាននៅឡើយ បានជាក្រសួង

អប់រំ យុវជន និងកីឡា ព្យាយាមពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ បន្តពង្រឹងការគ្រប់គ្រង និងការធ្វើបច្ចុប្បន្នកម្មទិន្នន័យបុគ្គលិកអប់រំក្នុងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HRMIS)។ទន្ទឹមនឹងនេះ ការជ្រើសរើសបេក្ខជនក្នុងមូលដ្ឋានឱ្យចូលបម្រើការងារក្នុងអាជីពជាគ្រូបង្រៀន ត្រូវបានគេចាត់ទុកជាគំនិតផ្តួចផ្តើមក្នុងការបង្កើតគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាខ្វះខាតគ្រូបង្រៀនពុំរ៉ៃ ជាពិសេសនៅតំបន់ជនបទ តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល។ ការទាក់ទាញបេក្ខជនដែលមានចំណេះដឹង សមត្ថភាពដើម្បីបានបម្រើការងារជាគ្រូបង្រៀនក្នុងសហគមន៍ បានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈម និងកាត់បន្ថយចំនួនគ្រូបង្រៀនផ្លាស់ចេញចូល ឬបោះបង់ការងារ (Benveniste, L., Marshall, J., & Araujo, M. C., 2008a)។

ក្រសួងអប់រំ យុវជន និងកីឡាបានជំរុញការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា គោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងគោលនយោបាយស្តីពីការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ បន្តតាមដាន និងជំរុញការអនុវត្តគោលការណ៍ស្តីពីការប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀន។ ជាមួយគ្នានេះ បានបន្តពិនិត្យតាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលការណ៍ និងសេចក្តីណែនាំពាក់ព័ន្ធ និងការគ្រប់គ្រងធនធានមនុស្ស (អយក, 2022)។ ទន្ទឹមនឹងនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការប្រើប្រាស់ក្របខ័ណ្ឌ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបែងចែកក្របខ័ណ្ឌសម្រាប់ការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩ ដែលក្រសួងអប់រំបានធ្វើកំណែទម្រង់លើនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិឱ្យចូលក្របខ័ណ្ឌ ដោយតម្រូវឱ្យបេក្ខជនជ្រើសរើសប៉ុស្តិ៍សាលារៀន ឬអង្គភាពដែលមានតម្រូវការគ្រូ ផ្អែកតាមតារាងកំណត់ប៉ុស្តិ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបានពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងអង្គភាពក្រោមឱវាទ ស្របតាមចំនួនកូតាបែងចែក និងមុខវិជ្ជាឯកទេស មុននឹងធ្វើការប្រឡងជ្រើសរើស (អយក, 2019a)។ សម្រាប់ក្របខ័ណ្ឌខេត្តតាកែវ ក្រសួងអប់រំបានផ្តល់កូតាជ្រើសរើសចំនួន ៥៥កន្លែង ដោយបែងចែកតាមមុខវិជ្ជាឯកទេសដូចជា អក្សរសាស្ត្រខ្មែរ បារាំង អង់គ្លេស សីលធម៌.ពលរដ្ឋ ប្រវត្តិវិទ្យា ភូមិវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា រូបវិទ្យា និងគណិតវិទ្យា (អយក, 2019b)។

## តារាង 1 តារាងបែងចែកក្របខ័ណ្ឌប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម "បរិញ្ញា+1" ជំនាន់ទី២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

### តារាងបែងចែកក្របខណ្ឌប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២៥ ឆ្នាំ២០១៩

| ល.រ | មុខវិជ្ជា / អង្គភាព | អក្សរ.ខ្មែរ | បារាំង | អង់គ្លេស | សីល.ពលរដ្ឋ | ប្រវត្តិវិទ្យា | ភូមិវិទ្យា | គីមីវិទ្យា | ជីវវិទ្យា | ផែនដី | រូបវិទ្យា | គណិត | ព័ត៌មានវិទ្យា | សេដ្ឋកិច្ច | អគ្គិសនី | អេឡិចត្រូនិច | មេកានិច | បសុវប្បកម្ម | ក្សេត្រសាស្ត្រ | កែច្នៃអាហារ | អរកកីឡា | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | រាជធានីភ្នំពេញ | | | | | | | | | | | | | | | 2 | 2 | | | | | 4 |
| 2 | ស្ទឹងត្រែង | 2 | | 2 | 1 | 1 | 1 | 1 | 1 | 2 | 1 | 3 | 2 | | | | | | | | | 17 |
| 3 | ព្រះវិហារ | 4 | | 1 | 2 | 2 | 1 | 2 | 2 | 2 | 3 | 7 | 1 | | | | | 2 | 2 | | | 31 |
| 4 | កោះកុង | 3 | | 2 | 2 | 1 | 2 | 2 | 2 | 3 | 3 | 3 | 2 | | 2 | | 4 | | | | | 31 |
| 5 | រតនគីរី | 3 | 1 | 2 | 1 | | 1 | 2 | 2 | 2 | 2 | 5 | 1 | | | | | | | | | 22 |
| 6 | មណ្ឌលគីរី | 3 | | 2 | | 1 | 1 | 1 | 1 | 2 | 2 | 4 | 2 | 1 | | | | | | | | 20 |
| 7 | កណ្ដាល | 3 | | 3 | 2 | 4 | 4 | 7 | 4 | 5 | 4 | 10 | 6 | | | 1 | 2 | | | | | 55 |
| 8 | កំពង់ឆ្នាំង | 8 | | 4 | 1 | 1 | 1 | 6 | 3 | 2 | 7 | 14 | 2 | 1 | 3 | | | | | | | 53 |
| 9 | កំពង់ស្ពឺ | 8 | | 3 | 1 | 2 | 3 | 5 | 3 | 3 | 3 | 10 | 1 | 1 | | | | | | | | 43 |
| 10 | បាត់ដំបង | 6 | 1 | 2 | 1 | 1 | 4 | 3 | 4 | 4 | 5 | 6 | 3 | 1 | | | | | | | | 41 |
| 11 | ពោធិ៍សាត់ | 7 | 1 | 2 | 3 | 3 | 3 | 5 | 3 | 3 | 5 | 12 | 2 | 1 | | | | | | | | 50 |
| 12 | បន្ទាយមានជ័យ | 6 | | 8 | 2 | 4 | 3 | 5 | 3 | 2 | 7 | 6 | 2 | 2 | | | 2 | | | | | 52 |
| 13 | សៀមរាប | 12 | | 4 | | 4 | 2 | 2 | 2 | 2 | 5 | 9 | 5 | | | 2 | | | | | | 49 |
| 14 | ឧត្ដរមានជ័យ | 5 | | 2 | 2 | 2 | 2 | 3 | 2 | 2 | | 6 | 2 | 2 | | | | | | | | 30 |
| 15 | ប៉ៃលិន | | | 1 | | | 1 | 1 | 1 | | 1 | 1 | 1 | 1 | | | | | | | | 8 |
| 16 | កំពង់ចាម | 8 | | 4 | 2 | 2 | 1 | 3 | 2 | 4 | 5 | 8 | 4 | | | | | | | | | 43 |
| 17 | ត្បូងឃ្មុំ | 15 | 1 | 6 | 4 | 8 | 5 | 7 | 3 | 7 | 5 | 12 | 6 | 1 | | | | | | | | 80 |
| 18 | កំពង់ធំ | 4 | 1 | 4 | 3 | 2 | 3 | 3 | 2 | 2 | 3 | 7 | 2 | 2 | | | | | | | | 38 |
| 19 | ក្រចេះ | 3 | | 7 | 4 | 2 | 2 | 4 | 5 | 3 | 2 | 5 | 7 | 1 | | | | | | | | 45 |
| 20 | ព្រៃវែង | 21 | 1 | 5 | 4 | 3 | 2 | 10 | 3 | 4 | 10 | 25 | 3 | 2 | | | | | | | | 93 |
| 21 | ស្វាយរៀង | 9 | 1 | 3 | 2 | 1 | 2 | 3 | | 3 | 4 | 9 | | | 3 | 2 | 4 | | | 2 | | 48 |
| 22 | តាកែវ | 12 | 1 | 3 | 2 | 1 | 1 | 6 | 3 | 3 | 8 | 15 | | | | | | | | | | 55 |
| 23 | កំពត | 9 | | 3 | 2 | | 2 | 4 | 1 | 3 | 2 | 11 | 2 | 1 | 1 | 1 | | | 2 | | | 44 |
| 24 | ព្រះសីហនុ | 2 | | 1 | 2 | | 1 | 1 | 1 | 2 | 1 | 1 | | | | | | | | | | 12 |
| 25 | កែប | | 1 | | | 1 | 2 | 2 | | | | 2 | | | | | | | | | | 8 |
| 26 | ម.អរប.កម្ពុជា-ជប៉ុន | | | | | | | | | | | | 2 | | | | 1 | | | | | 3 |
| 27 | វិ.ស្ថាន.អរក កីឡា | | | | | | | | | | | | | | | | | | | | 10 | 10 |
| 28 | វិ.ស្ថានបច្ចេក.កំពង់ស្ពឺ | | | | | | | 1 | | | 1 | | | | 1 | | 2 | | | | | 5 |
| 29 | នាយកដ្ឋានបុគ្គលិក | | | 1 | | | | | | | | | 1 | | | | | | | | | 2 |
| 30 | នា.កិច្ចការប្រឡង | | | 1 | | | | | | | | | 2 | | | | | | | | | 3 |
| 31 | នា.ឧត្តមសិក្សា | | | | | | | | | | | | 2 | | | | | | | | | 2 |
| 32 | នា.សវនកម្មផ្ទៃក្នុង | | | | | | | | | | | | 1 | | | | | | | | | 1 |
| 33 | នា.បច្ចេកវិទ្យាព័ត៌មាន | | | | | | | | | | | | 2 | | | | | | | | | 2 |
| | សរុប | 153 | 9 | 76 | 43 | 46 | 50 | 89 | 53 | 65 | 89 | 191 | 66 | 17 | 10 | 8 | 17 | 2 | 4 | 2 | 10 | 1000 |

*សម្គាល់ ៖ បេក្ខជនជាមន្ត្រីរាជការមកពីខេត្តណាត្រូវជ្រើសរើសប៉ុស្តិ៍នៅខេត្តនោះៗ*

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ .
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ២០១៩
[illegible]ប្រធាននាយកដ្ឋានបុគ្គលិក
នៀ_សុផន

បានឃើញ និងឯកភាព
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា [illegible]

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

នៅឆ្នាំ២០២១ ក្រសួងអប់រំ យុវជន និងកីឡាបានបន្តអនុវត្តនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនអនុលោមតាមឆ្នាំ២០១៩ និងមានការកែទម្រង់នូវកម្មវិធីបណ្តុះបណ្តាលជាពិសេសកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានជាតិអប់រំ ដោយកម្មវិធីនៃការបណ្តុះបណ្តាលត្រូវបានបែងចែកជាពីរកម្រិត គឺ (បរិញ្ញាបត្រ+១) និង(បរិញ្ញាបត្រ+២) ឱ្យឆ្លើយតបទៅនឹងជំនាញអប់រំសតវត្សទី២១ (អយក, 2021a)។ ចំពោះចំនួនកូតាក្របខ័ណ្ឌខេត្តតាកែវសម្រាប់ការប្រឡងជ្រើសរើសគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២១ មានចំនួនសរុប ៨៩កន្លែង ក្នុងនោះ (បរិញ្ញាបត្រ+១) ចំនួន ៧៧កន្លែង និង (បរិញ្ញាបត្រ+២) ចំនួន ១២កន្លែង (អយក, 2020)។

តារាង 2 តារាងបែងចែកក្របខ័ណ្ឌ៣៦០០ កន្លែងសម្រាប់ប្រឡងជ្រើសរើសគរុសិស្ស និស្សិតឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

តារាងបែងចែកក្របខ័ណ្ឌ ៣៦០០កន្លែង សម្រាប់ប្រឡងជ្រើសរើសគរុសិស្ស និស្សិត ឆ្នាំ២០២១

| ល.រ | ក្របខណ្ឌ អង្គភាព | ឧត្តមសិក្សា | ឧត្តម(NIE) សរុប | បរិ+1 | បរិ+2 | អបបរិ+1 | មូលដ្ឋាន សរុប | 12+2 | 12+4 | អជ 12+2 | មូលដ្ឋានអប់រំកាយ និងកីឡា សរុប | 12+2 | 12+4 | បឋមសិក្សា សរុប | 12+2 | 12+4 | មត្តេយ្យសិក្សា | វិ.ស្ថានអប់រំពិសេស | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | រាជធានីភ្នំពេញ | | 4 | | 4 | | 1 | | | 1 | 0 | | | 24 | 20 | 4 | 3 | | 32 |
| 2 | ស្ទឹងត្រែង | | 15 | 15 | | | 24 | 15 | 9 | | 5 | 3 | 2 | 40 | 35 | 5 | 6 | | 90 |
| 3 | ព្រះវិហារ | | 41 | 38 | | 3 | 22 | 15 | 6 | 1 | 4 | 3 | 1 | 28 | 25 | 3 | 5 | | 100 |
| 4 | កោះកុង | | 25 | 23 | | 2 | 18 | 12 | 5 | 1 | 5 | 4 | 1 | 44 | 38 | 6 | 5 | | 97 |
| 5 | រតនគិរី | | 25 | 25 | | | 17 | 11 | 5 | 1 | 4 | 4 | 0 | 56 | 49 | 7 | 8 | | 110 |
| 6 | មណ្ឌលគិរី | | 21 | 21 | | | 12 | 6 | 5 | 1 | 0 | | | 27 | 24 | 3 | 5 | | 65 |
| 7 | កណ្តាល | | 47 | 39 | 8 | | 24 | 14 | 10 | | 3 | 0 | 3 | 80 | 67 | 13 | 5 | | 159 |
| 8 | កំពង់ឆ្នាំង | | 49 | 45 | 4 | | 22 | 13 | 8 | 1 | 7 | 5 | 2 | 45 | 35 | 10 | 8 | | 131 |
| 9 | កំពង់ស្ពឺ | | 41 | 37 | 4 | | 16 | 9 | 6 | 1 | 2 | 2 | 0 | 60 | 50 | 10 | 10 | | 129 |
| 10 | បាត់ដំបង | | 59 | 51 | 8 | | 27 | 17 | 9 | 1 | 14 | 12 | 2 | 130 | 75 | 55 | 18 | | 248 |
| 11 | ពោធិ៍សាត់ | | 37 | 33 | 4 | | 32 | 19 | 12 | 1 | 10 | 6 | 4 | 50 | 38 | 12 | 10 | | 139 |
| 12 | បន្ទាយមានជ័យ | | 50 | 43 | 4 | 3 | 17 | 12 | 4 | 1 | 5 | 5 | 0 | 90 | 70 | 20 | 14 | | 176 |
| 13 | សៀមរាប | | 66 | 61 | 4 | 1 | 50 | 26 | 23 | 1 | 18 | 15 | 3 | 135 | 98 | 37 | 18 | | 287 |
| 14 | ឧត្តរមានជ័យ | | 26 | 26 | | | 23 | 14 | 8 | 1 | 3 | 3 | 0 | 55 | 44 | 11 | 5 | | 112 |
| 15 | ប៉ៃលិន | | 17 | 17 | | | 4 | 1 | 2 | 1 | 2 | 2 | 0 | 20 | 15 | 5 | 4 | | 47 |
| 16 | កំពង់ចាម | | 70 | 61 | 8 | 1 | 18 | 9 | 8 | 1 | 9 | 8 | 1 | 100 | 83 | 17 | 12 | | 209 |
| 17 | ត្បូងឃ្មុំ | | 80 | 72 | 8 | | 31 | 15 | 15 | 1 | 16 | 13 | 3 | 90 | 77 | 13 | 11 | | 228 |
| 18 | កំពង់ធំ | | 49 | 45 | 4 | | 17 | 7 | 9 | 1 | 7 | 5 | 2 | 80 | 69 | 11 | 8 | | 161 |
| 19 | ក្រចេះ | | 40 | 40 | | | 17 | 8 | 8 | 1 | 11 | 11 | 0 | 65 | 56 | 9 | 7 | | 140 |
| 20 | ព្រៃវែង | | 121 | 109 | 12 | | 27 | 12 | 15 | | 18 | 18 | 0 | 110 | 90 | 20 | 10 | | 286 |
| 21 | ស្វាយរៀង | | 39 | 29 | 8 | 2 | 16 | 9 | 6 | 1 | 5 | 4 | 1 | 68 | 60 | 8 | 6 | | 134 |
| 22 | តាកែវ | | 89 | 77 | 12 | | 32 | 18 | 14 | | 0 | | | 80 | 69 | 11 | 8 | | 209 |
| 23 | កំពត | | 32 | 24 | 4 | 4 | 16 | 11 | 5 | | 0 | | | 50 | 43 | 7 | 8 | | 106 |
| 24 | ព្រះសីហនុ | | 22 | 14 | 4 | 4 | 12 | 6 | 5 | 1 | 2 | 2 | 0 | 18 | 16 | 2 | 3 | | 57 |
| 25 | កែប | | 5 | 5 | | | 5 | 1 | 3 | 1 | 0 | | | 5 | 4 | 1 | 3 | | 18 |
| 26 | ថ្នាក់កណ្តាល | 85 | 30 | 30 | | | 0 | | | | 0 | | | 0 | | | | 15 | 130 |
| | សរុប | 85 | 1100 | 980 | 100 | 20 | 500 | 280 | 200 | 20 | 150 | 125 | 25 | 1550 | 1250 | 300 | 200 | 15 | 3600 |

សម្គាល់ ៖ - អជ ៖ ផ្នែកអប់រំបំណិនជីវិត(នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល)។ - អប ៖ ផ្នែកអប់រំបច្ចេកទេស(នៅវិទ្យាស្ថានជាតិអប់រំ)

- មន្ទីរ អយក.រាជធានី ខេត្ត ត្រូវយកចំនួនរួមទៅបែងចែក តាមកម្រិត តាមតម្រូវការចាំបាច់របស់ខ្លួន និងរៀបចំបញ្ជីប៉ុស្តិ៍សាលារៀន រួចផ្ញើទៅក្រសួងវិញ ដើម្បីរៀបចំការប្រឡង។

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០២០

បានឃើញ និងឯកភាព
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ប្រធាននាយកដ្ឋានបុគ្គលិក

ឡៅ សុជីន

Scanned with CamScanner

ក្រសួងអប់រំ បានផ្តល់អាទិភាពដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដើម្បីធ្វើការរៀបចំបញ្ជីប៉ុស្តិ៍សម្រាប់ការប្រឡងជ្រើសរើសដោយកំណត់អាទិភាពសាលារៀនដែលមានតម្រូវការគ្រូបង្រៀនជាចាំបាច់។ បន្ថែមពីនេះ បានកំណត់នូវយន្តការនៃការដាក់ពាក្យ ដោយបេក្ខជនត្រូវជ្រើសរើសប៉ុស្តិ៍មុនការប្រឡងចូលក្របខ័ណ្ឌទៅតាមតារាងកំណត់ប៉ុស្តិ៍របស់ក្រសួងអប់រំ និងតាមតម្រូវការរបស់វិទ្យាល័យ ឬអង្គភាព ដោយមានការបញ្ជាក់ចំណារយល់ព្រមលើកិច្ចសន្យាស្ម័គ្រចិត្តទៅបម្រើការងារពីនាយក នាយិកាគ្រឹះស្ថានសិក្សា ឬប្រធានអង្គភាពដែលបេក្ខជនបានជ្រើសរើសប៉ុស្តិ៍ (អយក, 2021)។ នៅឆ្នាំ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកំណែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ដោយការបណ្តុះបណ្តាលមានរយៈពេលពីរឆ្នាំ (បរិញ្ញាបត្រ+២) គ្រប់មុខវិជ្ជាឯកទេសទាំងអស់ និងកូតាជ្រើសរើស សរុបចំនួន ៧៣៥កន្លែង (អយក, 2023a)។

តាមរយៈការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ គ្រឹះស្ថានសិក្សានីមួយៗត្រូវធ្វើការវិភាគ និងព្យាករណ៍ ក៏ដូចជារៀបចំផែនការតម្រូវការធនធានមនុស្សតាមប្រភេទក្របខ័ណ្ឌ និងមុខវិជ្ជា ដើម្បីផ្តល់ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តរបស់ខ្លួន ធ្វើការពិនិត្យផ្ទៀងផ្ទាត់។ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវម្ចាស់ការត្រួតពិនិត្យ និងរៀបចំស្វ័យប្រកាសសាលារៀនដែលមានតម្រូវការគ្រូបង្រៀនតាមប្រភេទក្របខ័ណ្ឌ និងមុខវិជ្ជាឯកទេស ដោយធ្វើការសហការជាមួយនាយកដ្ឋានបុគ្គលិក នៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបែងចែកតួលេខក្របខ័ណ្ឌឱ្យទៅដល់សាលារៀនខ្វះគ្រូបង្រៀន។ សម្រាប់គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខ័ណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ (អយក, 2019)។

យោងតាម (Brutti, Z., & Sánchez, F, 2017) ប្រទេសកូឡុំប៊ីបានធ្វើកំណែទម្រង់ជាមួយនឹងការប្រកួតប្រជែងជ្រើសរើសឱ្យចូលរៀន និងការលើកទឹកចិត្តប្រកបដោយគុណភាព ចំពោះគ្រូបង្រៀននៅតាមសាលារៀនសាធារណៈ ដោយពិនិត្យលើផលប៉ះពាល់របស់គ្រូបង្រៀនដែលបានជ្រើសរើស និងចេញបម្រើការងារថ្មី តាមរយៈការត្រួតពិនិត្យគុណភាពលើការអនុវត្តការងារនៅកម្រិតវិទ្យាល័យ។ លទ្ធផលបង្ហាញពីឥទ្ធិពលវិជ្ជមានរបស់គ្រូបង្រៀនបទបញ្ញត្តិថ្មី និងប្រសិទ្ធភាពចំពោះការបំពេញការងារនៅក្នុង

សាលារៀន។ ផ្អែកតាម (Reimers, F. M., 2020a) កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនទ្រង់ទ្រាយធំ មានគោលបំណងផ្តល់ផលប្រយោជន៍ចំណេះដឹង បំណិន ដល់សិស្សដើម្បីចេះរស់នៅក្នុងពិភពលោកដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ លើសពីនេះទៅទៀត កម្មវិធីបណ្តុះបណ្តាលថ្មីជួយគ្រូបង្រៀនបានស្វែងយល់ពីកម្លាំងចលករសំខាន់របស់សិស្ស មានលទ្ធភាពឱ្យសិស្សស្វែងរកទេពកោសល្យរបស់ខ្លួនជាពិសេស ជំនាញការយល់ដឹង និងសង្គម-អារម្មណ៍។ ការវិភាគប្រៀបធៀបត្រូវបានប្រើដើម្បីជំរុញទ្រឹស្តីដ៏រឹងមាំនៃតួនាទីរបស់ការអភិវឌ្ឍវិជ្ជាជីវៈក្នុងការកែលម្អការបង្រៀន។ មួយវិញទៀត គ្រូចេះរៀបចំការបង្រៀនដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ មានការប្រៀបធៀបអំពីបទពិសោធនៃការសិក្សារបស់សិស្ស ដើម្បីជួយឱ្យសិស្សរៀនសូត្រកាន់តែស៊ីជម្រៅ និងការអភិវឌ្ឍន៍ជំនាញការយល់ដឹង និងសង្គម-អារម្មណ៍។ អាស្រ័យហេតុនេះ ផលប៉ះពាល់វិជ្ជមានពីការអភិវឌ្ឍន៍គ្រូបង្រៀននៅក្នុងកំណែទម្រង់កម្រិតប្រព័ន្ធប្រកបដោយមហិច្ឆិតាបានឱ្យសិស្សមានជំនាញទូលំទូលាយដើម្បីច្នៃប្រឌិតអនាគតកាន់តែប្រសើរឡើង និងបានជួយកាត់បន្ថយបញ្ហាប្រឈមដែលកើតមានក្នុងអង្គភាព។ នៅកម្ពុជា ក្នុងឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីណែនាំ ដោយតម្រូវឱ្យបេក្ខជនដែលមានបំណងដាក់ពាក្យចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀន ត្រូវជ្រើសរើសប៉ុស្តិ៍បម្រើការងារជាមុន ដោយបេក្ខជនត្រូវជ្រើសរើសសាលារៀន ឬអង្គភាពខ្វះគ្រូដែលមានក្នុងបញ្ជីរាយនាមសាលារៀន ឬអង្គភាពសម្រាប់ការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ និងមានកិច្ចសន្យាបម្រើការងារយ៉ាងតិចប្រាំឆ្នាំសម្រាប់តំបន់វាលរាប និងយ៉ាងតិចបីឆ្នាំសម្រាប់តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល។ ទន្ទឹមនឹងនេះ នាយកសាលារៀនត្រូវសម្ភាសន៍បេក្ខជន និងផ្តល់ចំណារយល់ព្រមទទួលនៅលើពាក្យសុំចុះឈ្មោះប្រឡង ដើម្បីធានាថានៅពេលបញ្ចប់ការបណ្តុះបណ្តាល គ្រូបង្រៀនចេញថ្មីទាំងអស់ត្រូវទៅបម្រើការងារនៅតាមសាលារៀន ឬអង្គភាពគោលដៅដែលសាមីខ្លួនបានជ្រើសរើស (អយក, 2019a)។ ជាមួយគ្នានេះ ក្រសួងអប់រំ នៅបន្តការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាស្ថានជាតិអប់រំតាមកម្មវិធីបណ្តុះបណ្តាល (បរិញ្ញាបត្រ+១) និងកំពុងពិនិត្យឡើងវិញនៅកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតផងដែរ (អយក, 2019b)។ នៅឆ្នាំ ២០២១ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម

(បរិញ្ញាបត្រ+១) បណ្ដុះបណ្ដាលរយៈពេលមួយឆ្នាំ និង(បរិញ្ញាបត្រ+២) បណ្ដុះបណ្ដាលរយៈពេលពីរឆ្នាំ ដោយផ្ដោតលើមុខវិជ្ជាវិទ្យាសាស្ត្រ រួមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា (អយក, 2021b)។ នៅឆ្នាំ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម (បរិញ្ញាបត្រ+២) លើគ្រប់មុខវិជ្ជាឯកទេសទាំងអស់ ដោយធ្វើការបណ្ដុះបណ្ដាលរយៈពេលពីរឆ្នាំតាមក្របខ័ណ្ឌកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+២) របស់វិទ្យាស្ថានជាតិអប់រំ (អយក, 2023b)។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលដៅសំខាន់ៗពីរគឺ៖

១.សិក្សាឈ្វេងយល់ពីការយល់ឃើញរបស់នាយកសាលាទៅលើកំណែទម្រង់ការជ្រើសរើស និងបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។

២.សិក្សាពីផលជះនៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិដល់សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីបកស្រាយឱ្យកាន់តែច្បាស់នូវបញ្ហានៃការស្រាវជ្រាវ និងឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ មានសំណួរស្រាវជ្រាវចំនួនពីរត្រូវបានកំណត់ដូចខាងក្រោម៖

១.តើនាយកសាលាមានការយល់ឃើញយ៉ាងដូចម្ដេច ទៅលើកំណែទម្រង់ការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា?

២.តើកំណែទម្រង់ការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិ បានជួយឱ្យប្រសើរឡើង លើការដោះស្រាយបញ្ហាប្រឈមនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិដូចម្ដេចខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះ ជាចម្លើយឆ្លើយតបដ៏ចាំបាច់ជាមួយនឹងកំណែទម្រង់ដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្ត ដើម្បីបានបង្ហាញអំពីឧត្តមានុវត្តរបស់កំណែទម្រង់ចំពោះការចូលរួមចំណែកបង្កើនគុណភាពគ្រូបង្រៀន ប្រសិទ្ធភាពដល់ដំណើរការបង្រៀន និងរៀន ធានាបាននូវការ

បំពេញភារកិច្ចរបស់គ្រូបង្រៀនចេញថ្មីប្រកបដោយភាពស័ក្តសិទ្ធិ និងនិរន្តភាពនៃការបំពេញការងារ។ លើសពីនេះទៅទៀត បានសម្រួលដល់ការងារគ្រប់គ្រងបុគ្គលិកកាន់តែមានភាពប្រសើរឡើង ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមនានាដែលបានកើតឡើងនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានវិសាលភាពឆ្លុះបញ្ចាំងពី "**ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ករណីសិក្សា ខេត្តតាកែវ**"។ ដើម្បីអាចបកស្រាយលទ្ធផលការសិក្សាស្រាវជ្រាវនេះ ត្រូវធ្វើឡើងក្នុងទម្រង់ជាបរិមាណវិស័យ ដោយបានជ្រើសរើសនាយក នាយិកា នាយករង នាយិការងសាលារៀន ចំនួន ៤៣នាក់ ពីវិទ្យាល័យចំនួន ២១ ស្ថិតក្នុងស្រុកបាទី ស្រុកព្រៃកប្បាស ស្រុកសំរោង ស្រុកត្រាំកក់ និងស្រុកទ្រាំង ក្នុងខេត្តតាកែវ ដែលគ្រឹះស្ថានសិក្សាទាំងនោះស្ថិតក្នុង តំបន់ធម្មតា តំបន់ជួបការលំបាក និងតំបន់ទីប្រជុំជន។ រយៈពេលនៃការសិក្សាចាប់ពីថ្ងៃទី០៧ ខែឧសភា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣។

## ១.៧ ក្របខ័ណ្ឌគោលគំនិតនៃការស្រាវជ្រាវ

ក្របខ័ណ្ឌគោលគំនិតនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ" គឺដើម្បីសិក្សាឱ្យស៊ីជម្រៅទៅលើដំណើរការនៃការជ្រើសរើសគ្រូបង្រៀន ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងលទ្ធផលនៃកំណែទម្រង់សំដៅឆ្ពោះទៅរកគុណភាព និងផលជះរបស់គ្រូបង្រៀន។




រូបភាព 1 ក្របខ័ណ្ឌគោលគំនិតនៃការសិក្សាស្រាវជ្រាវ

## ១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដំណើរការនៃការស្រាវជ្រាវត្រូវបានបែងចែកជាប្រាំជំពូកធំៗគឺ៖

ជំពូក១ សេចក្តីផ្តើម៖ បង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ក្របខ័ណ្ឌគោលគំនិតនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូក២ រំលឹកទ្រឹស្តី៖ អ្នកស្រាវជ្រាវលើកយកទ្រឹស្តីទាំងឡាយណាដែលពាក់ព័ន្ធនឹងចំណោទបញ្ហានៃការស្រាវជ្រាវដោយលើកយកសេចក្តីពន្យល់លម្អិតបន្ថែមដើម្បីឱ្យទ្រឹស្តីទាំងនោះកាន់តែច្បាស់លាស់ និងស៊ីជម្រៅដោយមានឯកសារយោងត្រឹមត្រូវ។

ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ៖ បង្ហាញពីវិធីសាស្ត្រនៃការស្រាវជ្រាវ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ ក្រមសីលធម៌នៃការស្រាវជ្រាវ និងវិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ។

ជំពូក៤ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា៖ លើកពីលទ្ធផលស្រាវជ្រាវជាក់ស្តែងស្របតាមសំណួរស្រាវជ្រាវ គោលបំណង និងប្រធានបទស្រាវជ្រាវ ព្រមទាំងធ្វើការពិភាក្សាលើលទ្ធផលស្រាវជ្រាវដែលបានរកឃើញ ធៀបទៅនឹងសំណួរស្រាវជ្រាវ និងទ្រឹស្តីពាក់ព័ន្ធ។

ជំពូក៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖ សង្ខេបគំនិត និងលើកឡើងពីសេចក្តីសន្និដ្ឋាន និងសំណូមពរ។ ធ្វើការវែកញែក បង្ហាញអំពីចំណុចល្អ ចំណុចខ្វះខាតនានាដែលត្រូវកែលម្អ និងគំនិតជាទុនសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយសិក្សាស្វែងយល់បន្ថែម។

# ជំពូក ២

# រំលឹកទ្រឹស្តី

# ជំពូក ២

# រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

សព្វថ្ងៃនេះ យើងត្រូវតែមានគ្រូបង្រៀនដែលមានសមត្ថភាពទាំងចំណេះដឹងមូលដ្ឋាន ចំណេះដឹងវិជ្ជាជីវៈ វិធីសាស្ត្របង្រៀន ចិត្តវិទ្យា ចំណេះដឹងបច្ចេកទេសថ្មីៗក៏ដូចជាលើផ្នែកបច្ចេកវិទ្យាផងដែរ ដើម្បីជួយឱ្យដំណើរការរៀនសូត្ររបស់សិស្សប្រកបដោយប្រសិទ្ធភាព និងស្របតាមតម្រូវការសិក្សារបស់សិស្ស (Reimers, F. M., 2020b) ។ គ្រូបង្រៀនត្រូវតែស្វែងរកចំណេះដឹងថ្មីៗជានិច្ចក្នុងវិស័យផ្សេងៗ រួមទាំងព័ត៌មាន ជំនាញ និងរបកគំហើញ។ គ្រូបង្រៀននាពេលបច្ចុប្បន្ននេះ ត្រូវបានគេរំពឹងថានឹងមានចំណេះដឹង ជំនាញកម្រិតខ្ពស់ ស្តង់ដាសិក្សា សីលធម៌ខ្ពស់ និងមានស្មេរភាពក្នុងការបំពេញភារកិច្ច ដើម្បីរួមចំណែកលើកកម្ពស់វឌ្ឍនភាពសិក្សា ក៏ដូចជាការអភិវឌ្ឍន៍សង្គម-អារម្មណ៍ សីលធម៌ និងដើម្បីការពារសុខភាព និងសុខុមាលភាពរបស់សិស្ស។ ការកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន គឺជាកង្វល់ទូទាំងពិភពលោក ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍព្រោះថាគ្មានការអប់រំណាមួយអាចកើនឡើងលើសពីគុណភាពគ្រូបង្រៀនរបស់ខ្លួន (Adeosun, O., 2014)។ ទំនាក់ទំនងវិជ្ជាជីវៈនៃការបង្រៀនជាមួយនឹងសមធម៌អប់រំ គុណភាព និងប្រសិទ្ធភាព សង្កត់ធ្ងន់លើតួនាទីសំខាន់របស់គុណភាពគ្រូបង្រៀនក្នុងការសម្រេចបានលទ្ធផលសិក្សារបស់សិស្ស និងការអភិវឌ្ឍន៍ការអប់រំ។ ផ្អែកតាមរយៈស្ថិតិ និងការស្ទង់មតិបានគូសបញ្ជាក់ពីការពិតដែលបង្ហាញថា បញ្ហាគ្រូបង្រៀន គឺជាបញ្ហាចម្បង ជាពិសេស ការទទួលបានគ្រូបង្រៀនសម្រាប់បម្រើការងារនៅតំបន់ជួបការលំបាក និងដាច់ស្រយាល ដែលវាបានជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ កត្តាទាំងនេះចង្អុលទៅតម្រូវការដើម្បីដោះស្រាយលើការជ្រើសរើសគ្រូបង្រៀន ការបណ្តុះបណ្តាល ការរៀបចំផែនការបុគ្គលិក ការដាក់ពង្រាយ និងប្រាក់បៀវត្ស (Benveniste, L., Marshall, J., & Araujo, M. C., 2008b)។ នៅកម្ពុជា របាយគ្រូបង្រៀននៅតាមតំបន់ទីប្រជុំជន តំបន់ធម្មតា និងតំបន់ជួបការលំបាកនៅមានភាពខុសគ្នាខ្លាំងដែលជាបញ្ហាប្រឈមក្នុងការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន ហេតុនេះបានជាក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រកំណែ

ទម្រង់ដំណាក់កាលទី២ តាមរយៈការធ្វើកំណែទម្រង់ទី២ គឺការពង្រាយគ្រូបង្រៀន និងកំណែទម្រង់ទី៤ គឺការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ដោយបានកែលម្អលក្ខខណ្ឌនៃការជ្រើសរើសបេក្ខជនចូលក្របខ័ណ្ឌគ្រូបង្រៀន ក្នុងនោះបានរៀបចំគោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ តម្រូវឱ្យសិស្ស និស្សិតដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀន ត្រូវជ្រើសរើសសាលារៀនដែលខ្វះគ្រូបង្រៀនដែលសាមីខ្លួនអាចទៅបម្រើការងារបាន និងមានកិច្ចសន្យាបម្រើការងារយ៉ាងតិច៥ឆ្នាំ ចំពោះតំបន់ធម្មតា និងយ៉ាងតិច៣ឆ្នាំ ចំពោះតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល ដោយមានចំណារឯកភាពព្រមទទួលពីនាយក នាយិកាសាលារៀននោះ និងត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស។ ខណៈដែលក្រសួងអប់រំ យុវជន និងកីឡាកំពុងបន្តការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាស្ថានជាតិអប់រំតាមកម្មវិធី (បរិញ្ញាបត្រ+១) ក៏មានការពិនិត្យឡើងវិញនូវកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតស្របពេលជាមួយគ្នានោះផងដែរ (អយក, 2019c)។ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ក្នុងសសរស្តម្ភទី១ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ក្នុងកំណែទម្រង់ដំណាក់កាលទី៣ គឺកំណែទម្រង់ការកសាងប្រព័ន្ធ និងអភិវឌ្ឍធនធានមនុស្ស ឆ្នាំ២០១៩ ដល់២០២២ (អយក, 2023)។

## ២.២ ពាក្យគន្លឹះ

ប្រធានបទនៃការសិក្សាស្រាវជ្រាវនេះមានពាក្យគន្លឹះសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

**ទស្សនៈ** ៖ មកពីពាក្យ ទស្សន ដែលមានន័យថា ដំណើរយល់ឃើញ បញ្ញាសាមញ្ញ (សម្តេចព្រះសង្ឃរាជ ជួន ណាត)។

**នាយក** ៖ អ្នកដឹកនាំ អ្នកត្រួតត្រា (សម្តេចព្រះសង្ឃរាជ ជួន ណាត)។

**កំណែទម្រង់**៖ សំដៅលើការកែលម្អ ឬកែប្រែនូវអ្វីដែលខុស ពុករលួយ មិនពេញចិត្ត ដើម្បីធ្វើឱ្យមានភាពរីកចម្រើនក្នុងវិស័យដែលពាក់ព័ន្ធ(Wikipedia, n.d.)។ កំណែទម្រង់ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងកាត់បន្ថយការចំណាយថវិកា ជារឿយៗនាំទៅរកការបង្រួបបង្រួមភ្នាក់ងារ ការផ្តោតអារម្មណ៍លើហានិភ័យ និងការបង្កើនប្រសិទ្ធភាពធនធាន ខណៈដែលអ្នកដែលផ្តោតលើការកាត់

បន្ថយបន្ទុកទាមទារតម្លាភាព ច្បាប់ចូលរួម ការធ្វើផែនការ និងការកែលម្អព័ត៌មាន (Blanc, F., 2012)។

**ការជ្រើសរើស៖** គឺជាដំណើរការនៃការទាក់ទាញបុគ្គល ឬធនធានមនុស្សដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខណៈវិនិច្ឆ័យដើម្បីចូលរួមចំណែកបំពេញការងារ ឬតួនាទីតាមតម្រូវការរបស់អង្គភាព (Bach, S., 2005)។ មួយវិញទៀត គឺជាដំណើរការដែលអង្គភាពជ្រើសរើស និងជួលបុគ្គលដែលមានទាំងសមត្ថភាព ជំនាញ និងចំណេះដឹងពេញលេញ ទូលំទូលាយសម្រាប់ការងារ (Bratton, J., 2007)។ តាមទស្សនៈរបស់ (Adu-Darkoh, M. , 2014) ការជ្រើសរើស គឺជាដំណើរការនៃការទទួលបានអ្នកដាក់ពាក្យជាមួយបទពិសោធ ចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងអាកប្បកិរិយាដែលស្របតាមតម្រូវការសម្រាប់ការងារ។

**ការបណ្តុះបណ្តាល៖** គឺជាសកម្មភាពរបស់អង្គភាពនីមួយៗ ដែលត្រូវបានគ្រោងទុកជាប្រព័ន្ធដែលលទ្ធផលនាំមកនូវភាពរីកចម្រើននៃកម្រិតជំនាញ ចំណេះដឹងកាន់តែប្រសើរឡើង និងសមត្ថភាពដែលចាំបាច់ដើម្បីធានាបាននូវការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ គឺជាដំណើរការនៃការសិក្សាដែលរួមបញ្ចូលការទទួលបានចំណេះដឹង ការធ្វើឱ្យប្រសើរឡើងនូវចំណេះជំនាញ ការយល់ដឹងអំពីក្បួនច្បាប់ ឬការផ្លាស់ប្តូរអាកប្បកិរិយាដើម្បីកែលម្អការបំពេញភារកិច្ចរបស់បុគ្គលិក (Hanaysha, J., 2016)។

## ២.៣ ទ្រឹស្តីពាក់ព័ន្ធ

សិស្សឆ្នើម គឺជាសមិទ្ធផលរបស់គ្រូបង្រៀនដែលពូកែ។ ការសម្រេចបានលទ្ធផលជោគជ័យរបស់សិស្ស គឺមានឥទ្ធិពលមកពីកត្តាជាច្រើន ដែលក្នុងនោះកត្តាដែលមានឥទ្ធិពលសំខាន់ជាងគេ គឺគ្រូបង្រៀនដែលមានការបំផុសគំនិត និងបានគិតគូរគ្រប់ជ្រុងជ្រោយ ហេតុនេះ ពិតជាមានសារៈសំខាន់ក្នុងការដែលត្រូវពិនិត្យឱ្យបានហ្មត់ចត់ពីរបៀបបណ្តុះបណ្តាល ការផ្គត់ផ្គង់ និងការគាំទ្រទាំងគ្រូថ្មី និងគ្រូដែលមានបទពិសោធ។ ការអភិវឌ្ឍន៍វិជ្ជាជីវៈ គឺជាដំណើរការបន្តដែលជំរុញភាពរីកចម្រើនរបស់គ្រូបង្រៀន និងកែលម្អការអនុវត្តនៅក្នុងថ្នាក់រៀន ដែលពាក់ព័ន្ធនឹងការរៀនសូត្របន្តពីគ្នាទៅវិញទៅមក បន្តធ្វើបច្ចុប្បន្នភាពលើការស្រាវជ្រាវ ឧបករណ៍ និងបច្ចេកវិទ្យាថ្មីៗ។ គ្រូបង្រៀនត្រូវតែយល់អំពីវប្បធម៌របស់សិស្ស ហើយធ្វើការ

សហការគ្នាដើម្បីបង្កើនគុណភាពនៃការបង្រៀន។ នៅសតវត្សទី២១ គ្រូបង្រៀនត្រូវតែគិតគូរពីតម្រូវការរបស់សិស្ស ហើយរៀបចំសិស្សឱ្យរួចជាស្រេចសម្រាប់ប្រឈមមុខនឹងបញ្ហាប្រឈមនាពេលអនាគត ដោយសារ តួនាទីរបស់គ្រូបង្រៀន គឺជាមគ្គុទេសក៍ និងជាអ្នកសម្របសម្រួល មិនមែនគ្រាន់តែជាអ្នកផ្តល់ចំណេះដឹងនោះទេ។ ដើម្បីបង្កើតគុណភាពវិជ្ជាជីវៈឱ្យបានខ្ពស់ វាពិតជាមានសារៈសំខាន់ក្នុងការរៀបចំឱ្យមានកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនស្តង់ដា ដែលគួររួមបញ្ចូលបច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន (Jan, H., 2017)។ គ្រូបង្រៀនត្រូវបានជួលក្នុងវិស័យសាធារណៈតាមរយៈប្រព័ន្ធផ្អែកលើអាជីព ឬតាមមុខតំណែង។ ប្រព័ន្ធដែលមានមូលដ្ឋានផ្អែកលើអាជីព ទាមទារលក្ខណៈវិនិច្ឆ័យ និងវ័យរបស់បេក្ខជនដើម្បីចូលបម្រើការងារ ខណៈពេលដែលប្រព័ន្ធផ្អែកលើមុខតំណែងជ្រើសរើសបេក្ខជនល្អបំផុតតាមរយៈការជ្រើសរើស ឬការលើកកម្ពស់ផ្ទៃក្នុង។ ទោះបីជាមានភាពខុសប្លែកគ្នាក៏ដោយ ក៏ប្រទេសក្នុងតំបន់ប៉ាស៊ីហ្វិកផ្តល់អាទិភាពដល់គុណភាពគ្រូបង្រៀន និងភាពបត់បែនក្នុងការអប់រំ (Dy, S. S., 2017a)។

ជាទូទៅនៅប្រទេសជប៉ុន ការជ្រើសរើសគ្រូបង្រៀន និងការជួលត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាខេត្តនៃការអប់រំ ហើយជាធម្មតាគ្រូបង្រៀនត្រូវបានផ្លាស់ប្តូរទីកន្លែងបម្រើការងារក្នុងចំណោមសាលារៀននៅក្នុងខេត្តរៀងៗខ្លួន រៀងរាល់ប្រាំពីរ ឬប្រាំបីឆ្នាំម្តង (Dy, S. S., 2017b)។ នៅប្រទេសសិង្ហបុរី ការជ្រើសរើសគ្រូបង្រៀន គឺធ្វើឡើងដោយក្រសួងអប់រំ ដែលជ្រើសរើសគ្រូបង្រៀនថ្មី រួចបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំរបស់ខ្លួនមុនចូលបម្រើការងារជាគ្រូបង្រៀនពេញសិទ្ធិ។ ជាទូទៅ ការជ្រើសរើសគ្រូបង្រៀននៅប្រទេសសិង្ហបុរី គឺជ្រើសរើសចំនួនបេក្ខជនប្រមាណមួយភាគបី ប្រហែលសាមសិបភាគរយក្នុងចំណោមក្រុមនិស្សិតធ្វើមបានបញ្ចប់ការសិក្សាដែលមានលក្ខណៈសម្បត្តិប្រហាក់ប្រហែលគ្នាតាមរយៈជំហាននៃការជ្រើសរើសពីរ គឺទី១ ការសម្រាំងបេក្ខជនដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ បន្ទាប់មកធ្វើការសម្ភាសន៍បេក្ខជនជាមួយគណៈកម្មការរបស់វិទ្យាស្ថានជាតិអប់រំ និងក្រសួងអប់រំ ដើម្បីគណៈកម្មការអាចធ្វើការវាយតម្លៃអំពីសមត្ថភាព ជំនាញទំនាក់ទំនង គោលបំណង ឆន្ទៈ ការពេញចិត្ត និងចំណាប់អារម្មណ៍ក្នុងការបង្រៀន និងទី២ គឺដំណើរការនៃការចុះឈ្មោះចូលរៀន ដោយតម្រូវឱ្យបេក្ខជនដែលទទួលបានលទ្ធផលជោគជ័យពីការសម្ភាសន៍ត្រូវទៅបំពេញការងារជាអ្នកបង្រៀននៅសាលារៀន មុននឹងចុះឈ្មោះ

ចូលរៀនវគ្គបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានជាតិអប់រំសឹង្ហបុរី។ គោលបំណងនៃការបង្រៀន គឺដើម្បីវាយតម្លៃបន្ថែមនូវភាពស័ក្តិសមរបស់បេក្ខជនក្នុងការធ្វើជាគ្រូបង្រៀន ហើយថែមទាំងអាចឱ្យបេក្ខជនបានស្វែងយល់ពីភារកិច្ចដែលពាក់ព័ន្ធនឹងការបង្រៀន និងមានភាពល្អប្រសើរក្នុងវិជ្ជាជីវៈផងដែរ។ ចំពោះបេក្ខជនដែលមិនទទួលបានជោគជ័យលើការបង្រៀនសាកល្បងរបស់ពួកគេ ត្រូវបានស្នើឱ្យដកខ្លួនចេញពីកម្មវិធីអប់រំ ឬបង្រៀនបន្ថែមសម្រាប់ធ្វើការវាយតម្លៃនាពេលក្រោយ។ ក្រសួងអប់រំ មិនគិតថ្លៃសិក្សាសម្រាប់បេក្ខជនជ័យលាភី និងផ្តល់ប្រាក់បៀវត្សក៏ដូចជាឧបត្ថម្ភផ្សេងៗប្រចាំខែ។ ខណៈពេលដែលដំណើរការនៃការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន ការខិតខំប្រឹងប្រែងនាំឱ្យប្រព័ន្ធអប់រំរបស់សឹង្ហបុរីទទួលបានគ្រូល្អ លើកកម្ពស់ធនធានគ្រូបង្រៀន បង្កើនការរក្សាទុកតាមរយៈយុទ្ធសាស្ត្រដូចជា ការត្រួតពិនិត្យ ការអភិវឌ្ឍវិជ្ជាជីវៈ ការតាមដានការបំពេញការងារ ប្រព័ន្ធលើកទឹកចិត្តល្អ និងតុល្យភាពរចនាសម្ព័ន្ធការងារ (Lim, K. M., 2014)។ ចំណែកនៅប្រទេសបារាំង គ្រូបង្រៀនត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង ទាំងការជ្រើសរើសចេញពីមន្ត្រីរាជការដែលមានសញ្ញាបត្របង្រៀនរួចហើយ និងក្នុងចំណោមបេក្ខជនដែលមិនមែនជាមន្ត្រីរាជការ។ បេក្ខជនទាំងអស់ត្រូវមានសញ្ញាបត្របរិញ្ញាបត្រយ៉ាងទាបបំផុត។ បេក្ខជនដែលដាក់ពាក្យទៅបម្រើការងារទាំងនៅសាលារដ្ឋ និងសាលាឯកជនត្រូវតែឆ្លងកាត់ការប្រឡង ដោយជ្រើសរើសប៉ុស្តិ៍មុននឹងចុះឈ្មោះប្រឡង។ ការប្រកួតប្រជែងមានពីរដំណាក់កាលរួមមាន ដំណាក់កាលទី១ គឺការត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការប្រឡងសរសេរក្នុងខែមេសា ហើយបេក្ខជនដែលមានពិន្ទុប្រឡងសរសេរខ្ពស់ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមប្រឡងផ្ទាល់មាត់ដែលជាដំណាក់កាលទី២ធ្វើឡើងក្នុងខែមិថុនា ដែលត្រូវបានផ្តល់ដំណឹងពីរសប្តាហ៍មុនដំណើរការប្រឡង។ ការផ្តល់ចំណាត់ថ្នាក់ចុងក្រោយ គឺផ្អែកតាមមធ្យមភាគរបស់ពិន្ទុប្រឡងសរសេរ និងផ្ទាល់មាត់ ប៉ុន្តែបេក្ខជនដែលមានពិន្ទុប្រឡងផ្ទាល់មាត់បានច្រើនជាង មានអាទិភាពជាង។ បេក្ខជនដែលជាប់ចំណាត់ថ្នាក់ត្រូវបានជ្រើសរើសជាគ្រូបង្រៀន។ ប្រាក់បៀវត្សត្រូវបានផ្តល់ខុសគ្នាពីកម្រិតសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ ការជ្រើសរើសគ្រូបង្រៀននៅប្រទេសបារាំងបានធ្វើកំណែទម្រង់ជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កំណែទម្រង់កម្រិតគុណវុឌ្ឍិគ្រូបង្រៀនត្រូវបានធ្វើឡើង

ក្នុងឆ្នាំ២០១១ សម្រាប់បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ត្រូវបានជ្រើសរើសជាគ្រូបង្រៀន ចំណែកនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមក្នុងដំណើរការជ្រើសរើសគ្រូបង្រៀន ហើយនៅពេលនិស្សិតបញ្ចប់ការសិក្សានឹងបានក្លាយជាគ្រូបង្រៀន។ ខណៈពេលដែលមានការតម្រូវកម្រិតសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និស្សិតដែលបានបញ្ចប់បរិញ្ញាបត្រថ្មីៗ ដែលមានបំណងចង់ក្លាយជាគ្រូបង្រៀន មានជម្រើសពីរគឺ ទី១ ករណីមិនរៀនបន្តត្រូវធ្វើការងារតាមដែលរកបាន និងទី២ បន្តយកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ហើយចូលបម្រើការងារជាគ្រូបង្រៀន។ នៅក្នុងឆ្នាំ២០១៨ ការដំឡើងប្រាក់បៀវត្ស ១១% សម្រាប់គ្រូបង្រៀននៅតំបន់ជួបការលំបាកបានទាក់ទាញគ្រូបង្រៀន និងបានកាត់បន្ថយអត្រាខ្វះគ្រូបង្រៀននៅតំបន់ទាំងនោះ (Hillion, M., 2018)។ ចាប់ពីឆ្នាំ២០១៣ គ្រូត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ក្នុងឯកទេសជាក់លាក់ណាមួយ ឧទាហរណ៍ដូចជា ឯកទេសរូបវិទ្យា ហើយបន្ទាប់មកឆ្លងកាត់ការប្រឡងថ្នាក់ជាតិ និងឆ្លងកាត់ការបណ្តុះបណ្តាលដោយផ្តោតលើការស្រាវជ្រាវ និងវិជ្ជាជីវៈដើម្បីបង្កើនចំណេះដឹងឯកទេសកាន់តែស៊ីជម្រៅ និងមានកម្មសិក្សារយៈពេលមួយឆ្នាំ (Misra, P. K., 2013)។

## ២.៤ ស្ថានភាពខេត្តតាកែវ

### ២.៤.១ ភូមិសាស្ត្រទូទៅ

តាកែវ គឺជាខេត្តដ៏ចំណាស់មួយ ស្ថិតក្នុងភាគខាងត្បូងនៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងលិចជាប់នឹងខេត្តកំពត ខាងជើងឆៀងខាងលិចជាប់នឹងខេត្តកំពង់ស្ពឺ ខាងជើងឆៀងខាងកើតជាប់នឹងខេត្តកណ្តាល និងខាងត្បូងជាប់នឹងព្រំដែនអន្តរជាតិប្រទេសវៀតណាម ដែលមានក្រុងដូនកែវ ជាក្រុងតែមួយរបស់ខេត្ត និងស្រុកចំនួន៩ រួមមានដូចជា ស្រុកអង្គរបូរី ស្រុកបាទី ស្រុកបូរីជលសារ ស្រុកគិរីវង់ ស្រុកកោះអណ្តែត ស្រុកព្រៃកប្បាស ស្រុកសំរោង ស្រុកត្រាំកក់ និងស្រុកទ្រាំង និងជាខេត្តមួយដែលមានសម្រស់ធម្មជាតិ និងរមណីយដ្ឋានប្រវត្តិសាស្ត្រជាច្រើន។ តាកែវត្រូវបានគេទទួលស្គាល់ជាញឹកញាប់ថាជា «លំយោលនៃអរិយធម៌ខ្មែរ» ហើយមានទីតាំងមុនសម័យអង្គរសំខាន់ៗមួយចំនួន (Wikipedia, 2022)។

### ២.៤.២ ស្ថានភាពអប់រំ

ក្នុងឆ្នាំសិក្សា ២០២២-២០២៣ ខេត្តតាកែវមានបុគ្គលិកអប់រំសរុបចំនួន ៨៤៥១ នាក់ ស្រី ៣១៦៨នាក់ ក្នុងនោះក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមមានចំនួន ១៧៤៥ ស្រី ៤៩៥នាក់។ ខេត្តតាកែវមានវិទ្យាល័យសរុបចំនួន ៥៣ វិទ្យាល័យ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ និងនៅឆ្នាំសិក្សា ២០២៣-២០២៤នេះ កើនមួយវិទ្យាល័យបន្ថែមទៀត គឺវិទ្យាល័យ ព្រះនរោត្តមសីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ តុំ ក្នុងក្រុងដូនកែវ (ប្រភព មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ)។

តារាង 3 ស្ថិតិក្របខ័ណ្ឌបុគ្គលិកអប់រំខេត្តតាកែវ ឆ្នាំសិក្សា ២០២២-២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា**
**ខេត្តតាកែវ**

**ស្ថិតិក្របខណ្ឌបុគ្គលិកអប់រំ ឆ្នាំសិក្សា ២០២២-២០២៣**

| ក្របខណ្ឌ / អង្គភាព | ចំនួនអង្គភាព | អធិការអប់រំ | | អធិការបឋម | | ឧត្តម | | មូលដ្ឋាន | | កីឡា | | បឋម | | មត្តេយ្យ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| មន្ទីរ អយកខេត្ត | 1 | 17 | 1 | 2 | 1 | 45 | 17 | 41 | 11 | 12 | 1 | 30 | 11 | 4 | 3 | 151 | 45 |
| ការិ.អយក នៃរដ្ឋបាលក្រុង/ស្រុក | 10 | 1 | 0 | | | 17 | 1 | 42 | 9 | 5 | 0 | 38 | 10 | 3 | 0 | 106 | 20 |
| គ្រឹះស្ថានមធ្យមសិក្សា(វិទ្យាល័យ) | 53 | 7 | 1 | | | 1617 | 458 | 1277 | 446 | 196 | 32 | 4 | 2 | | | 3101 | 939 |
| គ្រឹះស្ថានមធ្យមសិក្សា(អនុវិទ្យាល័យ) | 66 | 1 | 0 | | | 57 | 14 | 851 | 297 | 102 | 21 | 3 | 2 | | | 1014 | 334 |
| គ្រឹះស្ថានបឋមសិក្សា | 381 | | | | | 9 | 5 | 672 | 252 | 4 | 2 | 3059 | 1272 | 295 | 281 | 4039 | 1812 |
| គ្រឹះស្ថានមត្តេយ្យសិក្សា(ដាច់) | 4 | | | | | | | 2 | 2 | | | 2 | 0 | 12 | 12 | 16 | 14 |
| បឋមសិក្សាខ្មែរ-ឥស្លាម | 11 | | | | | | | 20 | 3 | | | 4 | 1 | | | 24 | 4 |
| **សរុបរួម** | 526 | 26 | 2 | 2 | 1 | 1745 | 495 | 2905 | 1020 | 319 | 56 | 3140 | 1298 | 314 | 296 | 8451 | 3168 |

បើក្រឡេកទៅមើលចំនួនកូតានៃការជ្រើសរើសគ្រូបង្រៀនតាមឆ្នាំនីមួយ ជាពិសេសឆ្នាំ២០២៣ បញ្ជាក់ឱ្យឃើញថាខេត្តតាកែវជាខេត្តមួយដែលមានតម្រូវការគ្រូបង្រៀនច្រើន និងទទួលបានចំនួនកូតាជ្រើសរើសគ្រូបង្រៀន ជាពិសេសគ្រូបង្រៀនកម្រិតឧត្តមស្ថិតក្នុងលំដាប់ខ្ពស់ (ផ្អែកតាមតារាងបែងចែកក្របខ័ណ្ឌ ៣០០០កន្លែង សម្រាប់ការប្រឡងជ្រើសរើសក្នុងឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា)។

# តារាង 4 តារាងបែងចែកក្របខ័ណ្ឌ ៣០០០កន្លែង សម្រាប់ការប្រឡងជ្រើសរើសក្នុងឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**
**នាយកដ្ឋានបុគ្គលិក**

## តារាងបែងចែកក្របខ័ណ្ឌ ៣០០០កន្លែង សម្រាប់ការប្រឡងជ្រើសរើស ក្នុងឆ្នាំ២០២៣

| ល.រ | ក្របខណ្ឌ / អង្គភាព | ឧត្តមសិក្សា | កម្រិតឧត្តម(NIE) | | | | កម្រិតមូលដ្ឋាន | | | | | | | កម្រិតបឋម | | | | មន្ត្រីគ្រប់គ្រងរដ្ឋបាល(ក) | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | បរិ+1 | | បរិ+2 | សរុប | 12+2 | | 12+4 | អកេ.កីឡា | | | បឋម | | | មត្តេយ្យ | | |
| | | | | ឧទៅ | អបេ | ឧទៅ | | ឧទៅ | អជេ | ឧទៅ | សរុប | 12+2 | 12+4 | សរុប | 12+2 | 12+4 | 12+2 | | |
| 1 | រាជធានី | | 3 | 2 | 1 | | 6 | 4 | 2 | | 0 | | | 3 | 3 | | 2 | | 14 |
| 2 | ស្ទឹងត្រែង | | 17 | 14 | | 3 | 13 | 9 | | 4 | 3 | 1 | 2 | 36 | 32 | 4 | 3 | | 72 |
| 3 | ព្រះវិហារ | | 23 | 18 | 2 | 3 | 16 | 10 | 2 | 4 | 2 | 1 | 1 | 33 | 29 | 4 | 5 | | 79 |
| 4 | កោះកុង | | 25 | 20 | 2 | 3 | 18 | 11 | | 7 | 3 | 2 | 1 | 34 | 28 | 6 | 6 | | 86 |
| 5 | រតនគិរី | | 20 | 17 | | 3 | 15 | 10 | 2 | 3 | 2 | 2 | | 54 | 49 | 5 | 8 | | 99 |
| 6 | មណ្ឌលគិរី | | 21 | 15 | 3 | 3 | 10 | 4 | 2 | 4 | 1 | 1 | | 31 | 23 | 8 | 8 | | 71 |
| 7 | កណ្ដាល | | 31 | 26 | | 5 | 18 | 8 | | 10 | 3 | | 3 | 51 | 37 | 14 | 5 | | 108 |
| 8 | កំពង់ឆ្នាំង | | 32 | 23 | 2 | 7 | 17 | 8 | | 9 | 4 | 2 | 2 | 40 | 30 | 10 | 8 | | 101 |
| 9 | កំពង់ស្ពឺ | | 31 | 25 | | 6 | 15 | 8 | | 7 | 2 | 2 | 0 | 50 | 40 | 10 | 8 | | 106 |
| 10 | បាត់ដំបង | | 45 | 36 | 2 | 7 | 32 | 18 | 2 | 12 | 9 | 7 | 2 | 90 | 50 | 40 | 15 | | 191 |
| 11 | ពោធិ៍សាត់ | | 26 | 22 | | 4 | 20 | 11 | 2 | 7 | 7 | 4 | 3 | 45 | 33 | 12 | 10 | | 108 |
| 12 | ប.មានជ័យ | | 34 | 26 | 3 | 5 | 22 | 14 | 2 | 6 | 7 | 5 | 2 | 80 | 60 | 20 | 12 | | 155 |
| 13 | សៀមរាប | | 51 | 40 | 2 | 9 | 41 | 20 | | 21 | 13 | 10 | 3 | 111 | 80 | 31 | 18 | | 234 |
| 14 | ឧត្ត.ជ័យ | | 18 | 14 | | 4 | 18 | 11 | | 7 | 3 | 3 | | 50 | 39 | 11 | 5 | | 94 |
| 15 | ប៉ៃលិន | | 7 | 4 | | 3 | 5 | 0 | 2 | 3 | 2 | 2 | 0 | 17 | 12 | 5 | 4 | | 35 |
| 16 | កំពង់ចាម | | 29 | 21 | 1 | 7 | 16 | 6 | 2 | 8 | 5 | 4 | 1 | 90 | 73 | 17 | 12 | | 152 |
| 17 | ត្បូងឃ្មុំ | | 34 | 27 | | 7 | 21 | 10 | | 11 | 7 | 5 | 2 | 80 | 66 | 14 | 18 | | 160 |
| 18 | កំពង់ធំ | | 30 | 23 | | 7 | 17 | 8 | | 9 | 5 | 3 | 2 | 70 | 58 | 12 | 8 | | 130 |
| 19 | ក្រចេះ | | 27 | 20 | | 7 | 17 | 7 | 2 | 8 | 6 | 6 | | 61 | 51 | 10 | 8 | | 119 |
| 20 | ព្រៃវែង | | 50 | 39 | | 11 | 25 | 9 | | 16 | 10 | 10 | 0 | 95 | 75 | 20 | 10 | | 190 |
| 21 | ស្វាយរៀង | | 23 | 16 | 1 | 6 | 14 | 8 | | 6 | 4 | 3 | 1 | 64 | 52 | 12 | 7 | | 112 |
| 22 | តាកែវ | | 50 | 41 | | 9 | 28 | 9 | 1 | 18 | 0 | | | 70 | 59 | 11 | 8 | | 156 |
| 23 | កំពត | | 26 | 17 | 2 | 7 | 17 | 7 | 2 | 8 | 0 | | | 40 | 33 | 7 | 8 | | 91 |
| 24 | ព្រះសីហនុ | | 10 | 6 | 2 | 2 | 12 | 5 | | 7 | 2 | 2 | 0 | 37 | 33 | 4 | 3 | | 64 |
| 25 | កែប | | 2 | | | 2 | 2 | | | 2 | 0 | | | 3 | 2 | 1 | 1 | | 8 |
| សរុប(រាជធានី ខេត្ត) | | 0 | 665 | 512 | 23 | 130 | 435 | 215 | 23 | 197 | 100 | 75 | 25 | 1335 | 1047 | 288 | 200 | 0 | 2735 |
| 1 | គ្រឹះ.ឧត្តមសិក្សា | 80 | 0 | | | | 0 | | | | 0 | | | 0 | | | | | 80 |
| 2 | គ្រឹះ.បណ្ដុះ.គ្រូ | | 70 | 16 | 4 | 50 | 0 | | | | 0 | | | 0 | | | | | 70 |
| 3 | អនុវិ.អនុវត្តន៍ | | 0 | | | | 3 | 2 | | 1 | 0 | | | 0 | | | | | 3 |
| 4 | បឋម.អនុវត្តន៍ | | 0 | | | | 0 | | | | 0 | | | 12 | | 12 | | | 12 |
| 5 | រដ្ឋបាលកណ្ដាល | | 0 | | | | 0 | | | | 0 | | | 0 | | | | 100 | 100 |
| សរុប | | 80 | 70 | 16 | 4 | 50 | 3 | 2 | 0 | 1 | 0 | | | 12 | 0 | 12 | 0 | 100 | 265 |
| **សរុបរួម** | | 80 | 735 | 528 | 27 | 180 | 438 | 217 | 23 | 198 | 100 | 75 | 25 | 1347 | 1047 | 300 | 200 | 100 | 3000 |

សម្គាល់ ៖ - **អបេ** ៖ អប់រំបច្ចេកទេស (សិក្សានៅវិទ្យាស្ថានជាតិអប់រំ) ។ - **អជេ** ៖ អប់រំបំណិនជីវិត (សិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល) ។
- **ចំពោះវិទ្យាល័យ**អប់រំពិសេស ចំនួន៥ សរុប **៤១** កន្លែង ៖ **រាជធានី**(វិ.អពស ភ្នំពេញថ្មី ៖ ម=២,ប=៣,អនុ=៤,វិ=២) **កណ្ដាល**(វិ.អពស ក្រុងតាខ្មៅ ៖ ម=៣,ប=៤) **បាត់ដំបង**(វិ.អពស បាត់ដំបង៖អនុ=២,វិ=២) **សៀមរាប**(វិ.អពស សៀមរាប៖អនុ=២,វិ=២) និង**កំពង់ចាម** (វិ.អពស កំពង់ចាម ៖ ម=១,ប=៤,អនុ=២,វិ=៨)។

ថ្ងៃអង្គារ ១១ ០ ៦ ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣
**ប្រធាននាយកដ្ឋានបុគ្គលិក**

បណ្ឌិត ឆៀ-សុផន

បានឃើញ និងឯកភាព
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

## ២.៥ ស្ថានភាពនៃការជ្រើសរើសគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ

នៅក្នុងទសវត្សខាងមុខ ប្រទេសជាតិត្រូវការចំនួនគ្រូបង្រៀនជាច្រើន សម្រាប់ជំនួសគ្រូបង្រៀនដែលមានស្រាប់នាពេលបច្ចុប្បន្ន នៅពេលដែលពួកគាត់ត្រូវបានដាក់ឱ្យចូលនិវត្តន៍ ឬសឹករិចរិល។ ស្ថិតក្នុងដំណាក់កាលនៃការជ្រើសរើសគ្រូបង្រៀនដ៏ច្រើនសន្ធឹកសន្ធាប់នេះ នឹងមានផលប៉ះពាល់យ៉ាងខ្លាំងទាំងគុណភាព និងសមភាពអប់រំ ។ គ្រូបង្រៀនដែលមានសមត្ថភាពមិនត្រឹមតែជាកត្តាកំណត់ដ៏សំខាន់នៃសមិទ្ធផលសិក្សារបស់សិស្សប៉ុណ្ណោះទេ ថែមទាំងជាធនធានអប់រំដែលមិនទាន់មានការបែងចែកបានស្មើភាពគ្នានៅឡើយ (Darling-Hammond, L., & Berry, B., 1999)។ ការជ្រើសរើសមនុស្សបានត្រឹមត្រូវ ជំនាញត្រឹមត្រូវ ចំណេះដឹងត្រឹមត្រូវ លក្ខណៈសម្បត្តិត្រឹមត្រូវ ពេលវេលាត្រឹមត្រូវ សម្រាប់ការងារត្រឹមត្រូវ ពិតជាមានសារៈសំខាន់ណាស់សម្រាប់អង្គភាព ឬវិស័យនីមួយៗ។ ដំណើរការនៃការជ្រើសរើសបុគ្គលិក គឺជាធាតុចូលដ៏សំខាន់មួយដែលកំណត់ភាពជោគជ័យនៃអង្គភាពនោះ (Chungyalpa, W., & Karishma, T., 2016)។

នៅកម្ពុជា នាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីស្តារប្រព័ន្ធអប់រំឡើងវិញនៅកំឡុងពេលដែលប្រទេសជាតិជួបវិបត្តិខ្លាំង គ្រូបង្រៀន ឬអ្នកមានចំណេះដឹងដែលនៅរស់រានមានជីវិតត្រូវជ្រើសរើសមកបម្រើការងារជាគ្រូបង្រៀន និងជាអ្នកបណ្តុះបណ្តាលនៅតាមសាលារៀន ឬគ្រឹះស្ថានឧត្តមសិក្សាដោយរាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយរបស់ខ្លួនគឺ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកអត់ចេះ" ។ នៅខែកក្កដា ឆ្នាំ១៩៨០ សាលាគរុវិជ្ជាជាន់ខ្ពស់ Ecole Normale Supérieure ឬ Higher Normal College ត្រូវបានបង្កើតឡើងដែលមានសាស្ត្រាចារ្យជនជាតិវៀតណាមប្រហែល៤០ នាក់ មកពីក្រសួងអប់រំវៀតណាម មកបណ្តុះបណ្តាលនិស្សិតកម្ពុជាដែលមិនទាន់បានបញ្ចប់ការសិក្សានៅឧត្តមសិក្សាមុនឆ្នាំ១៩៧៥ ដោយកម្មវិធីសិក្សាមានរយៈពេលបីឆ្នាំដើម្បីក្លាយជាគ្រូបង្រៀននៅវិទ្យាល័យ គោលបំណងចូលរួមចំណែកកសាងប្រព័ន្ធអប់រំនៅកម្ពុជាឡើងវិញ។ នៅឆ្នាំ ១៩៩០ និស្សិតដែលបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សាប្រមាណ ២១៩៦នាក់ បានក្លាយជាគ្រូបង្រៀននៅវិទ្យាល័យ (Rany, S., Zain, A. N. M., & Jamil, H, 2012)។ បន្ទាប់ពីឆ្នាំ ១៩៩៥ ការផ្លាស់ប្តូរយ៉ាងចម្បងនៅក្នុងគោល

នយោបាយស្តីពីការអប់រំគ្រូបង្រៀនត្រូវបានប្រតិបត្តិ ដោយការជ្រើសរើសបេក្ខជនចូលក្របខ័ណ្ឌគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិត្រូវមានសញ្ញាបត្របរិញ្ញាបត្រឯកទេស ហើយធ្វើការប្រឡងចូលរៀននៅវិទ្យាស្ថានជាតិអប់រំ និងត្រូវបណ្តុះបណ្តាលរយៈពេលមួយឆ្នាំ (បរិញ្ញា+១)។ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល បេក្ខជនត្រូវជ្រើសរើសប៉ុស្តិ៍បម្រើការងារតាមរាជធានី-ខេត្ត ផ្អែកទៅលើចំណាត់ថ្នាក់ពិន្ទុ និងតាមប្រភេទមុខវិជ្ជាឯកទេស ដែលដំណើរការនេះធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំ។ បន្ទាប់ពីទទួលបានគរុនិស្សិតកម្រិតឧត្តមចេញថ្មីពីវិទ្យាស្ថានជាតិអប់រំ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ធ្វើការបែងចែកប៉ុស្តិ៍បម្រើការងារតាមអង្គភាពក្រោមឱវាទមន្ទីរ ឬគ្រឹះស្ថានសិក្សាដែលមានតម្រូវការគ្រូបង្រៀន ដោយគរុនិស្សិតត្រូវជ្រើសរើសប៉ុស្តិ៍សម្រាប់ចូលបម្រើការងារផ្អែកតាមតារាងបែងចែកប៉ុស្តិ៍របស់មន្ទីរអប់រំ យុវជន និងកីឡា និងយោងទៅតាមចំណាត់ថ្នាក់ប្រឡងបញ្ចប់របស់សាមីជនតាមមុខវិជ្ជាឯកទេសនីមួយៗ។ គួរបញ្ជាក់ផងដែរថា មុខវិជ្ជាឯកទេសនាពេលនោះ គឺមានតែឯកទេសទីមួយ តែប៉ុណ្ណោះ (Sot, V., Sok, S., & Dickinson, G., 2019a)។ យោង(អយក, 2000a) ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសំណើជ្រើសរើស និងបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ (បរិញ្ញា+១) សម្រាប់ឆ្នាំសិក្សា ២០០០-២០០១ ដោយមានការបន្ថែមមុខវិជ្ជាឯកទេសថ្មីមួយទៀត គឺមុខវិជ្ជាសេដ្ឋកិច្ច ចំពោះការជ្រើសរើសចូលក្របខ័ណ្ឌគ្រូបង្រៀន គឺជ្រើសចេញពីប្រភពសកលវិទ្យាល័យ និងមហាវិទ្យាល័យនានាដែលពាក់ព័ន្ធនឹងមុខវិជ្ជាឯកទេសដែលមានតម្រូវការ។ នៅឆ្នាំ២០១០ ការជ្រើសរើសគរុនិស្សិតកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី១៦ តម្រូវឱ្យបេក្ខជនជ្រើសរើសប៉ុស្តិ៍ រាជធានី-ខេត្ត តាមមុខវិជ្ជាឯកទេស មុននឹងធ្វើការប្រឡងជ្រើសរើស ដោយក្នុងនោះមានកំណត់ចំនួនប៉ុស្តិ៍សម្រាប់បេក្ខជនជាអតីតបុគ្គលិកចំនួន១០០ប៉ុស្តិ៍ ក្នុងចំណោមមុខវិជ្ជាឯកទេសទាំងអស់ ហើយការជ្រើសរើសសម្រាប់ឯកទេសនីមួយៗរួមបញ្ចូលឯកទេសទី១ និងឯកទេសទី២។ បន្ថែមពីនេះមានការកំណត់លក្ខខណ្ឌអាយុសម្រាប់និស្សិតមិនឱ្យលើសពី៣០ឆ្នាំ និងក្រោម៥៩ឆ្នាំសម្រាប់បុគ្គលិកអប់រំ គិតត្រឹមថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០។ វិញ្ញាសាប្រឡងចូលក្របខ័ណ្ឌរួមមាន វប្បធម៌ទូទៅ ឯកទេសទី១ ឯកទេសទី២ និងភាសាបរទេស (បារាំង ឬអង់គ្លេស) ផ្អែកតាមការជ្រើសរើសរបស់បេក្ខជន (អយក, 2010a)។ ចាប់ពីឆ្នាំ២០១១មក មិនមានការកំណត់ចំនួនប៉ុស្តិ៍សម្រាប់

អតីតបុគ្គលិកនោះទេ គឺមានសិទ្ធិប្រឡងប្រជែងស្មើភាពគ្នាជាមួយនិស្សិតគ្រប់មុខវិជ្ជាឯកទេស ប៉ុន្តែអតីតបុគ្គលិកមានសិទ្ធិជ្រើសរើសប៉ុស្តិ៍រាជធានី-ខេត្តណាដែលសាមីជនកំពុងបម្រើការងារប៉ុណ្ណោះ។ វិញ្ញាសាប្រឡងចូលក្របខ័ណ្ឌ រួមមាន វប្បធម៌ទូទៅ ឯកទេសទី១ និងឯកទេសទី២។ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល គរុនិស្សិតត្រូវទៅបម្រើការងារនៅតាមរាជធានី-ខេត្ត ដែលខ្លួនបានជ្រើសរើស ហើយត្រូវជ្រើសរើសប៉ុស្តិ៍សាលារៀនផ្អែកតាមចំណាត់ថ្នាក់របស់ខ្លួន លើមុខវិជ្ជាឯកទេសនីមួយៗ ដែលរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត (អយក, 2011)។ ចាប់ពីឆ្នាំ២០១៤មក ដោយឯកទេសនៃការបណ្តុះបណ្តាលមានតែមួយឯកទេស ហេតុនេះវិញ្ញាសាប្រឡងចូលក្របខ័ណ្ឌមានតែ វិញ្ញាសាវប្បធម៌ទូទៅ និងឯកទេស។ បេក្ខជនត្រូវជ្រើសរើសប៉ុស្តិ៍តាមរាជធានី-ខេត្តមុនការប្រឡងជ្រើសរើស។ ក្រោយពីបញ្ចប់ការបណ្តុះបណ្តាលគរុនិស្សិតត្រូវទៅបម្រើការងារនៅតាមរាជធានី-ខេត្តដែលខ្លួនបានជ្រើសរើស ហើយធ្វើការជ្រើសរើសប៉ុស្តិ៍សាលារៀនដែលរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ផ្អែកតាមចំណាត់ថ្នាក់នៃមុខវិជ្ជាឯកទេសនីមួយៗ (អយក, 2014a)។ ការអនុវត្តនីតិវិធីនៃការជ្រើសរើសប៉ុស្តិ៍យោងទៅតាមសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី ដោយក្នុងនោះ អតីតបុគ្គលិកត្រូវបានអនុញ្ញាតនូវគោលការណ៍បីរួមមាន (១) ចូលបម្រើការងារនៅអង្គភាពដើមវិញ (២) ឬ ស្ម័គ្រចិត្តទៅបម្រើការងារនៅសាលារៀនខ្វះគ្រូ (អនុវិទ្យាល័យ ឬវិទ្យាល័យ តាមការចាត់តាំងរបស់មន្ទីរអប់រំ) (៣)ឬ ស្ម័គ្រជ្រើសរើសប៉ុស្តិ៍ស្មើភាពគ្នាជាមួយគ្រូបង្រៀនចេញថ្មីជាអតីតនិស្សិត។ ម្យ៉ាងទៀតគ្រូបង្រៀនចេញថ្មីដែលមានសហព័ទ្ធជាមន្ត្រីរាជការ ត្រូវបានគណៈកម្មការសម្របសម្រួលឱ្យបានទៅបម្រើការងារនៅអង្គភាពជាមួយគ្នាក្នុងករណីខ្វះគ្រូបង្រៀន ហើយត្រូវមានឯកទេសស្របនឹងឯកទេសដែលខ្វះគ្រូ ឬអង្គភាពជិតគ្នាដែលមានតម្រូវការគ្រូ។ ចំពោះសហព័ទ្ធជាគ្រូបង្រៀនចេញថ្មីដូចគ្នា ត្រូវបានគណៈកម្មការផ្តល់អាទិភាពឱ្យភាគីម្នាក់ជាអ្នកជ្រើសរើសប៉ុស្តិ៍ បន្ទាប់មកក៏សម្របសម្រួលឱ្យភាគីម្នាក់ទៀតបានទៅបម្រើការងារនៅអង្គភាពជាមួយគ្នា ឬអង្គភាពដែលនៅជិតគ្នាដែលមានតម្រូវការគ្រូ។ ស្របជាមួយគ្នានេះដែរ គ្រូបង្រៀនចេញថ្មីទាំងពីរភេទមានសិទ្ធិប្តូរប៉ុស្តិ៍គ្នាបន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច (រយៈពេលបីថ្ងៃ) ដែលការប្តូរប៉ុស្តិ៍នេះសម្រាប់ក្របខ័ណ្ឌដូចគ្នា ប្រភេទតំបន់ដូច

គ្នា មុខវិជ្ជាឯកទេសដូចគ្នា និងជំនាន់ជាមួយគ្នាប៉ុណ្ណោះ (អយក, 2017) ។ ការជ្រើសរើសប៉ុស្តិ៍សម្រាប់ចូលបម្រើការងារ គឺផ្អែកលើគុណសម្បត្តិ លទ្ធផលរបស់គរុនិស្សិត ដោយផ្តល់អាទិភាពយោងតាមលំដាប់ពិន្ទុសរុប និងចំណាត់ថ្នាក់បញ្ចប់ការបណ្តុះបណ្តាល បន្ថែមពីនេះគ្រូបង្រៀនជាស្ត្រីមានអាទិភាពជាងគ្រូបង្រៀនជាបុរស។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត មានភារកិច្ចក្នុងការដាក់ពង្រាយគ្រូ និងធានាឱ្យបាននូវតម្លាភាព។ បេក្ខជនដែលមកពីក្រៅរាជធានី-ខេត្ត អាចមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀនរបស់ខេត្តដែលមានតម្រូវការជ្រើសរើស លើកលែងតែខេត្តដែលស្ថិតក្នុងតំបន់ដាច់ស្រយាលដូចជាខេត្តកោះកុង មណ្ឌលគិរី រតនគិរី និងប៉ៃលិន ដែលមានការហាមឃាត់បេក្ខជនមកពីបណ្តាខេត្តផ្សេងដើម្បីផ្តល់អាទិភាពឱ្យបេក្ខជនក្នុងមូលដ្ឋាន (Benveniste, L., Marshall, J., & Araujo, M. C., 2008c)។

ការជ្រើសរើសឱ្យចូលក្របខ័ណ្ឌគ្រូបង្រៀន គឺបន្តអនុវត្តតាមលក្ខខណ្ឌ និងនីតិវិធីនេះ រហូតមកដល់ឆ្នាំ២០១៩ ទើបមានការកែទម្រង់ ដោយបេក្ខជនទាំងអស់តម្រូវឱ្យធ្វើការជ្រើសរើសប៉ុស្តិ៍សាលារៀន ឬអង្គភាពបម្រើការងារជាមុន មុននឹងមានសិទ្ធិចូលរួមប្រឡង។ សំណុំលិខិតរបស់បេក្ខជនត្រូវមានចំណារយល់ព្រមពីគ្រឹះស្ថានសិក្សា ឬអង្គភាពដែលមានតម្រូវការគ្រូបង្រៀនដែលមានរាយនាមនៅក្នុងបញ្ជីតម្រូវការគ្រូបង្រៀនកម្រិតឧត្តម សម្រាប់ការប្រឡងជ្រើសរើសឆ្នាំ២០១៩។ មិនតែប៉ុណ្ណោះ មានការកំណត់លក្ខខណ្ឌអាយុសម្រាប់បេក្ខជនជានិស្សិតត្រឹម៣៥ឆ្នាំ សម្រាប់និស្សិតដែលមានសញ្ញាបត្របរិញ្ញាបត្រ ៤០ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ លើកលែងលក្ខខណ្ឌអាយុសម្រាប់សញ្ញាបត្របណ្ឌិត និងចំពោះបេក្ខជនជាមន្ត្រីរាជការ (អយក, 2019c)។ នៅឆ្នាំ២០២០ ការជ្រើសរើស ចូលក្របខ័ណ្ឌគ្រូបង្រៀនត្រូវបានផ្អាកដោយសារការរីករាលដាលនៃវិបត្តិកូវីត១៩ (អយក, 2020)។ នៅឆ្នាំ២០២១ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម ដោយបែងចែកជា "បរិញ្ញាបត្រ+១" និង"បរិញ្ញាបត្រ+២" ដោយបានរៀបចំនីតិវិធីជ្រើសរើសប៉ុស្តិ៍បម្រើការងារមុនការដាក់ពាក្យ និងការប្រឡងជ្រើសរើសតាមប្រព័ន្ធអនឡាញដោយសារការរីករាលដាលនៃជំងឺកូវីត១៩ (អយក, 2021c)។ នៅឆ្នាំ២០២៣ យោងតាម (អយក, 2023c) ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់

លក្ខខណ្ឌនៃការជ្រើសរើសចូលក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដោយជ្រើសរើសក្នុងចំណោមបេក្ខជនទាំងពីរភេទ (១) ជានិស្សិតពុំទាន់មានការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការ (២) ជាបុគ្គលិកអប់រំកំពុងបម្រើការងារនៅក្រសួងអប់រំ យុវជន និងកីឡា (៣) មានសញ្ជាតិខ្មែរ មានជីវប្រវត្តិច្បាស់លាស់ មានសុខភាពល្អ មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ និងត្រូវមានលក្ខខណ្ឌអាយុគិតដល់ថ្ងៃប្រឡងជ្រើសរើសដូចខាងក្រោម៖

- សម្រាប់បេក្ខជនជានិស្សិត៖ (១) បេក្ខជនដែលមានសញ្ញាបត្របណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ (២) បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូលត្រូវមានអាយុច្រើនបំផុត៤០ឆ្នាំ គិតត្រឹមថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣ (៣)បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ គិតត្រឹមថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣។
- សម្រាប់បេក្ខជនជាបុគ្គលិកអប់រំ មិនកំណត់លក្ខខណ្ឌអាយុឡើយ។

នីតិវិធីនៃការជ្រើសរើសត្រូវបានកំណត់ ដោយឱ្យបេក្ខជនធ្វើការជ្រើសរើសប៉ុស្តិ៍មុនការប្រឡងជ្រើសរើសទៅតាមតារាងកំណត់ប៉ុស្តិ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយប៉ុស្តិ៍ដែលត្រូវជ្រើសរើសមាននៅក្នុងបញ្ជីប៉ុស្តិ៍វិទ្យាល័យសម្រាប់ប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម (បរិញ្ញាបត្រ+២) សម្រាប់ឆ្នាំ២០២៣ និងត្រូវឆ្លងកាត់ការប្រឡងដោយវិញ្ញាសារួមមាន វិញ្ញាសាវប្បធម៌ទូទៅ និងវិញ្ញាសាឯកទេស។ ទន្ទឹមនឹងនេះក៏មានលក្ខខណ្ឌដោយឡែកមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

- បេក្ខជនជាបុគ្គលិកអប់រំ មានសិទ្ធិជ្រើសរើសវិទ្យាល័យណាមួយ ក្នុងរាជធានី ខេត្តដែលខ្លួនកំពុងបម្រើការងារ។ ដោយឡែក បុគ្គលិកដែលស្ថិតក្រោមឱវាទទីស្តីការក្រសួង មានសិទ្ធិជ្រើសរើសតែប៉ុស្តិ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថាន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាប៉ុណ្ណោះ។
- បេក្ខជនដែលជាបុគ្គលិកអប់រំ បន្ទាប់ពីប្រឡងជាប់ ត្រូវយកលិខិតផ្អាច់ការងារពីអង្គភាពរបស់ខ្លួនទៅតម្កល់ទុកនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីជានាឱ្យមាននិយ័តភាពនៃការសិក្សា ដោយរក្សាបៀវត្ស និងប្រាក់បំណាច់មុខងារនៅដដែល តែមិនទទួលបានប្រាក់អាហារូបករណ៍ពីរដ្ឋឡើយ។

- ក្រោយពេលប្រឡងជាប់ បេក្ខជនត្រូវដាក់ពាក្យចូលរៀនតាមកាលបរិច្ឆេទកំណត់របស់វិទ្យាស្ថានជាតិអប់រំ។ ក្នុងករណីអវត្តមានរយៈពេលមួយសប្តាហ៍នៃដើមបវេសនកាល វិទ្យាស្ថានជាតិអប់រំត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត។
- បេក្ខជនដែលក្លែងបន្លំសំណុំលិខិតនៃការប្រឡងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត។
- បេក្ខជនដែលបន្លំដាក់ពាក្យប្រឡងជ្រើសរើសមុខវិជ្ជាឯកទេសខុសពីសញ្ញាបត្ររបស់ខ្លួន ដែលមានចែងនៅក្នុងសេចក្តីជូនដំណឹង ពេលរកឃើញនឹងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត។
- បេក្ខជនដែលបន្លំសញ្ញាបត្រ នឹងត្រូវលុបឈ្មោះជាស្វ័យប្រវត្តិពេលរកឃើញ ព្រមទាំងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ ចំពោះសញ្ញាបត្រ ដែលមិនមានបិទរូបថត ត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួននិស្សិតច្បាប់ដើមមកផ្ទៀងផ្ទាត់។
- ចំពោះបេក្ខជនជាបុគ្គលិកដែលជ្រើសរើសប៉ុស្តិ៍ខុសពីសេចក្តីណែនាំ ត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិតជាស្វ័យប្រវត្តិនៅពេលរកឃើញ ព្រមទាំងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។
- បេក្ខជនជាបុគ្គលិកដែលបន្លំសំណុំលិខិតជានិស្សិត ត្រូវលុបឈ្មោះចេញពីបញ្ជី និងពីក្របខ័ណ្ឌ។
- បេក្ខជនមិនអាចផ្លាស់ប្តូរប៉ុស្តិ៍តាមសហព័ទ្ធមុនពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ។

ការដាក់ពាក្យប្រឡងជ្រើសរើស គឺធ្វើឡើយដោយផ្ទាល់នៅវិទ្យាស្ថានជាតិអប់រំ។ បេក្ខជនត្រូវយកសំណុំលិខិតសុំចុះឈ្មោះប្រឡង ដើម្បីបានចំណារឯកភាពពីនាយក នាយិកា ឬប្រធានអង្គភាពដែលមានក្នុងបញ្ជីតម្រូវការជ្រើសរើសគ្រូបង្រៀន។ លក្ខខណ្ឌ និងនីតិវិធីផ្សេងៗត្រូវបានអនុវត្តដូចមានចែងក្នុងសេចក្តីជូនដំណឹងលេខ ៥០ អយក.សជន ស្តីពី ការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ជំនាន់ទី២ ឆ្នាំសិក្សា ២០២៣-២០២៤ (អយក, 2023d)។

## ២.៦ ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ

ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា (បរិញ្ញា+១) ជំនាន់ទី១ ជាផ្លូវការ ចាប់ផ្តើមនៅឆ្នាំ១៩៩៥ បណ្តុះបណ្តាលរយៈពេលមួយឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំ ចំពោះមុខវិជ្ជាឯកទេសមានមួយឯកទេសប៉ុណ្ណោះ គឺឯកទេសទី១ (Sot, V., Sok, S., & Dickinson, G., 2019b)។ នៅឆ្នាំ

២០០០ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសំណើបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ដោយមានការបន្ថែមមុខវិជ្ជាឯកទេសថ្មីមួយទៀត គឺមុខវិជ្ជាសេដ្ឋកិច្ច សម្រាប់ឆ្នាំសិក្សា ២០០០-២០០១(អយក, 2000b)។ នៅឆ្នាំ២០១០ កម្មវិធីបណ្តុះបណ្តាល (បរិញ្ញា+១) ជំនាន់ទី១៦ មានពីរឯកទេស គឺឯកទេសទី១ និងឯកទេសទី២ ចំពោះកម្មវិធីសិក្សាមានរយៈពេលមួយឆ្នាំ (អយក, 2010b)។ ចាប់ពីឆ្នាំ២០១៤មក កម្មវិធីបណ្តុះបណ្តាល (បរិញ្ញា+១) ប្តូរមក មួយឯកទេសវិញ គឺមានតែឯកទេសទី១ប៉ុណ្ណោះ និងបណ្តុះបណ្តាលរយៈពេលមួយឆ្នាំ (អយក, 2014b)។ យោង (វជអ, 2020a) ក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) មានគោលបំណងផ្តល់ឱ្យគ្រូបង្រៀនកម្រិតឧត្តម នូវកញ្ចប់សមត្ថភាពចំនួនប្រាំដូចខាងក្រោម៖

ក. ចំណេះដឹងវិជ្ជាជីវៈ

- មានសមត្ថភាពពង្រឹង និងពង្រីកចំណេះដឹង វិធីសាស្ត្រដែលត្រូវបង្រៀនបានច្បាស់លាស់
- យល់ដឹងពីនិន្នាការអប់រំ គោលនយោបាយអប់រំ និងកម្មវិធីសិក្សា
- មានសមត្ថភាពប្រើប្រាស់វិធីសាស្ត្របង្រៀន និងគរុកោសល្យសតវត្សទី២១
- មានសមត្ថភាពបង្កើត និងប្រើប្រាស់សម្ភារឧបទេសសម្បូរបែបសម្រាប់បម្រើដល់ការរៀន និងបង្រៀនក្នុងសតវត្សទី២១
- មានសមត្ថភាពសរសេរកិច្ចតែងការបង្រៀនបានល្អ

ខ.បំណិនវិជ្ជាជីវៈ

- មានជំនាញគរុកោសល្យ ការគ្រប់គ្រងថ្នាក់ និងការវាយតម្លៃការសិក្សា
- ប្រើប្រាស់ទ្រឹស្តីនៃការរៀន និងបង្រៀនសមស្រប
- ប្រើប្រាស់វិធីសាស្ត្រក្នុងការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព
- គ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព
- បង្កើតបរិស្ថានសិក្សាដែលមានសុវត្ថិភាព ភាពកក់ក្តៅ និងមានភាពសហការគ្នា

គ.លក្ខណៈសម្បត្តិបុគ្គល

- មានបុគ្គលិកលក្ខណៈល្អ មានទេពកោសល្យ មានការទទួលខុសត្រូវ គោរពពេលវេលា និងជាបុគ្គលគំរូ

ឃ.ក្រមសីលធម៌វិជ្ជាជីវៈ

- មានក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ធ្វើជាគំរូល្អក្នុងគ្រួសារ សាលារៀន និងសហគមន៍
- មានឧត្តមគតិ និងមនសិការវិជ្ជាជីវៈខ្ពស់
- មានទំនាក់ទំនងជាមួយគណៈគ្រប់គ្រង គ្រូបង្រៀន សហការី មាតាបិតា អាណាព្យាបាលសិស្ស និងសហគមន៍។

ង.ការអភិវឌ្ឍវិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត

- មានការអភិវឌ្ឍន៍វិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត តាមរយៈការផ្លាស់ប្តូរបទពិសោធ និងការចូលរួមសកម្មភាពផ្សេងៗ
- មានភាពឧស្សាហ៍ព្យាយាមក្នុងការស្រាវជ្រាវ ការបង្ហាញ និងការចែករំលែកស្នាដៃ នៅក្នុងវេទិកាអប់រំថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ
- មានសមត្ថភាព ICT និងប្រើប្រាស់ឧបករណ៍ឌីជីថល សម្រាប់ជំនួយដល់ការរៀន ការបង្រៀន និងការស្រាវជ្រាវ។

កម្មវិធីបណ្តុះបណ្តាលមានចំនួន ៤៣ក្រេឌីត ដែល១ក្រេឌីត ស្មើ១៥ម៉ោង តម្រូវឱ្យអ្នកសិក្សាចំណាយពេលមួយឆ្នាំដើម្បីបញ្ចប់វគ្គបណ្តុះបណ្តាលនេះ ដោយផ្តោតលើបួនផ្នែកធំៗរួមមាន មុខវិជ្ជាសិក្សាអប់រំ (២០ក្រេឌីត=៤៦.៥%) មុខវិជ្ជាកម្មវិធីសិក្សា (១៥ក្រេឌីត=៣៤.៩%) មុខវិជ្ជាជម្រើសភាសាបរទេស (២ក្រេឌីត=៤.៦%) និងកម្មសិក្សាគរុកោសល្យ (៦ក្រេឌីត=១៤%) ជាមួយកញ្ចប់មុខវិជ្ជាពីរផ្សេងទៀតដោយមិនគិតក្រេឌីត រួមមានមុខវិជ្ជាតម្រូវ និងម៉ោងសិក្សាបន្ថែម។ កម្មសិក្សាគរុកោសល្យចែកជាបីដំណាក់កាលដូចជា កម្មសិក្សាសង្កេត ស្មើ១ក្រេឌីត កម្មសិក្សាពាក់កណ្តាលប្រតិបត្តិ ស្មើ១ក្រេឌីត និងកម្មសិក្សាប្រតិបត្តិ ស្មើ៤ក្រេឌីត។

កម្មសិក្សាសង្កេតផ្តល់ឱកាសឱ្យកម្មសិក្សាការីក្នុងការសង្កេតគ្រូណែនាំ និងឆ្លុះបញ្ចាំងពីតួនាទី

និងទំនួលខុសត្រូវរបស់គ្រូបង្រៀន សរុប៣០ម៉ោង។ កម្មសិក្សាពាក់កណ្ដាលប្រតិបត្តិផ្ដល់បទពិសោធជាក់ស្ដែងដល់កម្មសិក្សាការីក្នុងការធ្វើជាជំនួយការគ្រូណែនាំក្នុងការរៀបចំកិច្ចតែងការបង្រៀន ការរៀបចំសម្ភារឧបទេស ការគ្រប់គ្រងសិស្ស ជាជំនួយដល់ការបង្រៀនខ្លះៗ និងជួបជាមួយគ្រូត្រួតពិនិត្យសរុប៣០ម៉ោង។ ចំណែកកម្មសិក្សាប្រតិបត្តិ ផ្ដល់ឱកាសដល់កម្មសិក្សាការីក្នុងការយកចំណេះដឹងដែលទទួលបានពីការបណ្ដុះបណ្ដាលទៅអនុវត្តផ្ទាល់នៅក្នុងថ្នាក់រៀនតាមរយៈការសរសេរកិច្ចតែងការបង្រៀន និងការផ្ទេរចំណេះដឹង ដោយរាប់បញ្ចូលទាំងជំនាញគ្រប់គ្រងថ្នាក់ និងជំនាញវាយតម្លៃផង ដែលមានម៉ោងសរុប១២០ម៉ោង។ ការវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាលនេះរួមមានការវាយតម្លៃជាប្រចាំ និងការវាយតម្លៃបញ្ចប់វគ្គនៃកម្មវិធីបណ្ដុះបណ្ដាល ដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃដោយសំណួរផ្ទាល់មាត់ កិច្ចការផ្ទះ កិច្ចការក្រុម ការរៀបចំគម្រោងស្រាវជ្រាវ ការធ្វើបទបង្ហាញ ការតាំងពិព័រណ៍អប់រំ ការសួរ និងឆ្លើយសំណួរ ការធ្វើកម្មសិក្សាគរុកោសល្យ ការធ្វើថ្នាក់និទស្សន៍ និងការប្រឡងនានា (វជអ, 2020b)។ រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញា+១) នៅវិទ្យាស្ថានជាតិអប់រំដូចមានក្នុងតារាងខាងក្រោមៈ

តារាង 6 រចនាសម្ព័ន្ធនៃកម្មវិធីបណ្ដុះបណ្ដាល (បរិញ្ញាបត្រ+១)

| **ជំពូក** | **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** |
|---|---|---|---|
| មុខវិជ្ជាសិក្សាអប់រំ (Education Studies) (២០ក្រេឌីត=៤៦.៥%) | | | |
| | EDS01 | ចិត្តវិទ្យា | ៣ |
| | EDS02 | គរុកោសល្យ | ៣ |
| | EDS03 | ការស្រាវជ្រាវសកម្មភាពរៀន និងបង្រៀន (Action Research) | ៣ |
| | EDS04 | សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | ០ |
| | EDS05 | ការវាយតម្លៃលទ្ធផលសិក្សា | ៣ |
| | EDS06 | រដ្ឋបាលសិក្សា | ០ |

| | | | |
|---|---|---|---|
| | EDS07 | និន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ (Social Context of Education) | ៣ |
| | EDS08 | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀន និងបង្រៀន (Digital Portfolio) | ៣ |
| | EDS09 | សិល្បៈ និងវប្បធម៌ខ្មែរ | ២ |
| មុខវិជ្ជាជម្រើសភាសាបរទេស (២ក្រេឌីត=៤.៦%) | | | |
| | EC01 | ភាសាអង់គ្លេស ឬភាសាបារាំង | ២ |
| មុខវិជ្ជាកម្មវិធីសិក្សា (Curriculum Studies) ឯកទេស ៥ក្រេឌីត វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ ១០ក្រេឌីត ស្មើ ៣៤.៩% | | | |
| | CSM01 | ការបង្រៀនអក្សរសាស្ត្រខ្មែរ | ១៥ |
| | CSM02 | ការបង្រៀនភាសាបារាំង | ១៥ |
| | CSM03 | ការបង្រៀនភាសាអង់គ្លេស | ១៥ |
| | CSM04 | ការបង្រៀនសីលធម៌ពលរដ្ឋ | ១៥ |
| | CSM05 | ការបង្រៀនប្រវត្តិវិទ្យា | ១៥ |
| | CSM06 | ការបង្រៀនភូមិវិទ្យា | ១៥ |
| | CSM07 | ការបង្រៀនគីមីវិទ្យា | ១៥ |
| | CSM08 | ការបង្រៀនជីវវិទ្យា | ១៥ |
| | CSM09 | ការបង្រៀនផែនដីវិទ្យា | ១៥ |
| | CSM10 | ការបង្រៀនរូបវិទ្យា | ១៥ |
| | CSM11 | ការបង្រៀនគណិតវិទ្យា | ១៥ |
| | CSM12 | ការបង្រៀនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ | ១៥ |

| | | | |
|---|---|---|---|
| | CSM13 | ការបង្រៀនសេដ្ឋកិច្ច | ១៥ |
| | CSM14 | ការបង្រៀនអគ្គិសនី | ១៥ |
| | CSM15 | ការបង្រៀនអេឡិចត្រូនិក | ១៥ |
| | CSM16 | ការបង្រៀនក្សេត្រសាស្ត្រ | ១៥ |
| | CSM17 | ការបង្រៀនបសុវប្បកម្ម | ១៥ |
| | CSM18 | ការបង្រៀនមេកានិច | ១៥ |
| | CSM19 | ការបង្រៀនកែច្នៃអាហារ | ១៥ |
| | CSM20 | ការបង្រៀនអប់រំកាយ និងកីឡា | ១៥ |
| កម្មសិក្សាគរុកោសល្យ (៦ក្រេឌីត=១៤%) | | | |
| | TPM01 | កម្មសិក្សាសង្កេត (ការសង្កេតសាលារៀន និងថ្នាក់រៀន និងការឆ្លុះបញ្ចាំង) ១សប្តាហ៍ | ១ |
| | TPM02 | កម្មសិក្សាពាក់កណ្តាលប្រតិបត្តិ ១សប្តាហ៍ | ១ |
| | TPM03 | កម្មសិក្សាប្រតិបត្តិ ៦សប្តាហ៍ | ៤ |

តារាង 7 តារាងពិន្ទុនិទ្ទេសសរុប និងមូលវិចារ (បរិញ្ញាបត្រ+១)

| ពិន្ទុតាមកម្រិត | សមាសភាគភាគរយ | សញ្ញាពិន្ទុជាអក្សរ | ការបរិយាយ |
|---|---|---|---|
| ៤.00 | ៩0-១00 | A | ល្អប្រសើរ |
| ៣.៥0 | ៨0-៨៩ | B | ល្អណាស់ |
| ៣.00 | ៧0-៧៩ | C | ល្អ |
| ២.៥0 | ៦0-៦៩ | D | ល្អបង្គួរ |
| ២.00 | ៥0-៦៩ | E | មធ្យម |
| ១.00 | <៥0 | F | ខ្សោយ |

ក្នុងឆ្នាំ២០២១ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមត្រូវបានរៀបចំ និងកែទម្រង់ជាពីរកម្មវិធី រួមមាន (បរិញ្ញាបត្រ+១) បណ្តុះបណ្តាលរយៈពេលមួយឆ្នាំ និង(បរិញ្ញាបត្រ+២) បណ្តុះបណ្តាលរយៈពេលពីរឆ្នាំសម្រាប់មុខវិជ្ជាឯកទេសវិទ្យាសាស្ត្រដូចជាមុខវិជ្ជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា (អយក, 2021d)។ នៅឆ្នាំ២០២៣ កម្មវិធីបណ្តុះបណ្តាលត្រូវបានកែទម្រង់មកជា (បរិញ្ញាបត្រ+២) សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ ដោយការបណ្តុះបណ្តាលមានរយៈពេលពីរឆ្នាំ (អយក, 2023e)។ ក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) មានគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តមប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ អ្នកស្រាវជ្រាវអប់រំដែលមានការអភិវឌ្ឍន៍ ការអនុវត្ត និងការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ ការរំពឹងទុករបស់កម្មវិធីបណ្តុះបណ្តាល គរុនិស្សិតនឹងទទួលបានកញ្ចប់សមត្ថភាពជាច្រើនរួមមាន ចំណេះដឹងវិជ្ជាជីវៈ បំណិនវិជ្ជាជីវៈ លក្ខណៈសម្បត្តិបុគ្គល ក្រមសីលធម៌វិជ្ជាជីវៈ ការអភិវឌ្ឍន៍វិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត (វជអ, 2021b)៖

ក.ចំណេះដឹងវិជ្ជាជីវៈ

- យល់ដឹងពីបញ្ញត្តិនៃទស្សនវិជ្ជាអប់រំ និងសង្គមវិជ្ជាអប់រំក្នុងការរៀន និងបង្រៀន
- មានសមត្ថភាពពង្រឹង និងពង្រីកចំណេះដឹង និងវិធីសាស្ត្រដែលត្រូវបង្រៀនបានច្បាស់លាស់
- យល់ដឹងពីនិន្នាការអប់រំ គោលនយោបាយអប់រំ និងកម្មវិធីបណ្តុះបណ្តាល
- មានសមត្ថភាពប្រើប្រាស់វិធីសាស្ត្របង្រៀន និងគរុកោសល្យសតវត្សទី២១
- មានសមត្ថភាពបង្កើត និងប្រើប្រាស់សម្ភារឧបទេសសម្បូរបែប សម្រាប់បម្រើដល់ការរៀន និងបង្រៀនក្នុងសតវត្សទី២១
- មានសមត្ថភាពសរសេរកិច្ចតែងការបង្រៀនបានសមស្រប។

ខ.បំណិនវិជ្ជាជីវៈ

- អនុវត្តទ្រឹស្តីទស្សនវិជ្ជាអប់រំក្នុងការរៀន និងបង្រៀន
- មានជំនាញគរុកោសល្យ

- ប្រើប្រាស់ទ្រឹស្តីនៃការរៀន និងបង្រៀនសមស្រប
- ប្រើប្រាស់វិធីសាស្ត្រក្នុងការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព
- គ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព
- បង្កើតបរិស្ថានសិក្សាដែលមានសុវត្ថិភាព និងមានភាពសហការគ្នា
- មានជំនាញវាយតម្លៃការសិក្សារបស់សិស្ស។

គ.លក្ខណៈសម្បត្តិបុគ្គល

- មានបុគ្គលិកលក្ខណៈគំរូ (គោរពពេលវេលា មានទេពកោសល្យ មានការទទួលខុសត្រូវ)

ឃ.ក្រមសីលធម៌វិជ្ជាជីវៈ

- មានក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ធ្វើជាគំរូក្នុងគ្រួសារ សាលារៀន សហគមន៍ និងសង្គម
- មានឧត្តមគតិ និងមនសិការវិជ្ជាជីវៈខ្ពស់
- មានទំនាក់ទំនងល្អជាមួយគណៈគ្រប់គ្រង គ្រូបង្រៀន សហការី មាតាបិតា អ្នកអាណាព្យាបាល សិស្ស សហគមន៍ និងសង្គម។

ង.ការអភិវឌ្ឍន៍វិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត

- មានការអភិវឌ្ឍន៍វិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត តាមរយៈការផ្លាស់ប្តូរបទពិសោធ និងការចូលរួមសកម្មភាពផ្សេងៗ
- មានភាពឧស្សាហ៍ព្យាយាមក្នុងការស្រាវជ្រាវ ការបង្ហាញ និងការចែករំលែកស្នាដៃ នៅក្នុងវេទិកាអប់រំ ថ្នាក់ជាតិ និងថ្នាក់តំបន់
- មានសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) និងប្រើប្រាស់ឧបករណ៍ឌីជីថល សម្រាប់ជំនួយដល់ការរៀន ការបង្រៀន និងការស្រាវជ្រាវ។

គរុនិស្សិតកម្រិតឧត្តម (បរិញ្ញាបត្រ+២) នឹងក្លាយជាគ្រូបង្រៀនកម្រិតឧត្តម និងអ្នកស្រាវជ្រាវអប់រំប្រកបដោយគុណភាព ដើម្បីរួមសុខដុមរមនាទាំងអស់គ្នានាពេលអនាគត។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) នៅវិទ្យាស្ថានជាតិអប់រំ មានរយៈពេលបណ្តុះបណ្តាលពីរឆ្នាំ និង

មានចំនួនក្រេឌីតសរុប ៤៨ ក្រេឌីត ដូចមានក្នុងតារាងខាងក្រោម៖

តារាង 8 បណ្តុំមុខវិជ្ជា និងចំនួនក្រេឌីតតាមប្រភេទនៃការបណ្តុះបណ្តាល

| ល.រ | ក្រុមមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| ១ | មុខវិជ្ជារួមនៃឯកទេស | ១៧ |
| ២ | មុខវិជ្ជាស្នូលនៃឯកទេស | ១៥ |
| ៣ | មុខវិជ្ជាជម្រើស | ៦ |
| ៤ | កម្មសិក្សាប្រតិបត្តិគរុកោសល្យ | ៤ |
| ៥ | ការសរសេរនិក្ខេបបទ | ៦ |
| សរុប | | ៤៨ |

តារាង 9 រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល (បរិញ្ញាបត្រ+២) ឆ្នាំទី១ ឆមាសទី១

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|
| 101201 | ទស្សនវិជ្ជាអប់រំ | ២ (២-0-៤) | មុខវិជ្ជារួមនៃឯកទេស |
| 101202 | ចិត្តវិទ្យា | ៣ (៣-0-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101203 | គរុកោសល្យ | ៣ (៣-0-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101401 | សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ | S/U (២-0-៤) | មុខវិជ្ជាជម្រើស |
| 101204 | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀន និងបង្រៀន | ៣(២-២-៥) | មុខវិជ្ជារួមនៃឯកទេស |
| 101303 | វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ * | ៣ (២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |

តារាង 10 រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល (បរិញ្ញាបត្រ+២) ឆ្នាំទី១ ឆមាសទី២

| **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
|---|---|---|---|
| 101205 | ការវាយតម្លៃលទ្ធផលសិក្សា | ៣ (៣-០-៦) | មុខវិជ្ជារួម នៃឯកទេស |
| 101402 | ប្រឹក្សាគរុកោសល្យ | ២ (២-០-៤) | មុខវិជ្ជាជម្រើស |
| 101301 | ឯកទេសទី១ * | ៣ (២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101304 | វិធីសាស្ត្របង្រៀន និង ហ្វឹកហ្វឺនគរុកោសល្យ២ * * | ៣ (២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101305 | វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ៣ * * * | ៣(២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101901 | កម្មសិក្សា១ (សង្កេត និង ពាក់កណ្តាលប្រតិបត្តិ) | ១ (០-៣-២) | កម្មសិក្សាប្រតិបត្តិ គរុកោសល្យ |

តារាង 11 រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល (បរិញ្ញាបត្រ+២) ឆ្នាំទី២ ឆមាសទី១

| **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
|---|---|---|---|
| 101206 | ស្រាវជ្រាវអប់រំ | ៣ (៣-០-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101302 | ឯកទេសទី២ * * | ៣ (២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101902 | កម្មសិក្សា២ (ប្រតិបត្តិ) | ៣(០-៦-៣) | កម្មសិក្សាប្រតិបត្តិគរុកោសល្យ |
| 101501 | ការសរសេរនិក្ខេបបទ១ | ៣ | ការសរសេរនិក្ខេបបទ |

តារាង 12 រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាល (បរិញ្ញាបត្រ+២) ឆ្នាំទី២ ឆមាសទី២

| **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
|---|---|---|---|
| 101403 | ភាសាអង់គ្លេស ឬភាសាបារាំង | ២ (២-០-៤) | មុខវិជ្ជាជម្រើស |
| 101404 | និន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ | ២ (២-០-៤) | មុខវិជ្ជាជម្រើស |
| 101405 | សិល្បៈ និងវប្បធម៌ខ្មែរ | S/U (១-២-៣) | មុខវិជ្ជាជម្រើស |
| 101502 | ការសរសេរនិក្ខេបបទ១ | ៣ | ការសរសេរនិក្ខេបបទ |

តារាង 13 តារាងពិន្ទុនិទ្ទេសសរុប និងមូលវិចារ (បរិញ្ញាបត្រ+២)

| **ពិន្ទុតាមកម្រិត** | **សមាសភាគភាគរយ** | **សញ្ញាពិន្ទុជាអក្សរ** | **ការបរិយាយ** |
|---|---|---|---|
| ៤.០០ | ៨៥-១០០ | A | ល្អប្រសើរ |
| ៣.៥០ | ៨០-៨៤ | B+ | ល្អណាស់ |
| ៣.០០ | ៧០-៧៩ | B | ល្អ |
| **២.៥០** | **៦៥-៦៩** | C+ | **ល្អបង្គួរ** |
| ២.០០ | ៥០-៦៤ | C | មធ្យម |
| ១.៥០ | ៤៥-៤៩ | D+ | ខ្សោយ |
| ១.០០ | ៤០-៤៤ | D | ខ្សោយណាស់ |
| ០.០០ | ០-៣៩ | F | ធ្លាក់ |
| បញ្ជាក់៖ បរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម ត្រូវមានពិន្ទុនិទ្ទេសសរុបយ៉ាងតិច ៦៥.០០ (GPA ≥២.៥០) ឬនិទ្ទេស C+ | | | |

តារាង 14 តារាងវាយតម្លៃការបណ្តុះបណ្តាល

| ល.រ | ទម្រង់ការវាយតម្លៃ | ភាគរយ (%) |
|---|---|---|
| ១ | វត្តមាន និងការចូលរួមសិក្ខាសកម្ម | ១៥ |
| ២ | ការវាយតម្លៃជាដំណាក់ | ៣០ |
| ៣ | ការសរសេររបាយការណ៍គម្រោង | ៣០ |
| ៤ | ប្រឡងបញ្ចប់តាមមុខវិជ្ជា ឬបទបង្ហាញរបាយការណ៍គម្រោង | ២៥ |
| សរុប | | ១០០ |
| គ្រូឧទ្ទេសមានសិទ្ធិក្នុងការរៀបចំរង្វាយតម្លៃតាមមុខវិជ្ជាទទួលបន្ទុកក្នុងភាពបត់បែន | | |

## ២.៧ និន្នាការនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន

### ២.៧.១ មូលហេតុនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន

នៅក្នុងបរិបទដែលពិភពលោកមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនាពេលបច្ចុប្បន្ននេះ ប្រព័ន្ធអប់រំត្រូវតែផ្តល់អាទិភាពដល់ការរៀនសូត្រពេញមួយជីវិត និងការសម្របខ្លួនសម្រាប់សិស្ស។ ក្នុងដំណាក់កាលនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ការផលិតធនធានអប់រំតាមទម្រង់ប្រព័ន្ធ ឬគោលការណ៍ដដែលៗ ទោះបីមានចំនួនច្រើនក្តី ក៏នឹងមិនគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលអនាគតនោះទេ។ គ្រូបង្រៀនត្រូវតែផ្តោតលើការលើកកម្ពស់ប្រាជ្ញា ដើម្បីប្រែក្លាយជាអ្នកអប់រំជួរមុខ ដែលអនុញ្ញាតឱ្យពួកគេសម្របខ្លួន និងរីកចម្រើននៅក្នុងពិភពលោកដែលកំពុងមានការវិវត្តន៍នេះ។ ការផ្លាស់ប្តូរពីការផ្តោតទៅលើគោលនយោបាយទៅលទ្ធផល ទាមទារការផ្លាស់ប្តូរពីការផ្តល់នូវប្រាជ្ញាទៅជាការជំរុញប្រាជ្ញា (Andreas, S., 2012)។ កង្វះខាតគ្រូបង្រៀន ស្តង់ដារវិជ្ជាជីវៈមានកម្រិតទាប និងកម្រិតជីវភាព គឺជាឧបសគ្គរាំងចម្បងក្នុងការទទួលបានគុណភាពអប់រំ ជាពិសេសកុមារក្រីក្រប្រឈមនឹងឧបសគ្គទាំងនេះ។ ដើម្បីដោះស្រាយបញ្ហាប្រឈម តម្រូវឱ្យមានការអនុវត្តយុទ្ធសាស្ត្រដ៏ទូលំទូលាយសម្រាប់ការជ្រើសរើសគ្រូបង្រៀន ការរៀបចំ ការបណ្តុះបណ្តាល ការដាក់ពង្រាយ និងការផ្តល់ប្រាក់រង្វាន់លាភការផ្សេងៗ (Benveniste, L., Marshall, J., & Araujo, M. C., 2008d)។ ក្នុងនាមជាសមាជិករបស់ក្រុមការងារអន្តរជាតិ ស្តីពី គ្រូ

បង្រៀនសម្រាប់ការអប់រំឆ្នាំ២០១៥ បានលើកទឹកចិត្តឱ្យកម្ពុជាចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះបញ្ហាគ្រូបង្រៀន ជាលទ្ធផល រាជរដ្ឋាភិបាលកម្ពុជា មានការប៉ុនប៉ងយ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍វិធានការកំណែទម្រង់គោលនយោបាយគ្រូបង្រៀន ដើម្បីសម្រេចបាននូវការពង្រឹងសមត្ថភាពគ្រូបង្រៀន ដើម្បីពង្រឹងការអនុវត្តការងារនៅតាមសាលារៀន (Dy, S. S., 2017c)។

### ២.៧.២ អត្ថប្រយោជន៍នៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន

គុណភាពនៃការបង្រៀនពឹងផ្អែកលើបរិយាកាសសាលារៀន និងបរិយាកាសថ្នាក់រៀនដែលមានរចនាសម្ព័ន្ធល្អ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខារ ជំនួយគ្រប់គ្រាន់ ជាពិសេសលក្ខខណ្ឌការងារសមស្របជួយដល់មុខងារបង្រៀន និងជួយសិស្សក្នុងការរៀនសូត្រ។ សមាមាត្រគ្រូបង្រៀន និងសិស្សដែលមានតុល្យភាពធានាបាននូវការយកចិត្តទុកដាក់ជាបុគ្គល ខណៈដែលលក្ខខណ្ឌនៃកិច្ចសន្យាការងារ អាចសម្រួចដល់ការពេញចិត្ត និងភាពទាក់ទាញនៃវិជ្ជាជីវៈ។ ការសិក្សារបស់សិស្សទទួលបានលទ្ធផលប្រសើរ ត្រូវបានសង្កេតឃើញថាកើតចេញពីគ្រូបង្រៀនដែលមានកម្រិតសញ្ញាបត្រសកលវិទ្យាល័យចំណេះដឹងអំពីខ្លឹមសារគរុកោសល្យដ៏រឹងមាំ ជាគ្រូបង្រៀនក្នុងមូលដ្ឋាន និងមានវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាពដែលលើកកម្ពស់ការចូលរួមរបស់សិស្ស (Benveniste, L., Marshall, J., & Araujo, M. C., 2008e)។

### ២.៧.៣ បញ្ហាប្រឈមនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន

ការជ្រើសរើសគ្រូបង្រៀនចេញពីធនធានមនុស្សក្នុងមូលដ្ឋានជួបប្រទះបញ្ហានៃការទទួលបានគរុសិស្ស គរុនិស្សិតមានកម្រិត ដែលមិនគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀន។ ការពង្រីកលទ្ធភាពទទួលបានការអប់រំ ការផ្តល់ការឧបត្ថម្ភជំនួយដល់សិស្សក្រីក្រ និងការផ្តល់សេវាបណ្តុះបណ្តាលគ្រូដល់តំបន់ដែលខ្វះខាត គឺជាកត្តាសំខាន់។ ការផ្តល់វគ្គបណ្តុះបណ្តាលម៉ូឌុលដែលផ្តល់តាមរយៈសាលាមធ្យមសិក្សាទុតិយភូមិដែលមានស្រាប់អាចជាដំណោះស្រាយបណ្តោះអាសន្នដើម្បីដោះស្រាយបញ្ហាកង្វះខាតភ្លាមៗ (Benveniste, L., Marshall, J., & Araujo, M. C., 2008f)។

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ សេចក្តីផ្តើម

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ" ដើម្បីបានដឹងពីការឈ្វេងយល់របស់នាយកសាលាទៅលើដំណើរការកំណែទម្រង់ និងការអនុវត្តកម្មវិធីកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀន ដែលក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ។ គោលបំណងសំខាន់ៗនៃការសិក្សាស្រាវជ្រាវគឺ៖

១.សិក្សាឈ្វេងយល់ពីការយល់ឃើញរបស់នាយកសាលាទៅលើកំណែទម្រង់ ការជ្រើសរើស និងបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។

២.សិក្សាពីផលជះនៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិដល់សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

## ៣.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវដែលប្រើក្នុងការសិក្សាស្រាវជ្រាវ គឺវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ (Quantitative Research Method) ដោយប្រើវិធីបែបពិពណ៌នា (Descriptive Research Design)។ ការស្រាវជ្រាវបែបពិពណ៌នា គឺជាវិធីសាស្ត្រមួយក្នុងការប្រមូល និងវិភាគទិន្នន័យក្នុងគោលបំណងពិពណ៌នាអំពីលក្ខណៈ ឬបាតុភូតមួយ។ ជាធម្មតាវាត្រូវបានកំណត់ជាប្រភេទនៃការស្រាវជ្រាវបែបបរិមាណវិស័យ។ ការស្រាវជ្រាវបែបពិពណ៌នា គឺជាជម្រើសដ៏សមស្របនៅពេលដែលគោលបំណងស្រាវជ្រាវ គឺដើម្បីកំណត់លក្ខណៈ ប្រេកង់ និន្នាការ និងប្រភេទ (McCombes, S., 2022)។ វិធីសាស្ត្រស្រាវជ្រាវ គឺជានីតិវិធីជាក់លាក់សម្រាប់ការប្រមូល និងវិភាគទិន្នន័យ។

យោងតាមប្រធានបទខាងលើ អ្នកស្រាវជ្រាវបានសិក្សាតាមបែប បរិមាណវិស័យ (Quantitative Research) ដោយដំណើរការនៃការប្រមូល និងវិភាគទិន្នន័យជាលេខ។ វាអាចត្រូវបានប្រើដើម្បីស្វែងរក

គំរូ និងកម្រិតនៃមធ្យមពិន្ទុ ធ្វើការទស្សន៍ទាយ សាកល្បងទំនាក់ទំនងបុព្វហេតុ និងលទ្ធផលកាន់តែទូលំទូលាយ ដោយធ្វើការប្រមូលទិន្នន័យ ឬព័ត៌មានពាក់ព័ន្ធនានា ព្រមទាំងទស្សនៈ និងទ្រឹស្តីមួយចំនួនដែលទាក់ទងនឹងប្រធានបទ។ ទន្ទឹមនឹងនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍សម្ភាសន៍ដើម្បីទទួលបានទិន្នន័យឆ្លើយតបនឹងសំណួរស្រាវជ្រាវ។

## ៣.៣ ការប្រមូលទិន្នន័យ

ទិន្នន័យ គឺជាព័ត៌មានទាំងឡាយណាដែលអ្នកស្រាវជ្រាវប្រមូលសម្រាប់គោលបំណងនៃការឆ្លើយសំណួរស្រាវជ្រាវ ហើយប្រភេទទិន្នន័យដែលអ្នកស្រាវជ្រាវត្រូវការ អាស្រ័យលើគោលបំណងនៃការស្រាវជ្រាវ។ ទិន្នន័យនៃការសិក្សានេះ ត្រូវបានយកចេញពីការប្រើប្រាស់ឧបករណ៍សម្ភាសន៍។ យោងតាម (Lodico, M. G., Spaulding, D. T., & Voegtle, K. H., 2010) ការប្រមូល និងការវិភាគទិន្នន័យសម្រាប់ការស្រាវជ្រាវបែប បរិមាណវិស័យ គឺជាដំណើរការ ពីជាក់លាក់ ទៅជា ទូទៅ (inductive processes)។ ចំពោះការចុះប្រមូលទិន្នន័យនៅតាមវិទ្យាល័យក្នុងខេត្តតាកែវ គឺអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយក នាយក នាយិកា នាយករង និងនាយិការងវិទ្យាល័យ ជាគោលដៅសម្រាប់ធ្វើការសម្ភាសន៍ដើម្បីបានឈ្វេងយល់ពីការយល់ឃើញរបស់គាត់ និងសិក្សាពីផលជះនៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យពីរប្រភេទ គឺការប្រមូលទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ។

**ការប្រមូលទិន្នន័យបឋម៖** ប្រភពទិន្នន័យបឋម គឺជាអ្វីៗដែលផ្តល់ឱ្យអ្នកស្រាវជ្រាវនូវភស្តុតាងដោយផ្ទាល់អំពីមនុស្ស ព្រឹត្តិការណ៍ ឬបាតុភូត ដែលកំពុងស្រាវជ្រាវ និងក្លាយជាវត្ថុសំខាន់សម្រាប់ការវិភាគរបស់អ្នកស្រាវជ្រាវ។ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍ដើម្បីទទួលបានព័ត៌មានស៊ីជម្រៅ។

**ការសម្ភាសន៍ជនបង្គោល៖** ដោយប្រើវិធីសាស្ត្រ (Purposive Sampling) ជ្រើសរើសតាមនីតិវិធី (Critical Sampling)។ អ្នកស្រាវជ្រាវបានធ្វើការជួបសម្ភាសន៍ជាមួយនាយក នាយិកា នាយករង និងនាយិការងវិទ្យាល័យ ដើម្បីបានដឹងពីការយល់ឃើញ ក៏ដូចជាផលជះនៃកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជានៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិ។

**ការប្រមូលទិន្នន័យបន្ទាប់បន្សំ៖** ទិន្នន័យបន្ទាប់បន្សំ គឺជាអ្វីៗដែលពិពណ៌នា បកស្រាយ វាយតម្លៃ ឬវិភាគព័ត៌មានពីប្រភពចម្បង។ ទិន្នន័យនេះទទួលបានតាមរយៈសៀវភៅ ឯកសារនានា ប្រព័ន្ធអ៊ីនធឺណិត គេហទំព័រ និងស្ថាប័នពាក់ព័ន្ធជាដើម។ ហេតុដូចនេះ ប្រភពទិន្នន័យបឋមគឺ មានភាពជឿជាក់ ជាកស្តុតាង ខណៈដែលប្រភពទិន្នន័យបន្ទាប់បន្សំបង្ហាញពីរបៀបជាប់ទាក់ទងនឹងការស្រាវជ្រាវដែលមានស្រាប់។

ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលដោយផ្អែកលើជំហានដូចខាងក្រោម៖

(១) ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតអនុញ្ញាតឱ្យនិស្សិតចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទ

(២) អ្នកស្រាវជ្រាវរៀបចំលិខិតសុំការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីចុះប្រមូលទិន្ន័យនៅតាមវិទ្យាល័យគោលដៅ

(៣) អ្នកស្រាវជ្រាវរៀបចំឧបករណ៍សម្ភាសន៍

(៤) ស្នើសុំការពិនិត្យសម្រេច និងយោបល់ឯកភាពលើឧបករណ៍សម្ភាសន៍ពីគ្រូណែនាំគោល និងណែនាំរង

(៥) សុំការអនុញ្ញាតពីនាយក នាយិកា នាយករង និងនាយិករងវិទ្យាល័យគោលដៅ និងកំណត់កាលបរិច្ឆេទជួបសម្ភាសន៍

(៦) អ្នកស្រាវជ្រាវប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍

(៧) អ្នកស្រាវជ្រាវបានដំណើរការប្រភពទិន្នន័យដែលបានមកពីការស្រាវជ្រាវ ដោយប្រើការពិពណ៌នាទូទៅ និងការសន្និដ្ឋាន។

## ៣.៤ ឧបករណ៍ស្រាវជ្រាវ

ការប្រមូលទិន្នន័យ គឺប្រមូលតាមរយៈការប្រើប្រាស់ឧបករណ៍សម្ភាសន៍ (កម្រងសំណួរ) ដោយធ្វើការសម្ភាសន៍ face-to-face (Structured Interview) ជាមួយនាយក នាយិកា នាយករង នាយិការងវិទ្យាល័យទាំង២១ ក្នុងខេត្តតាកែវ។ យោងតាម (Fontana, A., & Frey, J. H., 2005) ការសម្ភាសន៍ គឺ

ជាការចោទសំណួរ និងឆ្លើយសំណួរ ដែលវាជាវិធីសាស្ត្រសាមញ្ញ និងមានប្រសិទ្ធភាពក្នុងការដែលយើងព្យាយាមស្វែងយល់ពីអ្នកដែលយើងសម្ភាសន៍។ ការសម្ភាសន៍អាចធ្វើឡើងតាមរយៈ ការសម្ភាសន៍ផ្ទាល់ (face-to-face) ឬតាមទូរសព្ទ ជាបុគ្គល ឬក្រុម។ ការសម្ភាសន៍អាចមានរចនាសម្ព័ន្ធជា Structured Interview ឬ Semi-structured Interview ឬ Unstructured Interview។ យោងតាម (www.scribbr.com, 2023) បានកំណត់ថា Structured Interview គឺជាវិធីសាស្ត្រប្រមូលទិន្នន័យដែលពឹងផ្អែកលើការចោទសួរសំណួរតាមលំដាប់លំដោយ ដើម្បីប្រមូលទិន្នន័យលើប្រធានបទមួយ។ ចំពោះប្រធានបទខាងលើ អ្នកស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍សម្ភាសន៍ (កម្រងសំណួរ) ដោយប្រើប្រាស់រចនាសម្ព័ន្ធនៃការសម្ភាសន៍បែប Structured Interview ដោយបានរៀបចំកម្រងសំណួរសម្ភាស៍តាមប្រភេទសំណួរបើក និងសំណួរបិទ និងធ្វើការសម្ភាសន៍ដោយផ្ទាល់ (face-to-face) ជាមួយនាយកនាយិកា នាយករង នាយិការងវិទ្យាល័យដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់។ យោងតាម (Reja, U., Manfreda, K. L., Hlebec, V., & Vehovar, V., 2003) សំណួរបើក គឺអនុញ្ញាតឱ្យអ្នកឆ្លើយបានបញ្ចេញគំនិតយោបល់តាមការយល់ឃើញផ្ទាល់ខ្លួនដោយមិនមានការកំណត់ចម្លើយពីអ្នកសួរ។ គួរបញ្ជាក់ផងដែរថា សំណួរបើក គឺជាកម្រងសំណួរមួយប្រភេទដែលត្រូវបានប្រើក្នុងការស្រាវជ្រាវបែបគុណវិស័យ ទោះបីជាការស្រាវជ្រាវមួយចំនួន នឹងកំណត់បរិមាណចម្លើយក្នុងដំណាក់កាលវិភាគក៏ដោយ។ សំណួរនីមួយៗមិនមានប្រអប់សម្រាប់គូសទេ ប៉ុន្តែផ្ទុយទៅវិញទុកផ្នែកទទេសម្រាប់ឱ្យអ្នកឆ្លើយសរសេរចម្លើយ។ ចំណែកសំណួរបិទ អ្នកឆ្លើយត្រូវជ្រើសរើសចម្លើយដែលអ្នកសួរបានផ្ដល់នូវចម្លើយជម្រើសជូន។ ប្រភេទនៃកម្រងសំណួរនេះ ត្រូវបានប្រើដើម្បីបង្កើតស្ថិតិក្នុងការស្រាវជ្រាវបែបបរិមាណវិស័យ ដោយកម្រងសំណួរទាំងអស់ធ្វើតាមទម្រង់ដែលបានកំណត់ ហើយភាគច្រើនអាចត្រូវបានបញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រដើម្បីភាពងាយស្រួលសម្រាប់ការវិភាគទិន្នន័យជាលេខ។ អ្នកស្រាវជ្រាវជាច្រើនមានទំនោរនឹងប្រើការរួមបញ្ចូលគ្នានៃទម្រង់សំណួរបើក និងទម្រង់សំណួរបិទ។ កម្រងសំណួរជាច្រើនចាប់ផ្ដើមជាមួយនឹងសំណួរបិទជាបន្តបន្ទាប់ ដែលមានប្រអប់ដើម្បីគូស ឬធ្វើមាត្រដ្ឋានដើម្បីចាត់ថ្នាក់ ហើយបន្ទាប់មកបញ្ចប់ដោយផ្នែកនៃ

សំណួរបើកចំហសម្រាប់ការឆ្លើយតបលម្អិត និងផ្តល់ជាតុចូលបន្ថែមទៀត។ កម្រងសំណួរសម្ភាសន៍ត្រូវបានផ្តល់ជូនក្នុងឧបសម្ព័ន្ធ ៧ ដែលមានបួនផ្នែកសំខាន់ៗរួមមាន៖

ផ្នែកទី១៖ ព័ត៌មានប្រជាសាស្ត្រ ដែលផ្តល់ឱ្យអ្នកឆ្លើយផ្តល់នូវព័ត៌មានទូទៅដូចជា ភេទ អាយុ បទពិសោធការងារ កម្រិតវប្បធម៌ ក្របខ័ណ្ឌ ទីតាំង និងប្រភេទតំបន់របស់គ្រឹះស្ថានសិក្សា

ផ្នែកទី២៖ ការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ

ផ្នែកទី៣៖ ការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

ផ្នែកទី៤៖ ការយល់ដឹងទូទៅ និងសំណូមពរ។

## ៣.៥ ទំហំសំណាក និងការធ្វើសំណាក

គំរូ ឬសំណាក ទាក់ទងទៅនឹងការជ្រើសរើសក្រុមរងនៃបុគ្គលពីក្នុងចំណោមចំនួនក្រុមទាំងមូលដើម្បីប៉ាន់ប្រមាណលក្ខណៈនៃចំនួនប្រជាជនទាំងមូល។ គុណសម្បត្តិចម្បងពីរនៃការយកគំរូ ឬសំណាកគឺការប្រមូលទិន្នន័យកាន់តែលឿន និងចំណាយតិច (Singh, A. S., & Masuku, M. B., 2014a)។ ការកំណត់ទំហំគំរូ ឬសំណាក គឺជាបច្ចេកទេសនៃការជ្រើសរើសចំនួននៃការសង្កេតដាក់បញ្ចូលនៅក្នុងគំរូមួយ ដែលមានសារៈសំខាន់ក្នុងការសិក្សា ឬការអង្កេតណាមួយ នៅក្នុងគោលបំណងដើម្បីធ្វើឱ្យការសន្និដ្ឋានអំពីចំនួនប្រជាជន ឬក្រុមស្ថិតិដោយផ្អែកលើគំរូដែលបានជ្រើសរើស។ ជាធម្មតាវាត្រូវបានកំណត់ដោយផ្អែកលើតម្លៃ និងភាពគ្រប់គ្រាន់នៃទិន្នន័យ។ ករណីការសិក្សាស៊ីជម្រៅអាចនឹងរួមបញ្ចូលទំហំគំរូជាច្រើនដូចជាការធ្វើគំរូតាមកម្រិត ឬការរាប់បញ្ចូលទាំងស្រុង។ បច្ចេកទេសនៃការជ្រើសរើសគំរូ ឬសំណាកអាចធ្វើឡើងដោយពិចារណាលើបុគ្គលតាមរយៈ ការស៊ើបអង្កេត អាចត្រូវបានធ្វើឡើងលើក្រុមទាំងមូល ឬអ្នកតំណាងដែលដកចេញពីក្រុម ឬនៅពេលណាដែលគំរូត្រូវបានជ្រើសរើស វាគួរតែជាគំរូចៃដន្យ ឬខណៈពេលដែលជ្រើសរើសគំរូ ភាពមិនដូចគ្នានៅក្នុងក្រុមគួរតែត្រូវបានរក្សាទុកក្នុងចិត្ត និងបច្ចេកទេសគំរូត្រឹមត្រូវគួរតែត្រូវបានអនុវត្ត (Singh, A. S., & Masuku, M. B., 2014b)។

ដើម្បីទទួលបានទិន្នន័យក្នុងការសរសេរនិក្ខេបបទ អ្នកស្រាវជ្រាវធ្វើការប្រមូលទិន្នន័យពីខេត្តគោលដៅគឺខេត្តតាកែវ តាមវិធីជ្រើសរើសសំណាក Purposive Sampling ហើយក្រុមគោលដៅរួមមាន

នាយក នាយិកា នាយករង និងនាយិការងវិទ្យាល័យ ដោយបានប្រើប្រាស់ឧបករណ៍សម្ភាសន៍ដែលបានត្រួតពិនិត្យកែលម្អដោយសាស្ត្រាចារ្យណែនាំគោល និងណែនាំរង ដើម្បីរកឱ្យឃើញពីការយល់ឃើញនានារបស់នាយក នាយិកា នាយករង នាយិការងវិទ្យាល័យចំពោះកំណែទម្រង់ការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ក៏ដូចជាឧត្តមានុវត្ត និងផលជះនៃការអនុវត្តកំណែទម្រង់ រួមទាំងជាតុចូល និងសំណូមពររបស់អ្នកពាក់ព័ន្ធ។

ជាលទ្ធផល អ្នកស្រាវជ្រាវជ្រើសរើសយកខេត្តតាកែវ និងវិទ្យាល័យសរុបចំនួន២១ ដែលស្ថិតក្នុងតំបន់ជួបការលំបាក តំបន់ធម្មតា និងតំបន់ទីប្រជុំជន មកពីបណ្ដាស្រុកទាំង៥ រួមមាន៖

តារាង 15 វិទ្យាល័យគោលដៅ និងចំនួនសំណាក

| ល.រ | គ្រឹះស្ថានសិក្សា | ស្រុក | ប្រភេទតំបន់ | ចំនួនសំណាក |
|---|---|---|---|---|
| ១ | វិទ្យាល័យ ហ៊ុនសែន១មិថុនា | បាទី | ធម្មតា | ៣ |
| ២ | វិទ្យាល័យ ក្រាំងស្លា | ព្រៃកប្បាស | ធម្មតា | ៣ |
| ៣ | វិទ្យាល័យ សមរលាវ | ព្រៃកប្បាស | ធម្មតា | ២ |
| ៤ | វិទ្យាល័យ ចំប៉ា | ព្រៃកប្បាស | ធម្មតា | ២ |
| ៥ | វិទ្យាល័យ អង្គអណ្ដែត | ព្រៃកប្បាស | ធម្មតា | ២ |
| ៦ | វិទ្យាល័យ ភ្នីមាស | ព្រៃកប្បាស | ទីប្រជុំជន | ២ |
| ៧ | វិទ្យាល័យ ខ្សាច់ស | សំរោង | ធម្មតា | ២ |
| ៨ | វិទ្យាល័យ សុខអានក្ដីទន្ទឹម | សំរោង | ធម្មតា | ២ |
| ៩ | វិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនភ្នំជីសូរ | សំរោង | ធម្មតា | ១ |
| ១០ | វិទ្យាល័យ អេអូជីតាយឹង | សំរោង | ធម្មតា | ២ |
| ១១ | វិទ្យាល័យ សម្ដេចឪ | សំរោង | ទីប្រជុំជន | ៣ |
| ១២ | វិទ្យាល័យ អង្គសង្កែ | ត្រាំកក់ | ជួបការលំបាក | ២ |

| | | | | |
|---|---|---|---|---|
| ១៣ | វិទ្យាល័យ ហ៊ុនសែនត្នោតជុំ | ត្រាំកក់ | ជួបការលំបាក | ២ |
| ១៤ | វិទ្យាល័យ សម្តេចក្រុមព្រះ...អង្គរនាប | ត្រាំកក់ | ធម្មតា | ២ |
| ១៥ | វិទ្យាល័យ អង្គរកា | ត្រាំកក់ | ធម្មតា | ៣ |
| ១៦ | វិទ្យាល័យ សុខអាន១ឧសភា | ត្រាំកក់ | ទីប្រជុំជន | ១ |
| ១៧ | វិទ្យាល័យ ហ៊ុនសែនពោធិ៍អំពិល | ទ្រាំង | ជួបការលំបាក | ១ |
| ១៨ | វិទ្យាល័យ សម្តេចហ៊ុនសែន | ទ្រាំង | ជួបការលំបាក | ២ |
| ១៩ | វិទ្យាល័យ ព្រៃទប់ | ទ្រាំង | ធម្មតា | ២ |
| ២០ | វិទ្យាល័យ វត្តបារាយណ៍វិហារពីរ | ទ្រាំង | ធម្មតា | ២ |
| ២១ | វិទ្យាល័យ សុខអានព្រៃសណ្តែក | ទ្រាំង | ទីប្រជុំជន | ២ |
| សរុប | | | | ៤៣ |

## ៣.៦ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ គឺជាដំណើរការនៃការទទួលបានទិន្នន័យទៅ ដោយធ្វើការត្រួតពិនិត្យ សម្អាត ការបំប្លែង និងគំរូទិន្នន័យដែលមានគោលដៅស្វែងរកព័ត៌មានដែលមានប្រយោជន៍ដល់ការសន្និដ្ឋាន និងគាំទ្រការសម្រេចចិត្ត (Wikipedia, 2023)។ ទិន្នន័យដែលប្រមូលបានពីឧបករណ៍សម្ភាសន៍ ត្រូវបានធ្វើការវិភាគតាមបែប បរិមាណវិស័យ ដោយអ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគបែបពណ៌នាស្ថិតិ (Descriptive Statistics) តាមរយៈកម្មវិធី SPSS version ២៦ ក្នុងការរកតម្លៃមធ្យម (M) និងតម្លៃគម្លាតស្តង់ដា (SD) ដើម្បីឆ្លើយសំណួរស្រាវជ្រាវ ដោយកំណត់ភាពខុសគ្នានៃតម្លៃមធ្យម (M)។ តម្លៃមធ្យម (M) ចន្លោះពី ១.០០ ដល់ ២.៤៩ មានន័យថា កម្រិតទាប ចន្លោះពី ២.៥០ ដល់ ៣.៤៩ មានន័យថាកម្រិតមធ្យម និងចន្លោះពី ៣.៥០ ដល់ ៥.០០ មានន័យថា កម្រិតខ្ពស់ (WUJIABUDULA, A., 2019)។ បន្ទាប់មកប្រើប្រាស់កម្មវិធី Microsoft Excel version ២០១៩ ដើម្បីសង់ក្រាហ្វ ដ្យាក្រាម និងប្រើប្រាស់កម្មវិធី Microsoft Word version ២០១៩ ក្នុងការបកស្រាយលើក្រាហ្វ តារាង ដោយធ្វើការសរសេរជារបាយការណ៍នៅក្នុងការវិភាគទិន្នន័យនេះ និងការពិភាក្សាចុងបញ្ចប់ដោយធ្វើសេចក្តីសន្និដ្ឋាន និង

ផ្តល់ជាអនុសាសន៍។

អ្នកស្រាវជ្រាវបានប្រើមាត្រដ្ឋាន Likert សម្រាប់វិភាគទិន្នន័យ។ មាត្រដ្ឋាន Likert គឺជាមាត្រដ្ឋានមួយក្នុងចំណោមមាត្រដ្ឋានដែលមានគោលបំណង ដើម្បីទទួលបានចម្លើយនៃការស្រាវជ្រាវពីអ្នកឆ្លើយសំណួរ។ អ្នកស្រាវជ្រាវបានកំណត់ចម្លើយរបស់មាត្រដ្ឋាន Likert ចំនួនប្រាំដូចជា មិនយល់ស្របទាំងស្រុង មិនយល់ស្រប អព្យាក្រឹត យល់ស្រប និងយល់ស្របទាំងស្រុង ដែលមាននៅក្នុងឧបករណ៍សម្ភាសន៍។ ជាលទ្ធផលនៃមាត្រដ្ឋាន Likert អ្នកស្រាវជ្រាវបានប្រើការស្រាវជ្រាវបរិមាណ ដើម្បីរាប់ភាគរយនៃឧត្តមានុវត្ត និងដំណោះស្រាយលើបញ្ហាប្រឈម នៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។

## ៣.៧ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ ករណីសិក្សា ខេត្តតាកែវ" នេះធ្វើឡើងទៅបាន អាស្រ័យដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ សាស្ត្រាចារ្យណែនាំគោល សាស្ត្រាចារ្យណែនាំរង មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយក នាយិកា នាយករង នាយិការងវិទ្យាល័យទាំង២១ និងមិនបង្កហានិភ័យដល់តំណាងគំរូ។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះមានស្តង់ដាប្រកបដោយក្រមសីលធម៌ស្រាវជ្រាវដូចជាការរក្សាទំនុកចិត្ត រក្សាការសម្ងាត់ដោយមិនបង្ហាញអត្តសញ្ញាណអ្នកចូលរួមសម្ភាសន៍(ដាក់ជាលេខកូដតំណាង)។ អ្នកចូលរួមសម្ភាសន៍ទាំងអស់ត្រូវបានសុំការអនុញ្ញាតជាមុន និងផ្តល់កិច្ចសម្ភាសន៍ដោយស្ម័គ្រចិត្តគ្មានការបង្ខិតបង្ខំ និងបានយល់ដឹងច្បាស់អំពីនីតិវិធីក្នុងការសម្ភាសន៍។ អ្នកចូលរួមសម្ភាសន៍គ្រប់រូបទាំងអស់មានសិទ្ធិរំលងសំណួរណាមួយដែលសាមីខ្លួនមិនចង់ឆ្លើយបានគ្រប់ពេលវេលា។ មិនតែប៉ុណ្ណោះ ការសិក្សាស្រាវជ្រាវនេះ បានដាក់បញ្ចូលនូវសេចក្តីណែនាំ និងបញ្ជាក់បន្ថែមផ្សេងៗ ដែលមានបង្ហាញពីគោលបំណងមុននឹងចាប់ផ្តើមសម្ភាសន៍នៅខាងលើឧបករណ៍សម្ភាសន៍នីមួយៗ។ ដូច្នេះរាល់ពត៌មានដែលទទួលបាន នឹងត្រូវបានរក្សាជាការសម្ងាត់ សុវត្ថិភាព និងត្រូវបានលុបចោលក្រោយពេលវិភាគទិន្នន័យចប់ជាស្ថាពរ។

# ជំពូក ៤

# លទ្ធផលនៃការស្រាវជ្រាវ

# និងការពិភាក្សា

# ជំពូក ៤

## លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងយកលទ្ធផលដែលទទួលបានពីការប្រើប្រាស់ឧបករណ៍សម្ភាសន៍ និងទិន្នន័យបន្ទាប់ពីបានបញ្ចូលនៅក្នុងកម្មវិធីSPSSរួច មកធ្វើការបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវ និងធ្វើការពិភាក្សាទៅតាមសំណួរស្រាវជ្រាវ ដោយលើកយកនូវអំណះអំណាងរបស់អ្នកចូលរួមមកបកស្រាយ និងពិភាក្សា។

### ៤.១ ព័ត៌មានប្រជាសាស្ត្រ




ក្រាហ្វ 1 ភេទ និងអាយុអ្នកចូលរួមសម្ភាសន៍

យោងតាមការវិភាគទិន្ន័យ បានបង្ហាញឱ្យដឹងថា អ្នកចូលរួមសម្ភាសន៍ទាំងអស់មានចំនួន ៤៣ នាក់ ស្មើនឹង ១០០% សំណាក ក្នុងនោះ ស្រី ៨នាក់ ស្មើនឹង ១៨.៦០% និងប្រុស ៣៥នាក់ ស្មើនឹង ៨១.៤០% ដែលមានកម្រិតអាយុចន្លោះពី ២១ឆ្នាំ ដល់ ៣០ឆ្នាំ ចំនួន ៣នាក់ ស្មើនឹង ៦.៩៨% ចន្លោះពី ៣១ឆ្នាំ ដល់ ៤០ឆ្នាំ ចំនួន ១៣នាក់ ស្មើនឹង ៣០.២៣% ចន្លោះពី ៤១ឆ្នាំ ដល់ ៥០ឆ្នាំ ចំនួន ២៤នាក់ ស្មើនឹង ៥៥.៨១% និង ចន្លោះពី ៥១ឆ្នាំ ដល់ ៦០ឆ្នាំ ចំនួន ៣នាក់ ស្មើនឹង ៦.៩៨% (ក្រាហ្វ ១ ភេទ និងអាយុរបស់អ្នកចូលរួមសម្ភាសន៍)។




ក្រាហ្វ 2 កម្រិតវប្បធម៌

យោងតាមក្រាហ្វខាងលើ នៅក្នុងចំណោមសំណាក ១០០% អ្នកចូលរួមដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួន ១៨.៦០% សញ្ញាបត្របរិញ្ញាបត្រមានចំនួន ៦០.៤៧% និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ២០.៩៣% (ក្រាហ្វ ២ កម្រិតវប្បធម៌)។




ក្រាហ្វ 3 កម្រិតបណ្ដុះបណ្ដាលវិជ្ជាជីវៈ

ផ្អែកតាមទិន្នន័យក្នុងក្រាហ្វខាងលើ អ្នកចូលរួមដែលមានកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន ៤៤.១៩% និងជាគ្រូបង្រៀនកម្រិតឧត្តម ចំនួន ៥៥.៨១% (ក្រាហ្វ ៣ កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ)។




ក្រាហ្វ 4 បទពិសោធដឹកនាំគ្រប់គ្រង

យោងទៅតាមទិន្នន័យ (ក្រាហ្វ ៤ បទពិសោធដឹកនាំគ្រប់គ្រង) បានបង្ហាញថា នៅក្នុងចំណោមសំណាក ១០០% អ្នកដែលមានបទពិសោធដឹកនាំគ្រប់គ្រងតិចជាង៥ឆ្នាំមានចំនួន ៤.៦៥% ចន្លោះពី៥ឆ្នាំ ដល់ ១០ឆ្នាំ មានចំនួន ៤១.៨៦% និងលើសពី ១០ឆ្នាំមានចំនួន ៥៣.៤៩% ។

## ៤.២ ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូ

### ៤.២.១ ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ

ផ្អែកតាមការវិភាគទិន្នន័យដែលទទួលបានពីឧបករណ៍សម្ភាសន៍ ផ្នែកទី២៖ ការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ ចាប់ពីសូចនាករទី១ ដល់ទី៩ បានបង្ហាញនូវលទ្ធផលស្តីពីឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដូចខាងក្រោម៖

តារាង 16 ឧត្តមមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ

| | ការបរិយាយ | តម្លៃមធ្យម (M) | គម្លាតស្តង់ដា (SD) | មិនយល់ស្របទាំងស្រុង | មិនយល់ស្រប | អព្យាក្រឹត | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|
| ១ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិជាចំណុចចាប់ផ្តើមនៃការធានាគុណភាពអប់រំនៅកម្ពុជា | 4.42 | 0.54 | 0.00% | 0.00% | 2.33% | 53.49% | 44.19% |
| ២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិបង្កើតឱ្យមាននីតិវិធីនិងលក្ខខណ្ឌនៃការជ្រើសរើសគ្រូបង្រៀនបានច្បាស់លាស់ | 4.47 | 0.63 | 0.00% | 0.00% | 6.98% | 39.53% | 53.49 % |
| ៣ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនជួយឱ្យមានតុល្យភាពក្នុងការបែងចែកគ្រូបង្រៀន | 4.28 | 0.83 | 0.00% | 6.98% | 2.33% | 46.51% | 44.19% |
| ៤ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាពិតជាបានជ្រើសរើសគ្រូបង្រៀនចេញថ្មីឆ្លើយតបទៅតម្រូវការប្រើប្រាស់ | 4.40 | 0.49 | 0.00% | 0.00% | 0.00% | 60.47% | 39.53% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ដាក់ស្តែងនៅកម្រិតសាលារៀន និងអង្គភាពខ្វះគ្រូ | | | | | | | |
| ៥ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិជានាបានស្ថេរភាពនៃការបំពេញភារកិច្ចរបស់គ្រូបង្រៀនចេញថ្មីប្រកបដោយការទទួលខុសត្រូវ | 3.86 | 1.08 | 2.33% | 16.28% | 2.33% | 51.16% | 27.91% |
| ៦ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិទទួលបានគ្រូបង្រៀនចេញថ្មីដែលមានមនសិការវិជ្ជាជីវៈការងារ មានជំនាញ និងសមត្ថភាព | 3.98 | 0.99 | 2.33% | 9.30% | 6.98% | 51.16% | 30.23% |
| ៧ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនទទួលបានគ្រូបង្រៀនមុខវិជ្ជាឯកទេសត្រឹមត្រូវជានាបានប្រសិទ្ធភាពនៃការបង្រៀន និងរៀន | 4.42 | 0.66 | 0.00% | 2.33% | 2.33% | 46.51% | 48.84% |
| ៨ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនបានពង្រឹងស្មារតីម្ចាស់ការ និងការទទួលខុសរបស់នាយកសាលា | 4.33 | 0.64 | 0.00% | 2.33% | 2.33% | 55.81% | 39.53% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ការធ្វើផែនការក្របខណ្ឌ | | | | | | | |
| ៩ | បានត្រឹមត្រូវនាំឱ្យការជ្រើសរើសគ្រូបានត្រឹមត្រូវ | 4.42 | 0.50 | 0.00% | 0.00% | 0.00% | 58.14% | 41.86% |

យោងតាមលទ្ធផលនៃការវិភាគទិន្នន័យ លើការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ និងផ្អែកលើតម្លៃមធ្យម (M) របស់សូចនាករនីមួយៗ លើសពីកម្រិត ៣.៥០ បង្ហាញឱ្យឃើញថា កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាពិតជាបានចូលរួមចំណែកធ្វើឱ្យមានភាពប្រសើរឡើងក្នុងការអនុវត្តការងារនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ ដោយបានជំរុញនិងធានាគុណភាពអប់រំនៅកម្ពុជា តាមរយៈការជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចូលក្របខ័ណ្ឌគ្រូបង្រៀន ការបែងចែកគ្រូបង្រៀនមានតុល្យភាពផ្តល់នូវសមភាពសម្រាប់ការអប់រំទាំងនៅតំបន់ទីប្រជុំជន តំបន់ធម្មតា តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល។ មិនតែប៉ុណ្ណោះ គ្រូបង្រៀនចេញថ្មីមានឯកទេសឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជាក់ស្តែង ហើយថែមទាំងធានាបាននូវស្ថេរភាពនៃការបំពេញការងាររបស់គ្រូបង្រៀន ដោយប្រាកដថាបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ គ្រូបង្រៀនចេញថ្មីទាំងអស់នឹងទៅបម្រើការងារនៅតាមប៉ុស្តិ៍គោលដៅ ដែលសាមីជនបានជ្រើសរើសមុនការប្រឡង។ ទន្ទឹមនឹងនេះ គ្រូបង្រៀនចេញថ្មីគ្រប់រូបប្រកបដោយមនសិការវិជ្ជាជីវៈ ចំណេះដឹងជំនាញ និងសមត្ថភាពជាអ្នកអប់រំដែលធានាបាននូវប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ លើសពីនេះទៅទៀត ក៏បានពង្រឹងនូវស្មារតីម្ចាស់ការរបស់នាយក នាយិកា នាយករង នាយិការងសាលារៀន ក្នុងការបំពេញភារកិច្ចជាអ្នកគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់ តាមរយៈការរៀបចំនូវផែនការនានា ជាពិសេសផែនការប្រើប្រាស់បុគ្គលិក ការបែងចែកភារកិច្ចទទួលខុសត្រូវ ការរៀបចំសេវាបង្រៀន ការគ្រោងផែនការក្របខ័ណ្ឌ និងផែនការសកម្មភាពនានាជាប្រចាំ ដើម្បីប្រាកដថាសាលារៀនដំណើរការដោយមិនប្រឈមនឹងការប្រើប្រាស់ធនធានគ្រូបង្រៀនខ្វះខ្នាយ ឬខ្វះខាតធនធានគ្រូបង្រៀនដោយប្រការណាមួយ (តារាង ១៦ ឧត្តមមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ)។




ក្រាហ្វ 5 ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ

ក្រាហ្វ ៥ ខាងលើបង្ហាញពីតម្លៃមធ្យម (M) អ្នកចូលរួមដែលឆ្លើយតបទៅនឹងឧត្តមានុវត្តនៃកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។ ខាងក្រោមនេះ គឺជាកំណត់សម្គាល់បន្ថែមដើម្បីជំនួយដល់ការស្វែងយល់អំពីទិន្នន័យរបស់ក្រាហ្វ ៥៖

តារាង 17 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៥

| លេខសម្គាល់ | ការបរិយាយ | | |
|---|---|---|---|
| | សូចនាករ | ផ្នែកនៃឧបករណ៍សម្ភាសន៍ | ខ្លឹមសារ |
| 1 | ទី១ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិជាចំណុចចាប់ផ្តើមនៃការធានាគុណភាពអប់រំនៅកម្ពុជា |

| | | | |
|---|---|---|---|
| 2 | ទី២ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិបង្កើតឱ្យមាននីតិវិធី និងលក្ខខណ្ឌនៃការជ្រើសរើសគ្រូបង្រៀនបានច្បាស់លាស់ |
| 3 | ទី៣ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនជួយឱ្យមានតុល្យភាពក្នុងការបែងចែកគ្រូបង្រៀន |
| 4 | ទី៤ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាពិតជាបានជ្រើសរើសគ្រូបង្រៀនចេញថ្មីឆ្លើយតបទៅតម្រូវការប្រើប្រាស់ជាក់ស្តែងនៅកម្រិតសាលារៀន និងអង្គភាពខ្វះគ្រូ |
| 5 | ទី៥ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិធានាបានស្ថេរភាពនៃការបំពេញភារកិច្ចរបស់គ្រូបង្រៀនចេញថ្មីប្រកបដោយការទទួលខុសត្រូវ |
| 6 | ទី៦ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិទទួលបានគ្រូបង្រៀនចេញថ្មីដែលមានមនសិការវិជ្ជាជីវៈការងារ មានជំនាញ និងសមត្ថភាព |
| 7 | ទី៧ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនទទួលបានគ្រូបង្រៀនមុខវិជ្ជាឯកទេសត្រឹមត្រូវធានាបានប្រសិទ្ធភាពនៃការបង្រៀន និងរៀន |
| 8 | ទី៨ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនបានពង្រឹងស្មារតីម្ចាស់ការ និងការទទួលខុសរបស់នាយកសាលា |
| 9 | ទី៩ | ផ្នែកទី២ | ការធ្វើផែនការក្របខណ្ឌបានត្រឹមត្រូវនាំឱ្យការជ្រើសរើសគ្រូបានត្រឹមត្រូវ |

### ៤.២.២ ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

ផ្អែកតាមការវិភាគទិន្នន័យដែលទទួលបានពីឧបករណ៍សម្ភាសន៍ ផ្នែកទី៣៖ ការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ចាប់ពីសូចនាករទី១៧ ដល់សូចនាករទី២៩ បានបង្ហាញនូវលទ្ធផល ស្តីពីឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

នៅកម្ពុជា ដូចខាងក្រោម៖

តារាង 18 ឧត្តមមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

| | ការបរិយាយ | មធ្យមភាគ (M) | គម្លាតស្តង់ដា (SD) | មិនយល់ស្របទាំងស្រុង | មិនយល់ស្រប | អព្យាក្រឹត | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|
| ១៧ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិជាចំណុចចាប់ផ្តើមនៃការធានាគុណភាពអប់រំនៅកម្ពុជា | 4.07 | 1.03 | 6.98% | 2.33% | 0.00% | 58.14% | 32.56% |
| ១៨ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលមានទាំងចំណេះដឹង គុណវុឌ្ឍិ ជំនាញ សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ | 4.47 | 0.50 | 0.00% | 0.00% | 0.00% | 53.49% | 46.51% |
| ១៩ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ទទួលបានគ្រូបង្រៀនដែលយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀបរៀន ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សារបស់សិស្ស | 3.95 | 0.90 | 2.33% | 9.30% | 0.00% | 67.44% | 20.93% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២០ | កំណែទម្រង់ការបណ្តុះបណ្តាល ទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពក្នុងការរៀបចំកិច្ចតែងការផលិតសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀនមានប្រសិទ្ធភាព | 4.05 | 0.79 | 0.00% | 9.30% | 0.00% | 67.44% | 23.26% |
| ២១ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះប្រើប្រាស់វិធីសាស្ត្របង្រៀន និងចេះជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាសិស្សបានសមស្រប | 4.28 | 0.59 | 0.00% | 2.33% | 0.00% | 65.12% | 32.56% |
| ២២ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះបញ្ច្រាបខ្លឹមសារពីមេរៀនមួយទៅមេរៀនមួយ ឱ្យសិស្សទទួលបានបំណិនជាច្រើននិងមានចិត្តចង់រៀន | 4.14 | 0.52 | 0.00% | 2.33% | 0.00% | 79.07% | 18.60% |
| ២៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះដោះស្រាយបញ្ហាប្រឈមក្នុងការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន | 4.09 | 0.29 | 0.00% | 0.00% | 0.00% | 90.70% | 9.30% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៤ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះរៀបចំកម្មវិធីសិក្សា និងផែនការបង្រៀនបានត្រឹមត្រូវ | 4.28 | 0.45 | 0.00% | 0.00% | 0.00% | 72.09% | 27.91% |
| ២៥ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាផ្សារភ្ជាប់នឹងការបង្រៀន ភាសា និងមានគំនិតច្នៃប្រឌិត | 4.28 | 0.70 | 0.00% | 4.65% | 0.00% | 58.14% | 37.21% |
| ២៦ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលមានការទទួលខុសត្រូវខ្ពស់ និងប្រតិបត្តិវិជ្ជាជីវៈបានល្អ | 4.28 | 0.50 | 0.00% | 0.00% | 2.33% | 67.44% | 30.23% |
| ២៧ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះផ្តល់ឱកាសឱ្យសិស្សចេះដោះស្រាយបញ្ហា ស្វ័យសិក្សា និងមានភាពម្ចាស់ការ | 4.33 | 0.61 | 0.00% | 2.33% | 0.00% | 60.47% | 37.21% |
| ២៨ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលមានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវពង្រីកចំណេះដឹង និងចេះចែករំលែក | 4.26 | 0.44 | 0.00% | 0.00% | 0.00% | 74.42% | 25.58% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៩ | គ្រូបង្រៀនកម្រិតឧត្តម ចេញថ្មីឆ្នាំ២០២០ និង ២០២២ ពិតជាមាន គុណវុឌ្ឍិ និងសមត្ថភាព វិជ្ជាជីវៈសមស្របសម្រាប់ ការអប់រំសតវត្សទី២១ | 4.35 | 0.53 | 0.00% | 0.00% | 2.33% | 60.47% | 37.21% |

យោងតាមលទ្ធផលនៃការវិភាគទិន្នន័យ នៃការអនុវត្តកំណែទម្រង់ការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិ និងផ្អែកលើតម្លៃមធ្យម (M) របស់សូចនាករនីមួយៗ លើសពីកម្រិត ៣.៥០ បង្ហាញឱ្យឃើញថា កំណែទម្រង់ការបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាបានផ្ដល់នូវប្រសិទ្ធភាព និងផលជះវិជ្ជមានចំពោះការអនុវត្តការងារនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិដោយបានចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។ គ្រូបង្រៀនចេញថ្មីមានទាំងចំណេះដឹង ជំនាញ គុណវុឌ្ឍិខ្ពស់ សមត្ថភាពពេញលេញ និងមានក្រមសីលធម៌។ ជាងនេះទៅទៀត គ្រូបង្រៀនក្នុងដំណាក់កាលកំណែទម្រង់មានជំនាញសតវត្សទី២១ មានសមត្ថភាពយល់ដឹងច្បាស់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន យល់ពីសមត្ថភាព ទេពកោសល្យ និងរបៀបរៀនរបស់សិស្ស ដែលអាចនាំឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ គ្រូបង្រៀនមានសមត្ថភាពរៀបចំកិច្ចការបង្រៀន ចេះផលិត និងប្រើប្រាស់សម្ភារឧបទេស ចេះជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងចេះគ្រប់គ្រងថ្នាក់រៀន ក៏ដូចជាលទ្ធភាពក្នុងការដោះស្រាយនូវបញ្ហាប្រឈមនានាដែលកើតមានក្នុងដំណើរការបង្រៀននិងរៀន។ ជាមួយគ្នានេះដែរ គ្រូបង្រៀនចេះផ្ដល់ឱកាសឱ្យសិស្សចេះរៀនដោយខ្លួនឯង ចេះដោះស្រាយបញ្ហា និងភាពម្ចាស់ការលើការសិក្សា។ គ្រូបង្រៀនចេញថ្មីបានរៀបចំកម្មវិធីសិក្សា និងផែនការបង្រៀនបានត្រឹមត្រូវ និងជាប្រចាំ។ គ្រូបង្រៀនបានផ្សារភ្ជាប់បច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រួលដល់ដំណើរការបង្រៀន និងរៀន ការរៀបចំកិច្ចការរដ្ឋបាល ការស្រាវជ្រាវ និងមានចំណេះដឹងភាសាបរទេសទូលំទូលាយ។ ការប្រតិបត្តិវិជ្ជាជីវៈប្រកបដោយការទទួលខុសត្រូវ និងមានបំណិនសតវត្សទី២១ ដើម្បីជំរុញគុណភាពអប់រំរីកចម្រើន

ទៅមុខជាលំដាប់ (តារាង ១៨ ឧត្តមមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ)។




ក្រាហ្វ 6 ឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

ក្រាហ្វ ៦ ខាងលើបង្ហាញពីតម្លៃមធ្យម (M) អ្នកចូលរួមដែលឆ្លើយតបទៅនឹងឧត្តមានុវត្តនៃការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។ ខាងក្រោមនេះ គឺជាកំណត់សម្គាល់បន្ថែមដើម្បីជំនួយដល់ការស្វែងយល់អំពីទិន្នន័យរបស់ក្រាហ្វ ៦៖

តារាង 19 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៦

| លេខសម្គាល់ | ការបរិយាយ | | |
|---|---|---|---|
| | សូចនាករ | ផ្នែកនៃឧបករណ៍សម្ភាសន៍ | ខ្លឹមសារ |
| 17 | ទី១៧ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិជាចំណុចចាប់ផ្តើមនៃការធានាគុណភាពអប់រំនៅកម្ពុជា |
| 18 | ទី១៨ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀនទទួលបានគ្រូបង្រៀនដែលមានទាំងចំណេះដឹង គុណវុឌ្ឍិ ជំនាញ សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ |
| 19 | ទី១៩ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិទទួលបានគ្រូបង្រៀនដែលយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀបរៀន ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សារបស់សិស្ស |
| 20 | ទី២០ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀនទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពក្នុងការរៀបចំកិច្ចតែងការ ផលិតសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀនមានប្រសិទ្ធភាព |
| 21 | ទី២១ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀនដែលចេះប្រើប្រាស់វិធីសាស្ត្របង្រៀន និងចេះជ្រើសរើសវិធីវង្វាយតម្លៃលទ្ធផលសិក្សាសិស្សបានសមស្រប |

| | | | |
|---|---|---|---|
| 22 | ទី២២ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀន ដែលចេះបញ្ជ្រាបខ្លឹមសារពីមេរៀនមួយទៅមេរៀនមួយ ឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តចង់រៀន |
| 23 | ទី២៣ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀន ដែលចេះដោះស្រាយបញ្ហាប្រឈមក្នុងការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន |
| 24 | ទី២៤ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀន ដែលចេះរៀបចំកម្មវិធីសិក្សា និងផែនការបង្រៀនបានត្រឹមត្រូវ |
| 25 | ទី២៥ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀន ដែលចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាផ្សារភ្ជាប់នឹងការបង្រៀន ភាសា និងមានគំនិតច្នៃប្រឌិត |
| 26 | ទី២៦ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូទទួលបានគ្រូបង្រៀន ដែលមានការទទួលខុសត្រូវខ្ពស់ និងប្រតិបត្តិវិជ្ជាជីវៈបានល្អ |
| 27 | ទី២៧ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀន ដែលចេះផ្តល់ឱកាសឱ្យសិស្សចេះដោះស្រាយបញ្ហាស្វ័យសិក្សា និងមានភាពម្ចាស់ការ |
| 28 | ទី២៨ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលទទួលបានគ្រូបង្រៀន ដែលមានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវ ពង្រីកចំណេះដឹង និងចេះចែករំលែក |
| 29 | ទី២៩ | ផ្នែកទី៣ | គ្រូបង្រៀនកម្រិតឧត្តមចេញថ្មីឆ្នាំ២០២០ និង២០២២ ពិតជាមានគុណវុឌ្ឍិ និងសមត្ថភាពវិជ្ជាជីវៈសមស្រប សម្រាប់ការអប់រំសតវត្សទី២១ |

## ៤.៣ ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់

### ៤.៣.១ ការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ

ផ្អែកតាមការវិភាគទិន្នន័យដែលទទួលបានពីឧបករណ៍សម្ភាសន៍ ផ្នែកទី២៖ ការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ ចាប់ពីសូចនាករទី១០ ដល់ទី១៦ បានបង្ហាញនូវលទ្ធផលស្តីពីការចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ តាមរយៈការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាដូចខាងក្រោម៖

តារាង 20 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូ

| | ការបរិយាយ | មធ្យមភាគ (M) | គម្លាតស្តង់ដា (SD) | មិនយល់ស្របទាំងស្រុង | មិនយល់ស្រប | អព្យាក្រឹត | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|
| ១០ | ស្ថានភាព លើស-ខ្វះ គ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាប្រឈមដល់ការគ្រប់គ្រងបុគ្គលិក គុណភាពរៀន និងបង្រៀន | 4.40 | 0.62 | 0.00% | 0.00% | 2.33% | 53.49% | 44.19% |
| ១១ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិទទួលបានអគ្រាធនធានមនុស្សក្នុងមូលដ្ឋានខ្ពស់ដើម្បីក្លាយជាគ្រូបង្រៀនគោលបំណងចូលរួមចំណែកដោះស្រាយបញ្ហាខ្វះគ្រូបង្រៀនពុំរ៉ៃ | 3.47 | 1.28 | 6.98% | 25.58% | 2.33% | 44.19% | 20.93% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនកាត់បន្ថយអត្រាផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ | 3.74 | 1.11 | 0.00% | 25.58% | 0.00% | 48.84% | 25.58% |
| ១៣ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនកាត់បន្ថយអត្រាស្ថានភាពលើស-ខ្វះគ្រូបង្រៀនតាមគ្រឹះស្ថានសិក្សា និងអង្គភាព | 4.42 | 0.63 | 0.00% | 2.33% | 0.00% | 51.16% | 46.51% |
| ១៤ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនជះឥទ្ធិពលល្អដល់ការចាត់តាំងភារកិច្ច និងការគ្រប់គ្រងបុគ្គលិក | 4.42 | 0.54 | 0.00% | 0.00% | 2.33% | 53.49% | 44.19% |
| ១៥ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនទទួលបានគ្រូបង្រៀនដែលមានការពេញចិត្តក្នុងការបង្រៀនបង្រៀនមានគុណភាពនាំឱ្យសិស្សយល់តម្លៃ និងចូលរៀនឡើងវិញ | 4.19 | 0.55 | 0.00% | 0.00% | 6.98% | 67.44% | 25.58% |
| ១៦ | គ្រូបង្រៀនកម្រិតឧត្តមចេញថ្មីឆ្នាំ២០២០ និង ២០២២ ពិតជាបានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅតាមគ្រឹះស្ថានសិក្សា | 4.30 | 0.71 | 0.00% | 4.65% | 0.00% | 55.81% | 39.53% |

យោងតាមលទ្ធផលនៃការវិភាគទិន្នន័យ នៃការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ និងផ្អែកលើតម្លៃមធ្យម (M) របស់សូចនាករនីមួយៗ លើសពីកម្រិត ៣.៥០ បានបង្ហាញឱ្យឃើញថា កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា បានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង នៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិបានមួយផ្នែកធំ។ ជាក់ស្តែង កំណែទម្រង់បានចូលរួមចំណែកដោះស្រាយបញ្ហាលើគុណភាពរៀន និងបង្រៀន កាត់បន្ថយនូវស្ថានភាពលើស-ខ្វះគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា កាត់បន្ថយនូវអត្រានៃការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ ជួយសម្រួលដល់ការដឹកនាំគ្រប់គ្រង និងការចាត់តាំងភារកិច្ចបុគ្គលិកអប់រំក្រោមឱវាទរបស់គណៈគ្រប់គ្រងសាលារៀន ដោយជានាបាននូវការបែងចែកភារកិច្ចបុគ្គលិកអប់រំតាមជំនាញ តាមសមត្ថភាព តាមកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈសមស្របនឹងតម្រូវការប្រើប្រាស់ ជាពិសេស គឺទទួលបានគ្រូបង្រៀនដែលពេញចិត្តនឹងការបំពេញការងារនៅតាមប៉ុស្តិ៍ដែលសាមីជនបានជ្រើសរើស និងស្រលាញ់អាជីពរបស់ខ្លួន។

បើទោះបីជា កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនបានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនានាបានមួយផ្នែកធំក៏ពិតមែន ប៉ុន្តែចំពោះបញ្ហាប្រឈមនៃការទទួលបានអត្រាធនធានមនុស្សក្នុងមូលដ្ឋានខ្ពស់ដើម្បីក្លាយជាគ្រូបង្រៀនគោលបំណងចូលរួមចំណែកដោះស្រាយបញ្ហាខ្វះគ្រូបង្រៀនពុំរ៉ែ នៅតំបន់នោះ មិនទាន់ទទួលបានលទ្ធផលជាវិជ្ជមាននៅឡើយ ដោយការបើកទូលាយនៃការប្រកួតប្រជែងឱ្យមានបេក្ខជនពីក្រៅមូលដ្ឋានអាចដាក់ពាក្យប្រឡងជ្រើសរើសបាន និងការកំណត់នូវចំនួនមុខវិជ្ជាឯកទេសតាមគ្រឹះស្ថានសិក្សា និងផ្អែកតាមតម្លៃមធ្យម (M) កម្រិត ៣.៤៧ (តារាង២០ ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូ)។




ក្រាហ្វ 7 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូ

ក្រាហ្វ ៧ ខាងលើបង្ហាញពីតម្លៃមធ្យម (M)របស់អ្នកចូលរួម ឆ្លើយតបចំពោះការអនុវត្តកំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ពីដំណោះស្រាយលើបញ្ហាប្រឈមដែលធ្លាប់បានកើតមានឡើងនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ។ ខាងក្រោមនេះគឺជាកំណត់សម្គាល់បន្ថែមដើម្បីជំនួយដល់ការស្វែងយល់អំពីទិន្នន័យរបស់ក្រាហ្វ ៧៖

តារាង 21 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៧

| លេខសម្គាល់ | ការបរិយាយ | | |
|---|---|---|---|
| | សូចនាករ | ផ្នែកនៃឧបករណ៍សម្ភាសន៍ | ខ្លឹមសារ |
| 10 | ទី១០ | ផ្នែកទី២ | ស្ថានភាពលើស-ខ្វះគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាប្រឈមដល់ការគ្រប់គ្រងបុគ្គលិក គុណភាពរៀន និងបង្រៀន |
| 11 | ទី១១ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិទទួលបានអត្រាធនធានមនុស្សក្នុងមូលដ្ឋានខ្ពស់ដើម្បីក្លាយជាគ្រូបង្រៀនគោលបំណងចូលរួមចំណែកដោះស្រាយបញ្ហាខ្វះគ្រូបង្រៀនពុំរើ |
| 12 | ទី១២ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនកាត់បន្ថយអត្រាផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ |
| 13 | ទី១៣ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនកាត់បន្ថយអត្រាស្ថានភាពលើស-ខ្វះគ្រូបង្រៀនតាមគ្រឹះស្ថានសិក្សា និងអង្គភាព |
| 14 | ទី១៤ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនជះឥទ្ធិពលល្អដល់ការចាត់តាំងភារកិច្ច និងការគ្រប់គ្រងបុគ្គលិក |
| 15 | ទី១៥ | ផ្នែកទី២ | កំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនទទួលបានគ្រូបង្រៀនដែលមានការពេញចិត្តក្នុងការបង្រៀន បង្រៀនមានគុណភាពនាំឱ្យសិស្សយល់តម្លៃ និងចូលរៀនឡើងវិញ |
| 16 | ទី១៦ | ផ្នែកទី២ | គ្រូបង្រៀនកម្រិតឧត្តមចេញថ្មីឆ្នាំ២០២០ និង២០២២ពិតជាបានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅតាមគ្រឹះស្ថានសិក្សា |

## ៤.៣.២ ការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

តារាង 22 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ

| | ការបរិយាយ | តម្លៃមធ្យម (M) | គម្លាតស្តង់ដា (SD) | មិនយល់ស្របទាំងស្រុង | មិនយល់ស្រប | អព្យាក្រឹត | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|
| ៣០ | គ្រូបង្រៀនខ្វះគុណវុឌ្ឍិ ខ្វះជំនាញខ្វះសមត្ថភាព ជាកត្តាបណ្តាលឱ្យ សិស្សមិនចូលរួម សកម្មភាពសិក្សា | 4.30 | 0.74 | 0.00% | 4.65% | 2.33% | 51.16% | 41.86% |
| ៣១ | កំណែទម្រង់ការបណ្តុះ បណ្តាលគ្រូបង្រៀន ជម្រុញឆន្ទៈចូលរួម អភិវឌ្ឍសាលារៀន គាំទ្រ ការសិក្សា និងសុខមាល ភាពរបស់សិស្សនិងអ្នក រួមអាជីព និងមានទំនាក់ ទំនងល្អក្នុងអង្គភាព | 4.16 | 0.43 | 0.00% | 0.00% | 2.33% | 79.07% | 18.60% |
| ៣២ | ការពង្រីករយៈពេលនៃ ការបណ្តុះបណ្តាលបាន ជួយឱ្យគ្រូបង្រៀនមធ្យម សិក្សាទុតិយភូមិមាន ភាពប្រសើរឡើងលើវិជ្ជា សម្បទា បំណិនសម្បទា ចរិយាសម្បទា និងភាព ស៊ីជម្រៅនៃការអនុវត្ត វិជ្ជាជីវៈ | 4.44 | 0.55 | 0.00% | 0.00% | 2.33% | 51.16% | 46.51% |

ផ្អែកតាមការវិភាគទិន្នន័យដែលទទួលបានពីឧបករណ៍សម្ភាសន៍ ផ្នែកទី៣៖ ការអនុវត្ត កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ចាប់ពីសូចនាករទី៣០ ដល់ទី៣២ បានបង្ហាញ នូវលទ្ធផលស្តីពីការចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ តាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដូចបានបង្ហាញ ក្នុងតារាង ២២ ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ។ ផ្អែកតាមតម្លៃមធ្យម (M) របស់សូចនាករនីមួយៗលើសពី ៣.៥០ បានបង្ហាញឱ្យឃើញថា កំណែទម្រង់ ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា បានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈម ចម្បងៗដែលនាំឱ្យប៉ះពាល់ដល់ដំណើរការបង្រៀន និងរៀន។ បន្ទាប់ពីទទួលការបណ្តុះបណ្តាលនៅវិទ្យា ស្ថានជាតិអប់រំ គ្រូបង្រៀនចេញថ្មីទាំងអស់ទទួលបាននូវគុណវុឌ្ឍិខ្ពស់ មានជំនាញ សមត្ថភាពពេញលេញ មានបំណិនទាក់ទាញឱ្យសិស្សចូលរួមសកម្មភាពសិក្សា និងយល់ពីតម្លៃនៃការសិក្សា។ លើសពីនេះទៅ ទៀត គ្រូបង្រៀនមានភាពប្រសើរឡើងលើវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងភាពស៊ីជម្រៅ ក្នុងការអនុវត្តវិជ្ជាជីវៈ ថែមទាំងជាបុគ្គលដែលមានឆន្ទៈមោះមុត និងមានស្មារតីចូលរួមគាំទ្រដល់ការ អភិវឌ្ឍន៍អង្គភាព គាំទ្រការសិក្សាសិស្ស និងគិតគូរពីបរិយាកាសសាលារៀន ថ្នាក់រៀន ចេះរួមរស់ ចេះធ្វើ ការប្រកបដោយភាពសោមនស្សរីករាយ និងស្មារតីសាមគ្គីជាភាតរភាព (តារាង ២២ ដំណោះស្រាយបញ្ហា ប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ)។




ក្រាហ្វ 8 ដំណោះស្រាយបញ្ហាប្រឈមតាមរយៈការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ

ក្រាហ្វ ៨ ខាងលើបង្ហាញពីតម្លៃមធ្យម (M) របស់អ្នកចូលរួម ឆ្លើយតបចំពោះការអនុវត្តកំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ពីដំណោះស្រាយលើបញ្ហាប្រឈមដែលធ្លាប់បានកើតមានឡើងនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ។ ខាងក្រោមនេះគឺជាកំណត់សម្គាល់បន្ថែមដើម្បីជំនួយដល់ការស្វែងយល់អំពីទិន្នន័យរបស់ក្រាហ្វ ៨៖

តារាង 23 កំណត់សម្គាល់ទិន្នន័យក្រាហ្វ៨

| លេខសម្គាល់ | ការបរិយាយ | | |
|---|---|---|---|
| | សូចនាករ | ផ្នែកនៃឧបករណ៍សម្ភាសន៍ | ខ្លឹមសារ |
| 30 | ទី៣០ | ផ្នែកទី៣ | គ្រូបង្រៀនខ្វះគុណវុឌ្ឍិ ខ្វះជំនាញ ខ្វះសមត្ថភាព ជាកត្តាបណ្តាលឱ្យសិស្សមិនចូលរួមសកម្មភាពសិក្សា |
| 31 | ទី៣១ | ផ្នែកទី៣ | កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀនជម្រុញឆន្ទៈចូលរួមអភិវឌ្ឍសាលារៀន គាំទ្រការសិក្សា និងសុខមាលភាពរបស់សិស្សនិងអ្នករួមអាជីព និងមានទំនាក់ទំនងល្អក្នុងអង្គភាព |

| | | | |
|---|---|---|---|
| 32 | ទី៣២ | ផ្នែកទី៣ | ការពង្រីករយៈពេលនៃការបណ្តុះបណ្តាលបានជួយឱ្យគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិមានភាពប្រសើរឡើងលើវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងភាពស៊ីជម្រៅនៃការអនុវត្តវិជ្ជាជីវៈ |

## ៤.៤ ការពិភាក្សាពីការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូ

### ៤.៤.១ កំណែទម្រង់ការជ្រើសរើសគ្រូមធ្យមសិក្សាទុតិយភូមិ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ នាយកសាលាមានការសាទរ និងកោតសរសើរចំពោះកំណែទម្រង់ការជ្រើសរើសគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដោយហេតុថាបន្ទាប់ពីការអនុវត្តកំណែទម្រង់នេះ គ្រឹះស្ថានសិក្សាជាពិសេសកម្រិតមធ្យមសិក្សាទុតិយភូមិទទួលបាន៖

- ទទួលគ្រូបង្រៀនចេញថ្មីឆ្លើយតបនឹងតម្រូវការប្រើប្រាស់របស់គ្រឹះស្ថានសិក្សា
- កាត់បន្ថយអត្រាស្ថានភាពលើស-ខ្វះគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា
- កាត់បន្ថយអត្រានៃការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំបានមួយកម្រិត
- សម្រួលដល់ការដឹកនាំគ្រប់គ្រង និងការបែងចែកភារកិច្ចបុគ្គលិកអប់រំក្រោមឱវាទ
- គ្រូបង្រៀនចេញថ្មីមានការពេញចិត្ត យកចិត្តទុកដាក់ការបង្រៀន មានមនសិការការងារ មានមោទនភាពលើអាជីព និងវិជ្ជាជីវៈរបស់ខ្លួន

### ៤.៤.២ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ នាយកសាលាមានពេញចិត្ត និងមោទនភាពចំពោះកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដោយហេតុថា បន្ទាប់ពីការអនុវត្តកំណែទម្រង់នេះ គ្រឹះស្ថានសិក្សាជាពិសេសកម្រិតមធ្យមសិក្សាទុតិយភូមិទទួលបាន៖

- គ្រូបង្រៀនមានគុណភាព សមត្ថភាព ចំណេះដឹង គុណវុឌ្ឍិ ជំនាញ បំណិន និងក្រមសីលធម៌ធានាបានប្រសិទ្ធភាពនៃការបង្រៀន និងរៀន
- សិស្សមានលទ្ធភាពសិក្សារៀនសូត្រតាមបែបស្វ័យសិក្សា ចេះដោះស្រាយបញ្ហា ចេះស្រាវជ្រាវចេះរៀនតាមរបៀបរៀនថ្មីៗ និងចូលរួមសកម្មភាពសិក្សា

- គុណភាពអប់រំត្រូវបានលើកកម្ពស់តាមរយៈការរៀនបែបសកម្ម និងរូបី ដោយមានការប្រើប្រាស់សម្ភារឧបទេស បច្ចេកវិទ្យា និងប្រព័ន្ធវង្វាយតម្លៃលទ្ធផលសិក្សា
- អង្គភាពរីកចម្រើនដោយសារគ្រូបង្រៀនមានការអភិវឌ្ឍន៍បុគ្គលជាប្រចាំ និងចេះចែករំលែកចំណេះដឹង បទពិសោធរវាងគ្នា និងគ្នា
- គ្រូបង្រៀនមានចំណេះដឹង ជំនាញ និងបំណិនសតវត្សទី២១ នាំឱ្យសិស្សបានទទួលចំណេះដឹងសតវត្សទី២១។

សរុបមក កំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ពិតជាមានប្រសិទ្ធភាពដល់ការដោះស្រាយបញ្ហាប្រឈមនានាដែលធ្លាប់កើតមាននៅតាមគ្រឹះស្ថានសិក្សា និងដឹកនាំគុណភាពអប់រំកម្ពុជាឱ្យមានការរីកចម្រើនទៅមុខដោយវិជ្ជមានជាលំដាប់។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការវិភាគទិន្នន័យដែលជាលទ្ធផលចម្បងរបស់ការសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ការអនុវត្តកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ពិតជាមានផលជះវិជ្ជមានដល់គុណភាពអប់រំនៅកម្ពុជា ជាពិសេសនៅកម្រិតសាលារៀនមធ្យមសិក្សាទុតិយភូមិ ដោយបានជ្រើសរើសគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់នៅតាមគ្រឹះស្ថានសិក្សា បានជួយកាត់បន្ថយស្ថានភាពលើស-ខ្វះគ្រូបង្រៀន និងការប្រើប្រាស់ធនធានគ្រូបង្រៀនខ្ជះខ្ជាយ។ បន្ថែមពីនេះទៀត គ្រូបង្រៀនដែលទទួលបានគឺពោរពេញដោយចំណេះដឹង សមត្ថភាព ក្របខ័ណ្ឌគុណវុឌ្ឍិខ្ពស់ មានបំណិន មានឆន្ទៈ មានការទទួលខុសត្រូវ មានក្រមសីលធម៌ ជាពិសេសមានមោទនភាព និងការពេញចិត្តចំពោះអាជីពរបស់ខ្លួន។

លើសពីនេះទៅទៀត គ្រូបង្រៀនបានចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំ និងលើកស្ទួយវិស័យអប់រំ ដោយការប្រើប្រាស់ចំណេះដឹងវិជ្ជាជីវៈអាជីពដើម្បីអប់រំ បណ្តុះបណ្តាលសិស្សានុសិស្ស ជួយគាំទ្រការសិក្សារបស់សិស្ស និងចូលរួមដោះស្រាយបញ្ហាប្រឈមលើការសិក្សា។ មិនតែប៉ុណ្ណោះ ជាចលករជំរុញឱ្យគ្រូបង្រៀនកម្រិតឧត្តមដែលមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ មានចិត្តចង់បន្តការសិក្សាយកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬជំនាញវិជ្ជាជីវៈបន្ថែម ដើម្បីបានស្មើមុខស្មើមាត់នឹងអ្នកជំនាន់ក្រោយ ដោយសារក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាល បរិញ្ញាបត្រ+២ ថ្មីនេះ បានផ្តល់នូវកម្រិតសញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់អប់រំ។ ផលជះទាំងនេះ បានបញ្ជាក់ឱ្យឃើញថាបញ្ហាប្រឈមមួយចំនួនធំដែលធ្លាប់កើតមាននៅតាមគ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិត្រូវបានដោះស្រាយជាបណ្តើរៗ តាមរយៈការអនុវត្តកំណែទម្រង់ ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។

ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមមួយចំនួននៅតែមិនទាន់បានដោះស្រាយ ជាក់ស្តែង ការលើកកម្ពស់អត្រាធនធានមនុស្សក្នុងមូលដ្ឋានដើម្បីក្លាយជាគ្រូបង្រៀន នៅមិនទាន់ទទួលបានលទ្ធផលល្អ

នៅឡើយ ដោយសារការកំណត់នូវប៉ុស្តិ៍តាមប្រភេទមុខវិជ្ជា និងការអនុញ្ញាតឱ្យបេក្ខជនមកពីមូលដ្ឋានខាងក្រៅអាចមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះប្រឡងធ្វើឱ្យបេក្ខជនក្នុងមូលដ្ឋានត្រូវប្រកួតប្រជែងខ្ពស់។ ទន្ទឹមនឹងគ្នានេះដែរ ការដោះស្រាយបញ្ហាប្រឈមលើអត្រានៃការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំនៅមានកម្រិត ដោយហេតុថាការកំណត់ប៉ុស្តិ៍បម្រើការងារជាមុនធ្វើឱ្យបេក្ខជនដែលមានបំណងចង់ក្លាយជាគ្រូបង្រៀនកម្រិតឧត្តម និងដើម្បីទទួលបានក្របខ័ណ្ឌខ្ពស់ជាងក្របខ័ណ្ឌបច្ចុប្បន្ន ដូចនេះបេក្ខជនត្រូវបង្ខំចិត្តដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅប៉ុស្តិ៍ដែលស្ថិតនៅឆ្ងាយពីអាសយដ្ឋានរស់នៅរបស់ខ្លួន ដូចជាឆ្លងស្រុក ឬឆ្លងខេត្តជាដើម ហើយនឹងធ្វើការស្នើសុំផ្លាស់ប្តូរទីកន្លែងបម្រើការងារបន្ទាប់ពីមានការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ឬគ្រប់កិច្ចសន្យាកំណត់។

ជាពិសេស ការដែលអនុញ្ញាតឱ្យគរុនិស្សិតកំពុងទទួលការបណ្តុះបណ្តាលមានសិទ្ធិប្រឡងចូលបម្រើការងារនៅសាលាជំនាន់ថ្មី ឬការចាត់តាំងគរុនិស្សិតចេញថ្មីបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលទៅបម្រើការងារនៅសាលាជំនាន់ថ្មី ឬអង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំតាមរយៈការប្រឡងជាប់ ឬសម្ភាសន៍ជាប់ ខណៈដែលគរុនិស្សិតបានជ្រើសរើសប៉ុស្តិ៍បម្រើការងារនៅតាមគ្រឹះស្ថានសិក្សាដែលមានតម្រូវការគ្រូបង្រៀនមុនប្រឡងរួចហើយ ជាហេតុបណ្តាលឱ្យការផ្គត់ផ្គង់គ្រូមិនទាន់បានគ្រប់ជ្រុងជ្រោយតាមផែនការកំណត់។

ករណីដោយឡែក គ្រូបង្រៀនកម្រិតបឋម និងកម្រិតមូលដ្ឋានមួយចំនួនដែលមានទីកន្លែងបម្រើការងារនៅជិតទីលំនៅរស់នៅបច្ចុប្បន្ន មិនបានដាក់ពាក្យសុំចុះឈ្មោះប្រឡងគ្រូបង្រៀនកម្រិតឧត្តម ដែលអាក់ខានដល់ការរីកចម្រើនគុណវុឌ្ឍិ និងវិជ្ជាជីវៈគ្រូបង្រៀន ដោយសារប៉ុស្តិ៍ដែលប្រឡងជ្រើសរើសមានទីតាំងនៅឆ្ងាយ។ តាមរយៈការយល់ឃើញរបស់នាយក នាយិកា នាយករង នាយិការងសាលារៀនមួយចំនួនបានសង្កេតឃើញថា គ្រូបង្រៀនដែលជាអតីតបុគ្គលិកមួយចំនួនហាក់មិនសូវមានភាពរីកចម្រើនក្នុងការបណ្តុះបណ្តាលក្របខ័ណ្ឌថ្មី បើធៀបជាមួយគ្រូបង្រៀនដែលជាអតីតនិស្សិត នៅពេលចេញបម្រើការងារ។

## ៥.២ សំណូមពរ

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវ និងអ្នកចូលរួមសម្ភាសន៍សូមធ្វើការសំណូមពរដល់ភាគីពាក់ព័ន្ធរួមមានៈ

**ក.ក្រសួងអប់រំ យុវជន និងកីឡា**

❈នីតិវិធីនៃការជ្រើសរើស

- បន្តអនុវត្តនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមដូចបានអនុវត្តនៅ ឆ្នាំ២០២៣
- ត្រូវកំណត់អាទិភាព និងគោលដៅសម្រាប់បេក្ខជនដែលអាចមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅតាមប៉ុស្តិ៍ ដោយផ្តល់អាទិភាពដល់បេក្ខជននៅក្នុងមូលដ្ឋាន កំណត់ត្រឹមលក្ខខណ្ឌ ស្រុក-ខ័ណ្ឌ
- ក្រសួងអប់រំ យុវជន និងកីឡា គួរចាប់ផ្តើមអនុវត្តគន្លងអាជីពគ្រូបង្រៀនប្រកបដោយតម្លាភាពដើម្បីលើកទឹកចិត្តឱ្យគ្រូបង្រៀនអនុវត្តតួនាទី ភារកិច្ចឱ្យបានល្អប្រសើរ
- ជ្រើសរើសក្របខ័ណ្ឌគ្រូបង្រៀនទទួលបន្ទុកសុខភាពសិក្សា (គរុនិស្សិតកម្រិតឧត្តម) ដោយជ្រើសរើសចេញពីបេក្ខជនដែលមានសញ្ញាបត្រផ្នែកសុខាភិបាល(ផ្អែកតាមរយៈការបង្កើតឱ្យមានការអនុវត្តកម្មវិធីសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា)។

❈កិច្ចសន្យាការងារ

- កំណត់កិច្ចសន្យាបម្រើការងារឱ្យបានច្បាស់លាស់
- ជៀសវាងការផ្លាស់ប្តូរប៉ុស្តិ៍បេក្ខជនក្រោយបញ្ចប់ការបណ្តុះបណ្តាល ទៅបម្រើការងារនៅក្រោមឱវាទទីស្តីការក្រសួងអប់រំ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ឬសាលាជំនាន់ថ្មី ដោយមិនត្រូវអនុញ្ញាតឱ្យមានការប្រឡងចូល ឬសម្ភាសន៍ពេលកំពុងទទួលការបណ្តុះបណ្តាល
- ពិនិត្យរាល់សេចក្តីណែនាំ នៃការអនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ ដោយបញ្ចូលលក្ខខណ្ឌកិច្ចសន្យាចំពោះគ្រូបង្រៀនចេញថ្មីក្នុងសេចក្តីណែនាំ ស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងារដើម្បីធានាបានថា គ្រូបង្រៀនដែលបានបណ្តុះបណ្តាល

ក្នុងដំណាក់កាលនៃការអនុវត្តកំណែទម្រង់ នឹងមិនអាចផ្លាស់ប្តូរទីកន្លែងបម្រើការងារមុនកិច្ចសន្យាកំណត់

- គិតអតីតភាពបម្រើការងារជាថ្មី ចំពោះបុគ្គលិកអប់រំដែលផ្លាស់ប្តូរទីកន្លែងបម្រើការងារមុនកិច្ចសន្យាកំណត់។

**ខ.វិទ្យាស្ថានជាតិអប់រំ**

❈កម្មវិធីសិក្សា

- រៀបចំផែនការបណ្តុះបណ្តាលគ្រូដឹកនាំកម្មសិក្សា និងគ្រូនៅសាលាគោលដៅ ដែលទទួលកម្មសិក្សាការីដើម្បីឱ្យដំណើរការចុះកម្មសិក្សារបស់គរុនិស្សិតមានដំណើរការល្អ ប្រើប្រាស់វិធីសាស្ត្រ ទម្រង់នៃការអនុវត្តការងារតាមបែបផែនផ្លូវការតែមួយ
- គ្រូដឹកនាំកម្មសិក្សាត្រូវចុះពិនិត្យតាមដានជាប្រចាំជាមួយកម្មសិក្សាការី
- គរុនិស្សិតត្រូវចុះកម្មសិក្សានៅតាមគ្រឹះស្ថានសិក្សា ឬប៉ុស្តិ៍ដែលបានជ្រើសរើស
- រៀបចំកម្មវិធីឱ្យគរុនិស្សិតបង្រៀនថ្នាក់និទស្សន៍មុនចុះកម្មសិក្សា និងក្រោយចុះកម្មសិក្សា
- ពង្រីករយៈពេលនៃការចុះកម្មសិក្សា
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សានៅតាមសាលារៀនដែលមាននាយកសាលាល្អ គ្រូបង្រៀនល្អ សាលារៀនស្អាត និងសាលារៀនដែលមានផ្តល់សេវាសាធារណៈគំរូ
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សាក្រៅប្រទេសដល់គរុនិស្សិតឆ្នើម
- ពង្រឹងកម្រិតកិច្ចការស្រាវជ្រាវរបស់គរុនិស្សិត
- បញ្ចូលមុខវិជ្ជាចាំបាច់ជាឯកទេសទី២សម្រាប់គ្រប់មុខវិជ្ជាឯកទេសទី១ដែលពាក់ព័ន្ធ ដូចជា មុខវិជ្ជាកសិកម្ម បំណិនជីវិត សិល្បៈ គណនេយ្យ អេឡិចត្រូនិច
- ពង្រឹងកម្មវិធីសិក្សាផ្នែកព័ត៌មានវិទ្យា និងភាសាបរទេសដល់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ឱ្យបានស៊ីជម្រៅ

- រៀបចំកម្មវិធីសិក្សាអំពីការរៀបចំតេស្តស្តង់ដា ការប្រើប្រាស់សន្លឹកកិច្ចការ កិច្ចការរដ្ឋបាលឱ្យបានស៊ីជម្រៅ ដោយឱ្យការអនុវត្តច្រើនជាទ្រឹស្តី។

គ.អ្នកស្រាវជ្រាវបន្ត

- សិក្សាស្រាវជ្រាវគ្រប់ដណ្តប់ក្របខ័ណ្ឌទូទាំងប្រទេស
- សិក្សាពីកម្រិតសមត្ថភាពវិជ្ជាជីវៈ និងការប្រតិបត្តិវិជ្ជាជីវៈគរុនិស្សិតជាអតីតបុគ្គលិក និងអតីតនិស្សិតនៅក្នុងកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ។

# ឯកសារយោង

# ឯកសារយោង

Adeosun, O. (2014). Teacher education programmes and the acquisition of 21st century Retrieved 14th March. skills: Issues and challenges in Nigeria.

Adu-Darkoh, M. . (2014). Employee recruitment and selection practices in the construction industry in Ashanti Region (Doctoral dissertation).

Andreas, S. (2012). Preparing teachers and Developing School Leaders for the 21 Century. Paris: OEDC Publishing.

Bach, S. (2005). Personnel management in transition. Managing Human Resources: Personnel Management in Transition.

Benveniste, L., Marshall, J., & Araujo, M. C. (2008a). Teaching in Cambodia.

Benveniste, L., Marshall, J., & Araujo, M. C. (2008b). Teaching in Cambodia.

Benveniste, L., Marshall, J., & Araujo, M. C. (2008c). Teaching in Cambodia.

